# មគ្គុទេ្ទសក៏ម្នាក់

សូមព្រះជាម្ចាស់ប្រទានពរ ប្អូនប្រុសនីវៀល។

មានសេចក្តីអំណរណាស់ដែលបានវិលមកព្រះវិហារវិញនៅយប់នេះ។ គ្រាន់តែមានសំឡេងស្អកបន្តិច។ ព្រះរាជសារក៏ហាក់ដូចជាវែងបន្តិចដែរ នាព្រឹកនេះ ហើយ ខ្ញុំមានអំណរដែលបាននៅទីនេះ។ ហើយខ្ញុំក៏ពេញចិត្តនឹងខ្លួនឯងដែរ ចំពោះ ការ នាំមកនូវព្រះរាជសារ ហើយខ្ញុំក៏សង្ឃឹមថាអ្នកក៏ពេញចិត្តស្តាប់វាដែរ។ [ក្រុមជំនុំ ស្រែកថា "អាម៉ែន"—Ed។]

2 កុំភ្លេចឥឡូវនេះ ត្រូវចងចាំវាជានិច្ចថាទាំងនេះគឺជាកិច្ចការដែលស្អាង អ្នកបំរើរបស់ព្រះគ្រីស្ទឡើង។ ឃើញថា សេចក្តីជំនឿជាទីមួយ បន្ទាប់មកគុណធម៌។ ហើយឥឡូវត្រូវចងចាំព្រះវិញ្ញាណបរិសុទ្ធ មិនអាចទប់ស្កាត់ការស្អាងឡើងនៃ ព្រះជា ម្ចាស់បានទេរហូតដល់កិច្ចការទាំងនេះ ត្រូវបានប្រតិបត្តិការដោយព្រះវិញ្ញាណបរិសុទ្ធ។ មិនថាអ្នកធ្វើអ្វីនោះទេ ឃើញ។ ទាំងនោះគឺជាអ្វីដែលកសាងរូប កាយរបស់ ព្រះគ្រីស្ទឡើង ឃើញទេ។ ឥឡូវនេះកុំភ្លេចកិច្ចការទាំងនោះ ថាអ្វី *នៅទីនេះ* គឺជាទីមួយ គឺជាសេចក្តីជំនឿរបស់អ្នក។ គុណធម៌ ចំណេះដឹង ជាដើម គឺនឹងត្រូវបានបន្ថែមពីលើនោះរហូតដល់ព្រះកិត្តិនាមពេញ លេញ នៅក្នុងព្រះគ្រីស្ទ ត្រូវបានសម្តែងឡើងបន្ទាប់មកព្រះវិញ្ញាណបរិសុទ្ធយាង មកសណ្ឋិតលើ ហើយ បោះត្រាជារូបកាយតែមួយ។ អ្វីទាំងនេះត្រូវតែ។ ដូច្នេះ ហើយ ព្រះយេស៊ូវ មាន ព្រះបន្ទូលថា: "ដោយសារផលផ្លែរបស់ពួកគេយើងស្គាល់ពួកគេ។" សូមមើល ផលផ្លែ! អ្នកមិនអាចទទួលផលផ្លែនេះបានដោយគ្មានអ្វីទាំងនោះកើត ឡើង ក្នុងអ្នកនោះទេ។ ហើយបន្ទាប់មកនៅពេលដែលអ្វីទាំងអស់ នេះ កើត ឡើង ចេញពី លោកិយនិង—និង ការមិនកោតខ្លាចព្រះជាដើម បន្ទាប់មក អ្នក មិនជឿ គឺត្រូវ បណ្តេញចេញ ហើយអ្វីដែលមាននៅក្នុងលោកិយត្រូវបានកន្លងបាត់ទៅហើយ នឹង គ្មានអ្វីក្រៅពីស្នាព្រះហស្តថ្មីនៅក្នុងព្រះគ្រីស្ទទេ។ ហើយ បន្ទាប់ មក ទៀត អេភេសូ ៤:៣០ ចែងថា "មិនត្រូវធ្វើអោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ ព្រួយព្រះ ហឫទ័យសោះឡើយ ដ្បិតព្រះអង្គបានដៅសញ្ញាសំគាល់របស់ព្រះវិញ្ញាណមកលើបងប្អូនទុក សំរាប់ ថ្ងៃ ដែល ព្រះអង្គ នឹង យាង មក លោះ យើង។" ត្រាដៅ សម្គាល់ នៅក្នុង

ព្រះរាជរបស់ព្រះជាម្ចាស់! ឥឡូវចូរកុំភ្លេច។ ត្រូវរក្សាកិច្ចការ *ទាំងនេះ*នៅ ក្នុងគំនិតឥឡូវ។ យកកិច្ចការ*នេះ*ជាទីមួយ។ បន្ទាប់មកមានត្រាដៅសម្គាល់គឺព្រះវិញ្ញាណបរិសុទ្ធ សញ្ញាដៅនោះបានដៅទៅក្នុងរូបកាយរបស់យើង។ ត្រឹមត្រូវហើយ។

3 យើងមាន—សំណូមពរមួយពេលនេះសម្រាប់ប្អូនស្រីលីថលនៅរដ្ឋឈីកាហ្គោ ប្ដីរបស់គាត់ជួបគ្រោះថ្នាក់រថយន្តមួយ និងស្ថិតនៅក្នុង ស្ថានភាពគ្រោះថ្នាក់ដល់ ជីវិត។ ហើយប្អូនស្រីអ៊ីឌីដវ៉ាយ ដែលយើងបានស្គាល់ អស់រយៈ ពេល ជាយូរ គាត់ ពិត ជា ជួបស្ថានភាពអាក្រក់ខ្លាំងណាស់នៅឯផ្ទះរបស់គាត់ យប់ នេះ ហើយពួកគេចង់ប្រកាសពីការនេះទៅកាន់ក្រុមជំនុំ ដើម្បីឲ្យយើងទាំងអស់គ្នាអាចអធិស្ឋានរួមគ្នាសម្រាប់សំណូមពរនេះ។ ហើយឥឡូវនេះចូរយើងអោនក្បាល របស់យើងចុះមួយភ្លែត។

4 ព្រះវរបិតាដ៏ខ្ពង់ខ្ពស់របស់យើង យើងជួបជុំគ្នា(ដោយជំនឿ) ចំពោះបល្ល័ង្ករបស់ព្រះជាម្ចាស់ ហើយយើងទូលសុំសេចក្ដីមេត្តាមកពីព្រះជាម្ចាស់សម្រាប់ សំណូម ពរទាំងនេះ។ ចំពោះប្អូនប្រុសលីថល ដែលជួបគ្រោះថ្នាក់រថយន្តស្ទើរតែស្លាប់។ ព្រះជាម្ចាស់សូមជួយគាត់។ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធបានគង់នៅក្បែរគ្រែរបស់គាត់ ហើយនាំគាត់ត្រឡប់ មកកាន់ពួកយើងវិញព្រះអម្ចាស់។ ហើយប្អូនស្រី អ៊ីឌីដវ៉ាយ កំពុងតែនៅទីនោះខ្ញុំអធិស្ឋានទៅកាន់ព្រះជាម្ចាស់ ឲ្យព្រះវិញ្ញាណបរិសុទ្ធ គង់នៅក្បែរគ្រែរបស់នាងយប់នេះ ហើយស្ដារសុខភាពរបស់គាត់ឡើងវិញ។ សូមប្រោសប្រទានបិតាអើយ ។ ដូចជាព្រះបន្ទូលសន្យារបស់ព្រះអង្គចំពោះកិច្ចការ ទាំងនេះ ហើយយើងជឿទៅលើព្រះបន្ទូលទាំងនោះ។ ហើយខណៈពេលដែល ពួកយើងបានសញ្ជឹង គិតពីព្រះអង្គនាព្រឹកនេះ ថាទោះជាឆ្ងាយប៉ុណ្ណាក៏ដោយ ក៏ចម្ងាយនោះមិនជាអ្វីទេចំពោះព្រះអង្គ ព្រះអង្គជាព្រះដ៏អស្ចារ្យដែលជាផ្នែកមួយនៃពិភពលោក ក៏ដូចជាផ្នែកម្ខាងទៀតដែរ ពីព្រោះព្រះអង្គជាព្រះដ៏សព្វជ្ញភាព ជាសព្វានុភាព និង គ្មានដែនកំណត់។ ហើយយើងអធិស្ឋាន សូមព្រះវរបិតាទទួលយកសេចក្ដីសំណូមទាំងនេះតាមរយៈ ព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

5 សប្បាយចិត្តខ្លាំងណាស់ដែលមានវត្តមានក្នុងរាត្រីនេះជាថ្មីម្ដងទៀត…ហើយខ្ញុំដឹងថាវាក្ដៅ។ ទាំងនេះគឺជាកិច្ចប្រជុំជាប់គ្នាចំនួនបី ហើយ វា…ខ្ញុំដឹងថាមាន អ្នកមួយចំនួន បើកបររហូតដល់ប្រាំរយម៉ាយចន្លោះពេលនេះ និងពេលព្រឹក។ ហើយ

បន្ទាប់ពីថ្ងៃស្អែកទៅខ្ញុំចាប់ផ្ដើមបើកបរ ពីដប់បួនរយម៉ាយ បន្ទាប់ពីនោះទៀត។ ដូច្នេះ ដូច្នេះ ខ្ញុំ—ខ្ញុំជឿជាក់ថាវាជាពេលវេលាដ៏អស្ចារ្យសម្រាប់អ្នកទាំងអស់គ្នា។ និងជាពេលវេលាដ៏អស្ចារ្យ មួយសម្រាប់ខ្ញុំក្នុងការទៅ សួរសុខទុក្ខជា មួយអ្នក។ មានតែកិច្ចការមួយទេដែលយើង ស្នើរសុំ ដូច្នេះមានមនុស្សជា ច្រើន ត្រូវបាន ដើរទៅឆ្ងាយដោយសារតែមិនមានកន្លែង យើងមិនអាចដាក់ឲ្យណែនណាន់តាន់តាប់ច្រើនពេកទេ ខាងផ្នែកភ្លើងក៏មិនអាចទ្រទ្រង់បានដែរ។ ដូច្នេះឥឡូវនេះយើង កំពុងតែព្យាយាមរកព្រះវិហារធំបន្តិច ដើម្បីពេលដែលចូលទៅខាងក្នុង យើង អាចរៀបចំបន្ទប់អង្គុយសម្រាប់មនុស្សទាំងអស់បាន។

6 ហើយឥឡូវនេះ ពេលណាក៏ដោយ អ្នកតែងតែស្វាគមន៍នៅទីនេះ នៅឯរោងឧបោសថ ដែលមិនមែនជាកន្លែងគោលទ្ធិ តែព្រះគ្រីស្ទ មិនមែន ជាក្រិត្យវិន័យ ទេ តែជាក្ដីស្រឡាញ់ មិនមែនជាសៀវភៅទេ តែគឺព្រះគម្ពីរ។ ហើយដូច្នេះ… ហើយគ្រូគង្វាលរបស់យើងគឺលោក អ័រមេន នីវៀល នៅទីនេះ។ ហើយយើងមានក្រុមជំនុំទាំងមូលនៅទីនេះ—មនុស្សជាច្រើនបានប្រមូលផ្ដុំគ្នា នៅ ក្នុង រោងឧបោ សថ អន្តរនិកាយជាកន្លែងដែលយើងមកថ្វាយបង្គំព្រះជាម្ចាស់ដោយ យោងតាម មនសិការផ្ទាល់ខ្លួនរបស់យើង។ យើងតែងតែរីករាយពេលដែលមានអ្នក។ ហើយ ដូច្នេះ សូម អញ្ជើញចូលមកនៅពេល ដែលអ្នកអាចមកបានយើងតែងតែ រីករាយ ក្នុងការ ទទួលអ្នក។

7 ហើយឥឡូវពេលក្រោយទៀត ដរាបណាខ្ញុំដឹង គឺខ្ញុំនឹងនៅជាមួយអ្នក បន្ទាប់ពីក្រុមជំនុំត្រូវបានចប់សព្វគ្រប់។ ហើយខ្ញុំក៏ចង់ទៅដែរបន្ទាប់ពី *យុគសម័យក្រុមជំនុំ*ក៏មាន*សញ្ញា* ដៅសម្គាល់ប្រាំពីរហើយ *សញ្ញា* ដៅសម្គាល់ប្រាំពីរនោះនៅក្នុងកណ្ឌគម្ពីរវិវរណៈបានបង្រៀន។

8 ហើយឥឡូវមានពេលជាច្រើនដែលជម្ងឺ និងភាពម៉ួរម៉ៅមកដល់ និងកំឡុងពេលនៃប្រជុំទាំងនេះ ដែលតំរូវឲ្យមាននិមិត្តជាច្រើន និងមកចូលរួម សំរាប់ការសំភាសន៍ពិសេស។ ប្រសិនជាខ្ញុំចូលទៅក្នុងស្ថានភាពនោះហើយខ្ញុំ—ខ្ញុំនឹងមិនអាចបែងចែកពីភាពខុសប្លែកគ្នានោះ ទេ ហើយ វាគឺមានការពិបាកសម្រាប់ខ្ញុំនៅក្នុងការដែលនិយាយចេញបន្ទាប់ពីនោះ។ ហើយគ្រប់ គ្នា ដឹងថា នៅក្នុងយុទ្ធ នាការ នៃការប្រោសឱ្យជារបស់យើង ដែលលោក បាក់តឺ ឬ នរណា ម្នាក់ដែល ជា

ធម្មតា ធ្វើការអធិប្បាយ ហើយខ្ញុំចេញទៅអធិស្ឋាន សំរាប់អ្នក មានជម្ងឺ ពីព្រោះ វាគឺ គ្រាន់តែប្រើកម្លាំងច្រើនបន្តិច។ ហើយខ្ញុំបាន អធិស្ឋានសម្រាប់ មនុស្ស មួយ ចំនួន កាលពីប៉ុន្មាននាទីមុន ហើយខ្ញុំបានជួបក្មេងតូចម្នាក់ដែលគ្រូពេទ្យ...ថាមាន អ្វី មួយ ខុសប្រក្រតីនៅខ្នងរបស់គេពីកំណើតមក។ ចេញមក ខ្ញុំបាន ឃើញ វានៅ ទីនោះ អង្គុយសម្លឹង។ ក្មេងនោះនឹងមិនពិការដូច្នេះវានឹងធូរស្បើយ ឡើង វិញ ជា មិន ខាន។ ប្រាកដណាស់ឃើញទេ។ ខ្ញុំដឹងច្បាស់ណាស់។ ឃើញថា ខ្ញុំមាន ភាព វិជ្ជមាន ចំពោះ កិច្ចការនោះ។ ដូច្នេះយើងចង់មានជំនឿនិងជឿនៅក្នុង ព្រះជាម្ចាស់ របស់យើង។

9 យើងម្នាក់ៗ ហើយអ្នករាល់គ្នាភាគច្រើនជាមនុស្សដែលខ្ញុំមិនធ្លាប់ស្គាល់ ដូច ជា អ្នកបំរើព័ន្ធកិច្ចជាដើម។ ប្រសិនជាខ្ញុំមិនច្រឡំទេ នេះគឺជាប្អូនប្រុស ខ្រេស៍។ តើត្រឹមត្រូវទេ? ប្អូនប្រុស ខ្រេស៍ ខ្ញុំ—ខ្ញុំបានជំពាក់អ្នកពីការសុំអភ័យទោសមួយ ចំពោះការដែលមិនបានចូលរួមនៅក្នុងការឧទ្ទិសថ្វាយ។ ប្រហែលជាខ្ញុំត្រូវទៅទី នោះ សំរាប់កិច្ចប្រជុំនៅចុងសប្តាហ៍ ជាការល្អដែរ។ តើវាត្រឹម ត្រូវទេ? ចំណែកនៅ ប្លូមមីងតុន។ តើអ្នកសុខសប្បាយជាទេ? ល្អ។ បងប្អូនមួយចំនួននៅទីនេះជា អ្នក បំរើក្នុងព័ន្ធកិច្ច នេះគ្រាន់តែជាការសន្មតរបស់ខ្ញុំ។ តើអ្នកគឺជាអ្នកបំរើក្នុង ព័ន្ធ កិច្ច មែនទេ? បាទលោក។ សូមឲ្យព្រះជាម្ចាស់ប្រទានពរអ្នក។ ចុះតើមានអ្នកបំរើ ព័ន្ធ កិច្ចប៉ុន្មានអ្នកនៅក្នុងអាគារនេះសុំមើលដៃរបស់អ្នក។ មិនជាថ្វីទេ។ យើងមានចិត្ត រីករាយដែលមានវត្តមានអ្នកទាំងអស់គ្នានៅទីនេះ ព្រមទាំងមាន អំណរ ជា ខ្លាំង។ សូម ព្រះជាម្ចាស់ប្រទានពរអ្នក!

10 ឥឡូវយើងត្រូវក្រោកឡើង ពីព្រលឹមអ្នកខ្លះត្រូវចាកចេញទៅរដ្ឋចចា ថេននី ស៊ីស ញ៉ូវយ៉ក និងតាមកន្លែងផ្សេងៗទៀតនាយប់នេះ ចាប់ផ្តើមពីយប់នេះ។ ឥឡូវ នេះចូរបើកបរដោយមានការប្រុងប្រយ័ត្ននៅតាមផ្លូវ។ ប្រសិនជាអ្នកមានការងោក ងុយហើយ មិនចង់ចូលសំរាកនៅ ផ្ទះសំណាក់ចូរអែបទៅចិញ្ចើមថ្នល់ ហើយគេង រហូតដល់អ្នក...នេះជាអ្វីដែលខ្ញុំធ្វើ។ ឃើញទេ គ្រាន់តែអែបទៅម្ខាង ហើយគេង។ កុំឲ្យសោះ កុំបើកបរពេលអ្នកងោកងុយ។ វាគឺជាអ្វីដែលមិនល្អ នោះ ទេ។ ហើយ ចងចាំថាមិនមែនតែអ្នកទេគឺអ្នកបើកពីក្រោយអ្នកក៏ត្រូវមើលដែរ។ ឃើញ ទេ? អ្នកដឹង ពីកន្លែងណាដែលអ្នកទៅ ហើយអ្នកមិនដឹងពីកន្លែងណាដែលគាត់ទៅ

នោះទេ ដូច្នេះ—ដូច្នេះ ហើយអ្នកត្រូវមើលម្នាក់នោះ។ ដើម្បីឲ្យប្រាកដច្បាស់ថាអ្នកបាន ត្រៀម ខ្លួនជានិច្ច ដើម្បីមានការប្រុងប្រយ័ត្ន។

11 ឥឡូវខ្ញុំរំពឹងថានឹងអានបទគម្ពីរនៅយប់នេះដោយស្វែងរកនៅក្នុង កណ្ឌគម្ពីរយ៉ូហាន។ ឥឡូវនេះ បទគម្ពីរមួយចំនួនតូចដែលខ្ញុំបានអាន និង លើកមក គឺដើម្បីផ្តល់ឲ្យយើងនូវមូលដ្ឋានគ្រឹះនូវអ្វីដែលយើងចង់និយាយ។ ហើយស្ទើរតែរាល់ពេលគ្មានម្តងណាដែលចងចាំទេពេលបានចូលមកឈរនៅតុអធិប្បាយ ដើម្បីព្យាយាមនិយាយអ្វីដែលត្រូវនិយាយនោះ។ ខ្ញុំតែងតែរង់ចាំ មើលសិក្ខាអធិស្ឋានរហូត ដល់ខ្ញុំមានអារម្មណ៍ថាខ្ញុំមានអ្វីមួយដែលអាចជួយដល់មនុស្ស។ ប្រសិនជាខ្ញុំមិន អាចជួយបាននោះមិនចាំបាច់ឲ្យខ្ញុំមានវត្តមានឈរនៅទីនេះទេ។ ពិតជាព្យាយាមជួយ! ហើយឥឡូវយប់នេះមានមនុស្សជាច្រើនបានដូរចេញចាប់តាំង ពី ព្រឹកមិញ ហើយពួកគេជាច្រើនត្រូវត្រឡប់ទៅផ្ទះ។ ប៉ុន្តែយប់នេះខ្ញុំប្រាប់អ្នកប្រសិនជាអ្នកនៅ នោះយើងនឹងព្យាយាមយកពេលត្រឹមតែសែសិបប្រាំនាទី និយាយពីអ្វីមួយ ដែលខ្ញុំសង្ឃឹម ថានឹងអាចជួយដល់ពួកយើង។ ហើយយើងនឹងផ្អែកលើយ៉ូហាន ជំពូកដប់ប្រាំមួយ ហើយចូរចាប់ផ្តើមពីខទី៧ នៃជំពូកទី១៦ និងអានដល់ចប់—ខទី១៥។

*ខ្ញុំប្រាប់តាមត្រង់ថា ដែលខ្ញុំទៅ នោះមានប្រយោជន៍ដល់អ្នករាល់គ្នាវិញៈ ដ្បិតបើខ្ញុំមិនទៅទេ នោះព្រះដ៏ជាជំនួយក៏មិនមកឯអ្នករាល់គ្នាដែរ។ តែបើខ្ញុំទៅ នោះខ្ញុំនឹងចាត់ទ្រង់ឲ្យមក។*

*កាលណាទ្រង់ បានយាងមកហើយ នោះទ្រង់នឹងសំដែងឲ្យមនុស្សលោកដឹងច្បាស់ពីអំពើបាប* ពីសេចក្តីសុចរិត* ហើយពីសេចក្តីជំនុំជំរះៈ*

*គឺពីអំពើបាប ដោយព្រោះគេមិនជឿដល់ខ្ញុំ ពីសេចក្តីសុចរិតដោយព្រោះខ្ញុំទៅឯព្រះវបិតាខ្ញុំ ហើយអ្នករាល់គ្នាមិនឃើញខ្ញុំទៀតទេ*

*នឹងពី សេចក្តីជំនុំជំរះ ដោយព្រោះ ចៅហ្វាយ របស់ លោកីយ នេះ ត្រូវទោសហើយ។*

*ខ្ញុំនៅមានសេចក្តីជាច្រើន ទៀតនឹងប្រាប់អ្នករាល់គ្នា តែឥឡូវនេះអ្នករាល់គ្នាពុំអាចនឹងទទួលបានទេ។*

*កាលណាព្រះអង្គនោះគឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំ អ្នក រាល់ គ្នា ចូលក្នុងគ្រប់ទាំងសេចក្តី ពិតៈ ដ្បិត ទ្រង់*

*នឹង មានបន្ទូលមិនមែនដោយអាងព្រះអង្គទ្រង់ ទេ គឺនឹងមានបន្ទូលតែសេចក្តីណាដែលទ្រង់ឮ ហើយនឹងសំដែងឲ្យអ្នករាល់ គ្នាដឹងការដែលត្រូវមក។*

*ទ្រង់នឹងដំកើងខ្ញុំដ្បិតទ្រង់នឹងយកសេចក្តីដែលតំរូវពីខ្ញុំ មកប្រាប់ ដល់អ្នករាល់គ្នា។*

*គ្រប់ទាំងអស់ដែលព្រះវរបិតាមាន នោះជារបស់ផង—ខ្ញុំដែរ ហេតុនោះបានជាខ្ញុំប្រាប់ថាទ្រង់នឹងយកសេចក្តីដែលតំរូវពីខ្ញុំមកប្រាប់អ្នករាល់គ្នា។*

12 ឥឡូវ នៅក្នុងខទី ១៣ "កាល ណាព្រះវិញ្ញាណនៃសេចក្តីពិត យាងមកដល់ព្រះអង្គ នឹង ណែនាំ អ្នករាល់ គ្នា អោយ ស្គាល់ សេចក្តី ពិត គ្រប់ ចំពូក។ ពេលដែល ព្រះ វិញ្ញាណនៃ សេចក្តីពិតយាងមកដល់ ព្រះអង្គនឹងណែនាំ អ្នករាល់គ្នាអោយស្គាល់ សេចក្តី ពិត គ្រប់ ចំពូក។" តើអ្វីទៅគឺជាសេចក្តីពិត? ព្រះបន្ទូល។ "ដ្បិតសេចក្តីផ្សេងៗ ដែលព្រះអង្គថ្លែង មិនចេញមកពីព្រះអង្គផ្ទាល់ទេ គឺព្រះអង្គថ្លែងតែសេចក្តីណាដែលទ្រង់ព្រះសណ្តាប់ឮ ព្រមទាំងមានព្រះបន្ទូល។" និយាយបានថាព្រះអង្គ គឺជាម្នាក់ដែលបើកសម្តែងឲ្យអ្នកឃើញ។ ហើយនៅជំពូក៤ នៅក្នុងកណ្ឌគម្ពីរ ហេព្រើរព្រះគម្ពីរបានចែងថា "ដ្បិតព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាព្រះ បន្ទូលដ៏មានជីវិត និងមានមហិទ្ធិឫទ្ធិមុតជាងដាវមុខពីរទៅទៀត គឺ—គឺ ព្រះ បន្ទូលនេះចាក់ទម្លុះចូលទៅកាត់ព្រលឹង និងវិញ្ញាណដាច់ចេញពីគ្នា កាត់សន្លាក់ឆ្អឹង និងខួរឆ្អឹងចេញពីគ្នា។" មើល "អ្វីដែលទ្រង់ឮ ទ្រង់ថ្លែងប្រាប់និងសំដែងអោយអ្នករាល់គ្នាដឹង ការដែលត្រូវមក។" ឃើញទេ? តើទ្រង់នឹងធ្វើអ្វី? ព្រះវិញ្ញាណបរិសុទ្ធដែលនឹងយាងមកនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

13 ហើយខ្ញុំចង់ឆ្លៀតពេលពីរបីនាទីដើម្បីទាញយក ចំណាប់អារម្មណ៍របស់អ្នកនៅលើពាក្យថា "ណែនាំ" *អ្នកមគ្គុទេសក៍*។ អ្នកដឹងទេ ខ្ញុំធ្លាប់មានបទពិសោធន៍ជាច្រើននៅក្នុងព្រៃឈើ។ អ្នកនាំ គឺអ្នកណាម្នាក់ដែលបង្ហាញអ្នកមើលអ្វីជុំវិញ។ អ្នកត្រូវតែមានអ្នកនាំផ្លូវនៅពេលដែលអ្នកមិនដឹងជាទៅទីណា។ ហើយស្គាល់ការ ប្រមាញ់និងពិភពជុំវិញខ្ញុំមាន—មានឱកាសជួបជាមួយអ្នកនាំផ្លូវជាច្រើន។

នៅក្នុង រដ្ឋខូឡូរ៉ាដូខ្ញុំជាអ្នកនាំផ្លូវដោយខ្លួនឯងពីព្រោះស្គាល់តំបន់នោះច្បាស់ ដូចជាកន្លែង កសិដ្ឋានជាដើម ខ្ញុំអាចនាំបាននៅក្នុង រដ្ឋខូឡូរ៉ាដូ។

14 ឥឡូវអ្នកនាំផ្លូវត្រូវតែស្គាល់ផ្លូវ។ គាត់ត្រូវតែដឹងកន្លែងណា ដែលគាត់ត្រូវទៅ និងអ្វីដែលគាត់ត្រូវធ្វើ ហើយដឹងពីរបៀបថែទាំអ្នកនៅតាមផ្លូវ។ ឃើញទេ? គាត់ត្រូវតែមើលដឹងថាមិននាំអ្នកឲ្យវង្វេង។ អ្នកនាំផ្លូវជាអ្នកដែលបានជ្រើសរើស។ រដ្ឋ និងជ្រើសរើសគេបើគេជាអ្នកនាំផ្លូវ។ហើយឥឡូវខណៈពេលដែលបន្តការធ្វើដំណើរនៅក្នុងទីរហោស្ថានប្រហែលជាកន្លែងដែលអ្នកមិនធ្លាប់ធ្វើដំណើរទៅ វាគឺមិនមែន ជាការល្អសំរាប់អ្នកទេបើគ្មានអ្នកនាំផ្លូវទៅជាមួយ។ និយាយតាមត្រង់ទៅ ទីកន្លែង ខ្លះអ្នកស្ទើរតែមិនអាចទៅ ដោយគ្មានអ្នកផ្សេងទៅជាមួយឧទាហរណ៍ ប្រទេស កាណាដា។ អ្នក—អ្នកមគ្គុទេសក៏នោះ ត្រូវចុះហត្ថលេខាលើប័ណ្ណសម្គាល់របស់ អ្នកទទួលស្គាល់ដោយម្ចាស់តំបន់។ គាត់ត្រូវចុះហត្ថលេខាពីលើនោះដែរហើយ គាត់ជាអ្នកទទួលខុសត្រូវសម្រាប់អ្នក។ ប្រសិនជាមានអ្វីកើតឡើងចំពោះអ្នកវាគឺ ជាការទទួលខុសត្រូវសម្រាប់គាត់។ គាត់ត្រូវតែយកចិត្តទុកដាក់លើអ្នក។ គាត់ត្រូវ មើល អ្នកមិនឲ្យវង្វេង។ គាត់ត្រូវធានាឲ្យបានដោយមិនបញ្ជូនអ្នកទៅកន្លែងដែលអ្នកមិនស្គាល់ផ្លូវត្រឡប់មកវិញ។ ហើយប្រសិនជាអ្នកវង្វេង ផ្លូវគាត់ត្រូវតែ ស្គាល់ តំបន់នោះច្បាស់ ដើម្បីគាត់អាចទៅយកអ្នកបានគ្រប់ពេល។ គាត់ត្រូវតែ ដឹង ពីកិច្ច ការទាំងនោះបើមិនដូច្នេះទេគាត់មិនអាចធ្វើជាអ្នកមគ្គុទេសបានទេ។ហើយគាត់ មិនអាច ទទួល អាជ្ញាប័ណ្ណ ជាអ្នកមគ្គុទេសក៏បានទេ។

15 សម្រាប់អ្វីទាំងអស់នេះ ពេលខ្លះអ្នកត្រូវតែមានការណាត់ជួប ដោយទំនាក់ទំនងតាមទូរស័ព្ទជាមុន ហើយធ្វើការរៀបចំ ដោយបំរុងទុកជាមុននូវអ្វីដែលត្រូវការ ហើយប្រសិនជាឥវ៉ាន់របស់អ្នក...ពេលខ្លះពេញពេកមិនអាចយកឲ្យអ្នកបាន អ្នកត្រូវតែទុកវាចោលមួយឡែកសិន នេះអ្នកមគ្គុទេសក៏នៅលើផែនដី។ តែអ្នកមិនចាំបាច់ធ្វើដូច្នេះទេជាមួយនឹងការណែនាំរបស់ព្រះជាម្ចាស់ ព្រះអង្គតែងតែ ត្រៀមរួចរាល់ជាស្រេច។

16 ឥឡូវ ប្រសិនជាអ្នកមិនយល់ពីការរៀបចំទាំងនេះ ហើយអ្នកស្វែងយល់ពី ការធ្វើដំណើរទៅកាន់ទីរហោស្ថាន ដែលអ្នកមិនធ្លាប់ទៅពីមុនមក អ្នកនឹងវង្វេង និងស្លាប់។ អ្នកអាចមាន ឱកាសត្រឹមតែមួយភាគរយ នៅក្នុងការឆ្លងផុតទីវាលរហោស្ថាននោះប្រសិនជាវាមិនធំល្វល្វេវ ពេកអ្នកអាចមានឱកាសមួយភាគរយ អាច

រួចខ្លួនផុតពីទីនោះ។ប៉ុន្តែបើវាជាវាលរហោស្ថានដ៏អាក្រក់អ្នកមិនមានឱកាសនឹងចេញមកវិញទេ។ វាគ្មានផ្លូវនោះទេដែលធ្វើអញ្ចឹង ពីព្រោះអ្នកនឹង ឃើញ ខ្លួន ឯងដើរទៅរកសេចក្ដីស្លាប់ ហើយបន្ទាប់—បន្ទាប់មកទៀតជីវិតអ្នក ត្រូវចប់។ ឥឡូវហើយអ្នកនឹងត្រូវស្លាប់ ប្រសិនជាអ្នកមិនមានអ្នកនាំផ្លូវដែលស្គាល់ ប្រទេស នោះហើយស្គាល់ផ្លូវត្រឡប់មកវិញ។

17 អ្នករាល់គ្នាជាច្រើន បានស្គាល់ពីប្រធានបទដែលអ្នកអានកាលពីឆ្នាំមុន នៅឯតាក់សុន អារីសូណា គឺបុរសដែលហាត់ទាហាន ទាំងនោះ។ ពួកគេត្រូវ បានបង្ខឹកឲ្យចេះមើលថែទាំខ្លួនឯង ពួកគេជាអ្នកហាត់ទាហ៊ាន។ ហើយពួកគេមិនត្រឹមតែជា ទាហ៊ានអង្កេត ប៉ុណ្ណោះទេ តែជាក្រុមហាត់ពេញលេញ។ ហើយពួកគេមានការធ្វើដំណើរទៅតាម ភ្នំ ហើយមានព្យុះព្រិលមក ដោយបំរែបំរួលអាកាសធាតុធ្វើឲ្យមានការដូរទិសដៅ។ ហើយនៅពេលដែលពួកគេដឹងថាកំពុងតែវង្វេង និងពួកគេបានស្លាប់ គឺពីព្រោះ តែពួកគេ...ពេលខ្លះការប្រែប្រួលផ្សេងៗបានចូល មកខុសពីភាពប្រក្រតីពួកគេមិនដឹងថានឹងរកផ្លូវចេញដោយរបៀប ណា។ ឃើញទេ? ហើយខ្ញុំភ្លេចថាមានក្មេងប្រុសប៉ុន្មានអ្នកបានស្លាប់នៅលើភ្នំនោះ ទោះ បីជាពួក គេមានឧទ្ធម្ភាគចក្រ និងកងជីវពល និងក្រុមការពារជាតិ អ្នកស្ម័គ្រ ចិត្តជួយ ហើយមានសព្វគ្រប់ក៏ដោយ។ ប៉ុន្តែពួកគេបានបាត់ខ្លួន គ្មានអ្នក ណាម្នាក់ ដឹង ថាពួកគេនៅទីណានោះឡើយ។ ហើយពួកគេមិនអាចមើលថែទាំខ្លួន ឯង។ ពួកគេ ទាំង អស់បានស្លាប់នៅក្នុងព្រិល ពីព្រោះតែពួកគេមិនមានអ្វីបរិភោគ មិនដឹងទិស កើត លិច ជើង ត្បូង លើក្រោមគឺគ្រប់យ៉ាងមើលទៅដូចគ្នាទាំងអស់។

18 ឥឡូវអ្នកនាំផ្លូវដឹងថាគាត់កំពុងតែនៅកន្លែងណា ទោះជាអាកាសធាតុយ៉ាងណាក៏ដោយ។គឺគាត់—គាត់មានភាពស៊ាំថ្នឹកនៅក្នុងការធ្វើកិច្ចការនោះ។ គាត់ដឹងថា គាត់ កំពុងតែធ្វើអ្វី គាត់ស្គាល់ទិសតំបន់ទាំងអស់។ គាត់ស្គាល់គ្រប់សណ្ឋានរបស់ទាំងអស់ ដូច្នេះហើយទោះជាគាត់ស្ថិតនៅក្នុងភាពងងឹតក៏គាត់អាចដឹង នូវអ្វីគ្រប់យ៉ាង។

19 ឧទាហរណ៍ នេះគឺជាវិធីចាស់គំរិលមួយចំពោះការនាំផ្លូវ។ អ្នកដឹងទេ បើសិនជាអ្នកអាចមើលឃើញហ្វូងផ្កាយនោះគេអាចប្រាប់បានថាផ្លូវណាដែលអ្នកកំពុងតែធ្វើដំណើរទៅ បើអ្នកមើលតាមផ្កាយនោះ។ ហើយ អ្នកនឹងចង់មើលផ្កាយ

ដែល នាំ ផ្លូវនោះជានិច្ច។ គឺមានតែផ្កាយដែលពិតប្រាកដតែមួយគត់ ហើយដែលជា ផ្កាយទិសខាងជើង។ ឃើញទេ គឺមានតែមួយ ហើយគឺឈរនៅកន្លែងដដែល។ ដែលតំណាងឲ្យព្រះគ្រីស្ទ ព្រះអង្គមិនប្រែប្រួលឡើយ ពីដើម សព្វថ្ងៃ និងរហូតដល់អស់កល្បជានិច្ច។ អ្នកខ្លះទៀតអាចរសាយបាត់ ប៉ុន្តែព្រះអង្គគឺនៅដដែល។ ក្រុមជំនុំខ្លះអាចទាញអ្នកទៅតាមផ្លូវនេះ ឬក៏អ្នកខ្លះទាញអ្នកទៅតាមផ្លូវ*នោះ* ប៉ុន្តែមិនមែនព្រះអង្គទេ គឺព្រះអង្គតែងតែដូចដើមជានិច្ច។

20 ល្អ ឥឡូវប្រសិនជាអ្នកមិនអាចមើលឃើញផ្កាយទិសខាងជើងនេះ ក៏ដោយហើយពេញទៅដោយពពកបាំងជិត ហើយទោះបីជាអ្នកនឹងធ្វើការកត់ សម្គាល់បើទោះជាពេលថ្ងៃ ហើយអ្នកវង្វេងផ្លូវ ប្រសិនជាអ្នកគ្រាន់តែមើលទៅដើម ឈើ។ នោះអ្នកនឹងឃើញថាផ្នែកដែលមានដុះស្លែជាទិសខាងជើងរបស់ដើមឈើ នោះហើយ ពីព្រោះផ្នែកខាងត្បូងនៃដើមឈើទទួលបានពន្លឺថ្ងៃច្រើនជាងផ្នែក ខាងជើង។ ប៉ុន្តែចុះប្រសិនជាងងឹតហើយអ្នកមិនអាចមើលឃើញស្លែនោះវិញ? ប្រសិនជាអ្នកនឹងបិទភ្នែករបស់អ្នក ហើយដោយមិនចាំបាច់ព្យាយាមគិតអ្វីទាំង អស់ បិទភ្នែករបស់អ្នក ហើយយកសំបកឈើដែលរលោង ដាក់ដៃរបស់អ្នកជុំវិញ ដើមឈើរហូតដល់ម្រាមដៃរបស់អ្នកប៉ះគ្នា ហើយបន្ទាប់មកចាប់ផ្ដើមបង្វិលជុំវិញ ដើមឈើនោះតិចៗ។ ហើយនៅពេលដែលអ្នកប៉ះកន្លែងដែលមានសំបកឈើ ក្រាស់ ខ្លាំងនោះហើយជាទិសខាងជើង (ដែលត្រូវខ្យល់) ហើយអ្នកអាចប្រាប់បាន ថា អ្នកកំពុងតែនៅទិសជាងជើង ឬខាងត្បូង។ នេះជារបៀបមួយ អូ ហើយនៅមាន ច្រើនទៀត ប៉ុន្តែត្រូវតែមានការណែនាំដើម្បីឲ្យដឹងពីរបៀបដែលត្រូវធ្វើ។ មានតែ មនុស្សសាមញ្ញម្នាក់ក្រោកឡើងនៅទីនោះ ហើយនិយាយថា "ខ្ញុំមិនមានអារម្មណ៍ ថាវា មាន អ្វីខុសប្លែកគ្នាទាល់តែសោះ។" ឃើញទេ? ឃើញទេអ្នកត្រូវបានទទួល ការហ្វឹក ហាត់សំរាប់ការនាំផ្លូវ។

21 ហើយក្មេងប្រុសទាំងនេះ មិនបាច់ឆ្ងល់ទេ ប៉ុន្តែពួកគេជាទាហ៊ានដ៏ល្អ ដូច្នេះពួកគេអាចចងចំណង អាចបង្កាត់ភ្លើងជាមួយនឹងដុំថ្ម ជាដើម។ ប៉ុន្តែ ដើម្បីឲ្យដឹងផ្លូវចេញ នោះជាអ្វីត្រូវគិត! ពួកគេ ពួកគេអត់ស្គាល់ផ្លូវ ចេញរបស់ពួកគេទេ ដូច្នេះហើយទើបពួកគេទាំងអស់ត្រូវវិនាស ដោយសារតែពួកគេ មិនបាននាំអ្នកនាំផ្លូវទៅជាមួយ ។

22 ឪពុកដែលមិនចេះគិតម្នាក់ កាលពីពីរឆ្នាំមុន នៅក្នុងរដ្ឋកូឡូរ៉ាដូ អូ ពេលនោះគាត់បានឡើងទៅលើភ្នំ គាត់មានកូនប្រុសម្នាក់អាយុប្រហែលប្រាំមួយ ទៅប្រាំពីរឆ្នាំ។ គាត់បាននាំក្មេងនោះទៅបរបាញ់ សត្វក្តាន់ជាលើកទីមួយជាមួយគាត់។ ហើយ ពួកគេបានឡើងទៅលើកំពូលភ្នំហើយក្មេងប្រុសតូចនោះបាន និយាយទៅកាន់ឪពុករបស់គាត់ថា "ខ្ញុំអស់កម្លាំងខ្លាំងណាស់។"

23 "ឡើងលើខ្នងប៉ាមក។ យើងអត់ទាន់បានឡើងដល់ដល់កំពូលខ្ពស់ល្មមនៅឡើយទេ សត្វក្តាន់វានៅកន្លែងខ្ពស់ៗ។" បន្តឡើងទៅរហូតដល់កន្លែងដែល គាត់ពេញចិត្ត...គាត់អត់បានដឹងទេ គាត់ជាអ្នកទីក្រុងម្នាក់។ គាត់មិនដឹងអ្វីទាំងអស់ពីការបរបាញ់ឬ ត្រូវទៅកន្លែងណានោះឡើយ។ អ្នកដែលដឹងអំពីទីវាលរហោស្ថានទើបដឹងថាសត្វក្តាន់គឺវាមិនរស់នៅកន្លែងខ្ពស់បែបនោះទេ។ គឺពួកវាមិនឡើងទៅដល់ទីនោះឡើយ។ មានតែសត្វពពែដែលនៅទីនោះ មិនមែនសត្វក្តាន់ទេ។ ពួកវានៅខាងក្រោមកន្លែងដែលមានអាហារពួកវាត្រូវតែ នៅកន្លែងណាដែលអាចរកចំណីបាន។ ហើយ ដូច្នេះ តែបុរសម្នាក់នេះបានគិតថា "ប្រសិនជាខ្ញុំឡើងទៅដល់ជ្រលង ថ្មនៅ ខាងលើ ខ្ញុំនឹងអាចស្វែងរកសត្វធំៗបានហើយ។" គាត់ធ្លាប់ឃើញរូប ភាព ដាក់បញ្ឈរ—ដាក់បញ្ឈរលើផ្ទាំងថ្ម ហើយគាត់ក៏គិតថានឹងស្វែងរកសត្វក្តាន់នោះ។ កុំយកចិត្តទុកដាក់ទៅលើការអាននៅលើទស្សនាវដ្តី ខ្ញុំ អូ ខ្ញុំ អ្នកនឹងមានសុបិន្តអាក្រក់! ហើយថាអ្វីដែលត្រូវធ្វើ គឺនាំ អ្នកនាំផ្លូវម្នាក់ដើម្បីអ្នក ដឹងថាអ្នកកំពុងតែនៅកន្លែងណា។

24 ហើយឪពុកម្នាក់នោះ គឺមានភ្លៀងធ្លាក់ហើយនៅម៉្ញនោះ ហើយមានភ្លៀងយ៉ាងខ្លាំង។ ហើយបុរសនេះដើរប្រមាញ់យ៉ាងយូរ ដោយមេឃចាប់ផ្តើម ងងឹតហើយគាត់មិនអាចរកផ្លូវត្រឡប់មកវិញទេ។ ហើយ...ក៏មាន ខ្យល់បក់នៅលើកំពូល ភ្នំហើយគាត់រត់យ៉ាងលឿន ហើយនោះ...

25 អ្នកត្រូវតែដឹងពីរបៀបដើម្បីរួចជីវិត បើអ្នករបូតមួយ។ នឹងមានអ្វីមួយផ្សេងទៀត ចូលមក ត្រូវដឹងពីរបៀបដើម្បីរួចជីវិត! ខ្ញុំធ្លាប់បានឡើងដើមឈើនិងរអិលចុះហើយឡើងដើមឈើម្តងទៀតហើយរអិលចុះ ឡើយហើយចុះបែបនោះ ដើម្បីឲ្យរក្សាអាយុជីវិត។ ខ្ញុំបានយកព្រិលដាក់វាមានកំពស់បួនហ្វូត ទៅម្ខាង ទាញគល់ឈើហើយផ្តួលវាចុះ។ដោយហេវហត់យ៉ាងខ្លាំងធ្វើឲ្យខ្ញុំស្ទើរតែពុំអាចដាក់បញ្ឈរវាបាន! ហើយដាក់បញ្ឈរគល់ឈើចាស់នេះដុតវាឲ្យមានកំដៅ ហើយធ្វើឲ្យទឹកកក

វលោយ។ ហើយបន្ទាប់មកប្រហែលជាម៉ោងមួយព្រឹក ម៉ោងពីរ រមៀលគល់ឈើនោះនៅលើកន្លែងដែលមានកម្តៅ ដើម្បីរក្សាជីវិត។ ហើយអ្នកក៏ត្រូវចេះធ្វើ របៀបទាំងអស់នេះដែរ។

26 ហើយបុរសម្នាក់នេះ មិនបានដឹងថាគាត់បានធ្វើអ្វីនោះទេ គាត់គ្មានអ្នកណានៅជាមួយគាត់ ដើម្បីនឹងនាំផ្លូវដល់គាត់។ ហើយគាត់បានអោប កូនប្រុសរបស់គាត់ជាប់នឹងដើមទ្រូងរបស់គាត់រហូតដល់គាត់មានអារម្មណ៍ថា កូននោះត្រជាក់ហើយស្លាប់។ ដោយមិនមានការគិតពិចារណា! ប្រសិនជាគាត់បាន យកអ្នកនាំផ្លូវមកជាមួយគាត់ នោះអ្នកនាំផ្លូវនោះនឹងអាចនាំគាត់ចុះពីលើភ្នំដោយ មិនបាច់គិតដល់ពីពេលវេលា។ ប៉ុន្តែគាត់បានចាំរហូតដល់មេឃងងឹត ហើយគាត់ មិនអាចមើលឃើញផ្លូវនៅជុំវិញគាត់បាន។

27 នោះក៏ជា បញ្ហាជាមួយនឹងគ្រីស្ទាន នាពេលបច្ចុប្បន្ននេះ។ ពួកគេរង់ចាំរហូតដល់ភាពងងឹតកន្លងផុតទៅ បន្ទាប់មកទើបដឹងថាខ្លួនថា រូបគេត្រូវបោះបង់ ចោលដោយគ្មានអ្នកនាំផ្លូវ។ អ្នកនាំផ្លូវ!

28 មូលហេតុអ្វី តើអ្នកធ្លាប់ឃើញមនុស្សដែលវង្វេងដែរឬទេ? តើមាននរណាធ្លាប់មានបទពិសោធន៍នាំមនុស្សដែលវង្វេងដែរឬទេ? ជាអ្វីដែលអ្នកនឹងមើលទៅគួរឲ្យអាណិតជាងគេ។ នៅពេលដែលមនុស្សម្នាក់វង្វេងគាត់ត្រឡប់ដូចជាមនុស្សចម្លែក គាត់មិនដឹងថាគាត់កំពុងធ្វើអ្វីនោះទេ។ យើងចាប់បានបុរសម្នាក់ ដែលជា ក្មេងប្រុសដែលវង្វេងនៅក្នុងព្រៃ...គាត់ធ្លាប់ជាអ្នកចិញ្ចឹមសត្វ ប៉ុន្តែគាត់បាននៅ ក្នុងទឹកដីដែលគាត់មិនស្គាល់ហើយក៏វង្វេងវង្វាន់។ ហើយបីថ្ងៃក្រោយ គេរកឃើញ គាត់ គាត់បានរត់ដូចជាមនុស្សព្រៃ ស្រែកអស់សម្លេងរបស់គាត់។ បបូរមាត់គាត់ ត្រូវបានខូច ហើយគាត់គ្រវែងកាំភ្លើងរបស់គាត់ចោល ហើយអត់ ដឹងថាត្រូវធ្វើអ្វី។ ហើយនៅ ពេលដែលជួបបងប្រុសរបស់គាត់ ពេលនោះ...គេត្រូវចាប់គាត់ចង។ ពេលដែលបងប្រុសគាត់ចូលមកជិតគាត់ គាត់បានវាយដូចជាសត្វ ដោយបាន ព្យាយាមខាំគាត់ គាត់អត់បានដឹងទេថាខ្លួនគាត់បានឆ្លងកាត់អ្វី។ មូលហេតុអ្វី? គាត់បាន វង្វេង។ ហើយនៅពេលគាត់វង្វេង គឺគាត់ស្ថិតក្នុងស្ថានភាពច្របូកច្របល់។ ហើយគាត់មិនដឹងថាគាត់កំពុងតែស្ថិតនៅក្នុងស្ថានភាពនោះទេពីព្រោះគាត់កំពុងតែវង្វេងស្មារតី ជំងឺនេះកំពុងតែគ្រប់គ្រងគាត់ ហើយគាត់មិនដឹង ថាខ្លួន

គាត់កំពុងតែ នៅទីណាទេ ហើយក៏មិនបានដឹងថាគាត់កំពុងបញ្ចេញសកម្មភាព បែបណានោះដែរ។

29 អញ្ចឹងចុះនៅពេលដែលមនុស្សម្នាក់វង្វេងចេញពីព្រះជាម្ចាស់! គាត់នឹង ធ្វើអ្វី ដែលជាធម្មតាគាត់មិនធ្លាប់ធ្វើពីមុនមក។ គាត់នឹងធ្វើអ្វីដែល—ដែលហួសពី ការ គិត របស់មនុស្សធម្មតាបានធ្វើ។ មនុស្សដែល វង្វេងចេញពីព្រះជាម្ចាស់ ព្រះវិហារ ដែល បែកចេញពីព្រះជាម្ចាស់ ព្រះវិហារដែលវង្វេងផ្លូវចេញពីព្រះជាម្ចាស់ ឃ្លាត ចេញ ពី ផ្លូវគោលលទ្ធិនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ នឹងធ្វើអ្វីមួយដែលពេលខ្លះ អ្នកមិន បានរំពឹងថាអ្នកនឹងឃើញនៅក្នុងព្រះវិហារនៃព្រះមានព្រះជន្មគង់នៅនោះ ទេ។ ពួកគេនឹងរកលុយតាមការលេងល្បែងដែលបោកបន្លំការលេងឆ្នោត ល្បែង ស៊ី សង នឹងអ្វីផ្សេងទៀតជាច្រើនដែលពួកគេអាចធ្វើបាន។ ពួកគេនឹងបង្រៀន ពី អ្វីគ្រប់ យ៉ាង អនុញ្ញាតិឲ្យគ្រប់យ៉ាង ចំពោះអ្នកដែលបានចំណាយច្រើនចូល ទៅ ក្នុង ព្រះវិហារ ហើយទង្វើរប្រហាក់ប្រហែលនោះជាដើមដើម្បីឲ្យពួកគេរួចខ្លួន ។ គឺ ត្រូវ ហើយ។ លើកគ្រូជំនួយជាក្រុមប្រឹក្សា ដែលធ្លាប់រៀបការបួនទៅប្រាំដងរួចមក ហើយ។ ដើម្បីឲ្យអាចរួចផុត គឺត្រូវធ្វើកិច្ចជួបជុំចុងក្រោយ។ ក៏មានទីបញ្ចប់តែមួយ ដែលអ្នក ត្រូវជួបប្រទះ នោះហើយគឺជាតួនាទីរបស់អ្នកចំពោះ ព្រះជា ម្ចាស់។ ចូរ ឈរហើយ ប្រាប់តាមការពិត! មនុស្សបាត់បង់គឺមនុស្ស ដែលស្ថិតនៅ ក្នុង ស្ថាន ភាពវង្វេងវង្វាន់ គាត់គឺជាមនុស្សវិកលចរិត។

30 អ្នកនាំផ្លូវ (មគ្គុទេសក៍) យល់ពីរបៀប និង អ្វីដែលត្រូវធ្វើ។ ព្រះជាម្ចាស់... ព្រះអង្គតែងតែបញ្ជូនមគ្គុទេសក៍មកឲ្យរាស្ត្ររបស់ព្រះអង្គ។ ព្រះជាម្ចាស់មិនដែល បោះបង់យើងចោលឡើយ។ ព្រះអង្គចាត់អ្នកណែនាំមក ប៉ុន្តែអ្នកក៏ត្រូវតែទទួល អ្នកណែនាំនោះដែរ។ ឃើញទេ? អ្នកត្រូវតែជឿ។ អ្នកត្រូវតែទៅតាមផ្លូវ ដែលអ្នក ណែនាំនោះប្រាប់ឲ្យទៅ។ ប្រសិនជាអ្នកស្ថិតនៅក្នុងទីរហោស្ថាន ហើយ អ្នកនាំផ្លូវ របស់អ្នកនិយាយថា "យើងទៅតាមផ្លូវ*នេះ*" ហើយអ្នកគិតថាទៅតាម ផ្លូវនោះវិញ នោះអ្នកនឹងវង្វេងផ្លូវមិនខាន។ ហើយនៅពេលដែល...ព្រះជាម្ចាស់ ចាត់ឲ្យ មាន អ្នកនាំផ្លូវដើម្បីណែនាំយើង យើងត្រូវតែតាមអ្នកដែលនាំនោះ។ ទោះជាយើង គិត អ្វីក៏ដោយ ទោះជាវាមើលទៅសមហេតុផលប៉ុណ្ណាក៏ដោយ ហើយទោះជាមើលទៅ ពុំសមហេតុផលក៏ដោយ យើងមិនមានមានតួនាទីនៅក្នុង ការបែងចែកនោះទេ គឺ មានតែអ្នកនាំផ្លូវតែម្នាក់គត់ជាអ្នកធ្វើ។

31 ព្រះជាម្ចាស់នៅក្នុងសម្ព័ន្ធមេត្រីចាស់បានបញ្ជូនព្យាការីជាច្រើនមក។ ពួកគេជាអ្នក នាំផ្លូវ ពីព្រោះព្រះបន្ទូលរបស់ព្រះជាម្ចាស់បានប្រទានមកព្យាការី។ ពួកគេគឺ ជាអ្នក នាំផ្លូវ។ ពួកគេបានធ្វើការណែនាំទៅដល់មនុស្ស ដូចជាអ្វីដែលពួកយើងបានធ្វើ កាលពីយប់មិញ របស់ព្យាការីអេសាយ និង ស្ដេចអូសៀស។ ពួកគេបាន ទទួលការណែនាំនិងបានណែនាំទៅដល់មនុស្ស ហើយជាអ្នកនាំផ្លូវ ដល់ពួកគេ។ ហើយឥឡូវព្រះជាម្ចាស់តែងតែចាត់ឲ្យមានអ្នកនាំផ្លូវរបស់ព្រះអង្គ ព្រះអង្គមិនដែលគ្មានការណែនាំនោះឡើយ គ្រប់ទាំងសម័យកាល។ ព្រះជាម្ចាស់ តែងតែមាននរណាម្នាក់ធ្វើជាអ្នកតំណាងឲ្យព្រះអង្គ នៅលើផែនដីនេះ នៅគ្រប់ ជំនាន់។

32 ឥឡូវពេលខ្លះពួកគេបានបែរចេញពីអ្នកនាំផ្លូវ "បែចេញខុស" ជាអ្វីដែលយើងហៅ។ នៅពេលដែលព្រះយេស៊ូវមានវត្តមានគង់នៅលើផែនដី តើអ្នកមានចាំបានទេពីព្រះបន្ទូលដែលព្រះអង្គមានបន្ទូលទៅកាន់ គណៈផារីស៊ី "អ្នកជាអ្នកនាំផ្លូវដែល ខ្វាក់"? អ្នកនាំផ្លូវខ្វាក់ ខ្វាក់ផ្នែកព្រលឹងវិញ្ញាណ។ ឃើញទេ? ឥឡូវគេ គួរតែជា អ្នកដែលនាំផ្លូវដល់មនុស្ស នាំផ្លូវមនុស្សទៅកាន់សេចក្ដីសង្គ្រោះ។ ប៉ុន្តែព្រះយេស៊ូវមានបន្ទូលថា "អ្នកនាំផ្លូវខ្វាក់!" ហើយព្រះអង្គមានព្រះបន្ទូល"កុំអំពល់នឹងគេធ្វើអ្វី អ្នកទាំងនោះសុទ្ធតែជាមនុស្សខ្វាក់ ដឹកនាំមនុស្សខ្វាក់។ បើមនុស្សខ្វាក់ដឹក ដៃមនុស្សខ្វាក់ គេមុខជាធ្លាក់រណ្ដៅទាំងពីរនាក់មិនខាន?" មនុស្សខ្វាក់នាំផ្លូវ! អូ តើពាក្យនោះបាន ធ្វើឲ្យសៅហ្មងយ៉ាងណាទៅ ការនាំផ្លូវ ដោយ ងងឹតងងុល។ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យអ្នកពឹងផ្អែក លើការយល់ដឹង ផ្ទាល់ ខ្លួនឡើយ។ ព្រះជាម្ចាស់មិនសព្វព្រះហរឫទ័យឲ្យអ្នកពឹងផ្អែក លើការយល់ ដឹងផ្ទាល់ខ្លួន ឬគំនិតយោបល់របស់អ្នកឡើយ ឬ គំនិតដែលបង្កើតឡើងដោយនរណា ម្នាក់នោះដែរ។

33 ព្រះជាម្ចាស់ចាត់អ្នកនាំផ្លូវ ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យអ្នកបានចងចាំថា នោះគឺជាអ្នកនាំផ្លូវ ដែលព្រះអង្គចាត់តាំង។ ហើយយើងគួរតែចងចាំអំពីព្រះអង្គ។ នៅទីនេះព្រះយេស៊ូវមានព្រះបន្ទូល "ខ្ញុំនឹងមិនចាកចោលអ្នក ប៉ុន្តែខ្ញុំនឹងអធិស្ឋានទៅកាន់ ព្រះវរបិតា ហើយព្រះអង្គនឹងចាត់ឲ្យមានព្រះដែលជួយកំសាន្តចិត្តឲ្យមក។" ហើយអ្នកកំសាន្តចិត្តនេះ ពេលដែលចាត់ឲ្យមក ជាអ្នកដែលនឹងនាំ យើងបានស្គាល់ សេចក្ដីពិតគ្រប់យ៉ាង។ ហើយព្រះបន្ទូលរបស់ព្រះជាម្ចាស់គឺជាសេចក្ដីពិតហើយព្រះបន្ទូលគឺជាព្រះគ្រីស្ទ "ខ្ញុំជាផ្លូវ ជាសេចក្ដីពិតហើយ ជា

ជីវិត។៉ ព្រះអង្គ គឺជាព្រះបន្ទូល។ ៉កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្ម គង់នៅ។ ព្រះបន្ទូលគង់នៅជាមួយព្រះជាម្ចាស់ ហើយព្រះបន្ទូលជាព្រះជាម្ចាស់។ ហើយ ព្រះបន្ទូលត្រឡប់មកជារូបកាយហើយគង់នៅក្នុងចំណោមយើង។៉ បន្ទាប់មក ប្រសិន ជាយើងដើរតាមអ្នកនាំផ្លូវដ៏ពិតប្រាកដ ព្រះវិញ្ញាណបរិសុទ្ធ នឹងប្រាប់យើងនូវ សេចក្តីដែលព្រះអង្គបានឃើញ សេចក្តីដែលព្រះអង្គបានឮ ហើយ ព្រះអង្គនឹងបង្ហាញពីសេចក្តីដែលនឹងមកដល់ខាងមុខ។ អាម៉ែន។ អញ្ចឹង ព្រះអង្គ នឹងបង្ហាញ ពីកិច្ចការដែលនឹងត្រូវមកដល់។

34 ហើយនៅពេល ដែលក្រុមជំនុំ បច្ចុប្បន្នបដិសេធនោះ តើយើងនឹងរំពឹងពីការទៅស្ថានសួគ៌ដោយរបៀបណា? នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានចាត់មកដើម្បីនឹងណែនាំដល់យើង យើងត្រូវការមានអ្នកទូលអង្វរជំនួសផង បូជាចារ្យផង ជាអ្នកមើលការខុសត្រូវផង ឬអ្នកដែលណែនាំដល់យើង ព្រះវិញ្ញាណបរិសុទ្ធត្រូវបានចាត់ឲ្យមកដើម្បីនឹងណែនាំដល់យើង។

35 ហើយព្រះវិញ្ញាណបរិសុទ្ធ តែងតែមានបន្ទូលចេញពីព្រះបន្ទូល។ ៉ខ្ញុំមានសេចក្តី ជាច្រើនដែលត្រូវប្រាប់អ្នក ដែលអ្នកមិនអាចនឹងយល់បាននាពេលឥឡូវនេះប៉ុន្តែនៅពេល ដែលព្រះអង្គយាងមកព្រះអង្គនឹងណែនាំដល់អ្នកឲ្យស្គាល់។៉ នោះគឺជាមូលហេតុនៃការយាងមកនៃត្រា។នៅពេលដែលត្រា សម្គាល់ទីប្រាំពីរត្រូវបានបញ្ចប់ អាថ៌កំបាំងរបស់ព្រះជាម្ចាស់ក៏គួរតែចប់សព្វគ្រប់ដែរ ដើម្បីស្គាល់ថាព្រះជាម្ចាស់គឺជានរណា តើព្រះអង្គគឺជាអ្វី ហើយព្រះអង្គរស់នៅដោយរបៀបណា ព្រះនាមរបស់ព្រះអង្គ លក្ខណៈរបស់ព្រះអង្គ។ អ្នកគួរតែទៅដល់ កំរិតមួយនៅវេលា *នោះ* ដោយនាំយើងទៅកាន់លក្ខណៈ ពេញលេញនៃកូនប្រុសកូនស្រី របស់ព្រះជាម្ចាស់ ក្រុមជំនុំមួយដែលបានលាងសំអាត នៅក្នុងព្រះលោហិតរបស់ព្រះគ្រីស្ទ ដែលបានទិញដោយមិនប្រើលុយ គឺបានបង់ថ្លៃ ដោយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ។

36 ឥឡូវយើងជាអ្នកនាំផ្លូវ និង ការផ្តត់ផ្គង់ឲ្យមានអ្នកនាំផ្លូវ របស់ព្រះជាម្ចាស់។ ឥឡូវយើងកំពុងតែឆ្លងកាត់ទីរហោស្ថាន ហើយយើងកំពុងតែស្ថិតនៅលើផ្លូវរបស់យើងណាមួយហើយក៏មិនអាចឆ្លងផុតដោយគ្មានអ្នកនាំផ្លូវនេះទេ។ ហើយតើមានអ្នកណាហ៊ានយកអ្នកនាំផ្លូវផ្សេងមកជំនួសដែរទេ! ប្រសិនជាអ្នកហ៊ាន នោះអ្នក

នឹងត្រូវខ្វាតចេញពីផ្លូវនោះហើយ។ អ្នកនាំផ្លូវគឺគាត់ស្គាល់ផ្លូវ! ស្គាល់គ្រប់ទាំងប្រវែង នៃផ្លូវ។ ព្រះអង្គជ្រាបរាល់ទាំងគំនិតដែលមាននៅក្នុងចិត្តរបស់អ្នក។ ព្រះអង្គ ស្គាល់ម្នាក់ៗនៅទីនេះ។ ព្រះអង្គស្គាល់ថាអ្នកគឺជានរណា ហើយអ្នកបានធ្វើអ្វី ហើយស្គាល់គ្រប់យ៉ាងអំពីអ្នក។ ព្រះអង្គគឺជាអ្នកនាំផ្លូវមកពីព្រះជាម្ចាស់ ព្រះវិញ្ញាណបរិសុទ្ធ ព្រមទាំងធ្វើការបើកសម្ដែង គ្រប់អ្វីមួយទៅកាន់អ្នក ហើយនឹងប្រាប់អ្នកពី សេចក្ដីណាដែលព្រះអង្គឮ អាចនិយាយឡើងវិញនូវពាក្យរបស់អ្នក ហើយនិយាយសម្ដីដែលអ្នកបាននិយាយ។អាម៉ែន។ ប្រាប់អ្នកនូវអ្វីដែលអ្នកធ្លាប់ឆ្លងកាត់ អ្វីដែលអ្នកទទួល កន្លែងដែលអ្នកនឹងទៅ។ ជាអ្នកនាំផ្លូវ អ្នកនាំផ្លូវដែលទៀងត្រង់ ហើយព្រះអង្គនឹងនាំអ្នកទៅកាន់គ្រប់ទាំងសេចក្ដីពិត និង ព្រះបន្ទូលរបស់ព្រះអង្គគឺជាសេចក្ដីពិត។

37 ឥឡូវ ព្រះវិញ្ញាណបរិសុទ្ធនឹងមិនដែលនិយាយពាក្យថា "អាម៉ែន" ចំពោះប្រភេទមនុស្សលោភនោះទេ។ គឺមានតែការប្រើសញ្ញាវណ្ណយុត្តិនៃព្រះបន្ទូល របស់ព្រះជាម្ចាស់ជាមួយនឹងពាក្យថា "អាម៉ែន" នោះឯង។ ព្រះវិញ្ញាណបរិសុទ្ធ នឹងមិន នាំអ្នកនៅតាមផ្លូវឯណាផ្សេងទៀត។ ហើយអ្វីដែលជារឿងដ៏ចម្លែកគឺថា យើងគ្រប់គ្នាមាន និកាយដែលល្អប្រសើរនិងអ្វីៗរៀងៗខ្លួន ដោយយើងម្នាក់ៗបានប្រកាស ថាយើងបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ ហើយវាមាន ភាព ខុសប្លែកគ្នាដូចជាថ្ងៃហើយនឹងយប់នៅក្នុងយើងទាំងអស់គ្នា។

38 ប៉ុន្តែនៅពេលដែល លោកប៉ូលដែលជាអ្នកកាន់តាមផារីស៊ីខ្លះៗ ដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ នៅពេលដែលលោកអាណានាសបានធ្វើពិធីជ្រមុជទឹកឲ្យគាត់ ហើយគាត់បានទៅប្រទេសអារ៉ាប់ ហើយសិក្សានៅទីនោះអស់រយៈពេលបីឆ្នាំ ទើបត្រឡប់មកវិញ ហើយមិនដែលបានទទួលការផ្ដល់ប្រឹក្សាពិគ្រោះ អ្វីទាំង អស់ពីក្រុមជំនុំអស់រយៈពេលដប់បួនឆ្នាំ ហើយពេលដែលគាត់ត្រលប់មក និង បាន ជួបជាមួយនឹងលោកពេត្រុស ដែលជាអ្នកដឹកនាំក្រុមជំនុំ នៅក្រុង យេរ៉ូសាឡឹម ពួកគេបានប៉ះគ្នាក្នុងគោលលទ្ធិ។ មូលហេតុអ្វី? ព្រះវិញ្ញាណ បរិសុទ្ធតែមួយ! ដែលលោកពេត្រុសបានទទួលពីពិធីជ្រមុជទឹកនៅក្នុងព្រះនាម ព្រះ យេស៊ូវគ្រីស្ទ លោកប៉ូលក៏បានធ្វើដូចគ្នានោះដែរដោយមិនមានអ្នកណា ប្រាប់ គាត់ទេ។ ដោយលោកពេត្រុសបានបង្រៀនពីការជ្រមុជទឹកដោយ ព្រះ វិញ្ញាណបរិសុទ្ធ និង ដោយ ការវិសុទ្ធជាដើម លោកប៉ូលបានធ្វើដូចគ្នាដែរដោយ គ្មានការ ប្រឹក្សា

ពីក្រុមជំនុំពីព្រោះមានអ្នកនាំផ្លូវតែមួយដូចគ្នា។ ហើយ តើយើងអាចជាអ្វីនាពេលបច្ចុប្បន្ននៅពេលដែលមនុស្សបដិសេធសេចក្ដីពិត ទាំងនេះ? នៅពេលដែលលោកពេត្រុសបានបង្រៀនអ្វីដែលគាត់បានធ្វើស្ដីពី របៀបដែលធ្វើឲ្យមានសណ្ដាប់ធ្នាប់ នៅក្នុងក្រុមជំនុំលោកប៉ូលក៏មានគោលលទ្ធិ ដូចគ្នា ព្រោះពួកគាត់មានអ្នកនាំផ្លូវតែមួយ។

39 អ្នកនាំផ្លូវគឺមិននាំម្នាក់ទៅ*តាមផ្លូវនេះ* ហើយម្នាក់ទៀតតាម*ផ្លូវនោះ* នោះទេ ហើយម្នាក់ទៅខាងកើត និង ម្នាក់ទៅខាងលិចនោះទេ។ ព្រះអង្គនឹងរក្សាទុកអ្នកជាមួយគ្នា។ ហើយបើសិនជាយើងគ្រាន់តែឲ្យព្រះវិញ្ញាណបរិសុទ្ធរក្សាយើងជាមួយគ្នា នោះយើងនឹងក្លាយជាតែមួយ។ ហើយប្រសិន—ប្រសិន ជាយើងមិនអនុញ្ញាតិឲ្យ វិញ្ញាណអាក្រក់ទាញយើងចេញទៅតាមផ្លូវដែលខុស នោះយើងនឹងមានចិត្តតែមួយ គំនិតតែមួយ ក្នុងភាពចុះសម្រុងតែមួយ ដោយ វិញ្ញាណតែមួយ ព្រះវិញ្ញាណបរិសុទ្ធ ដែលជាអ្នកនាំផ្លូវមកពីព្រះជាម្ចាស់ ដែល នឹង ណែនាំ នូវ គ្រប់សេចក្ដីពិតទាំងអស់។ វាត្រឹមត្រូវហើយ។ ប៉ុន្តែអ្នកត្រូវតែដើរតាមអ្នក ដែលនាំផ្លូវរបស់អ្នក។ គឺពិតមែនហើយ។

40 មើលលោកនីកូដេម គាត់ត្រូវការអ្នកនាំផ្លូវ ទោះជាគាត់ជាម នុស្សដែលឆ្លាតក៏ ដោយ។ គាត់ធ្លាប់ជាគ្រូបង្រៀនគាត់មានអាយុប្រហែលជា៨០ឆ្នាំ។ គាត់ធ្លាប់ជា គណៈផារីស៊ី ឬ—ឬ នៅក្នុងក្រុមប្រឹក្សាសានហេឌ្រីន ជាសមាគមដែលធ្វើការសម្រាប់ស្ថាប័នរដ្ឋនាពេលនោះ។ គាត់ធ្លាប់ជា អ្នកខ្ពង់ខ្ពស់ ជាគ្រូនៅក្នុងប្រទេសអ៊ីស្រា អែលជាចៅហ្វាយ។ ចូរគិតពិចារណាជាគ្រូដ៏គួរឱ្យស្ញប់ស្ញែងម្នាក់! គាត់ចេះ ច្បាប់ប៉ុន្តែពេលដែលត្រូវកើតជាថ្មី គាត់ក៏ត្រូវការមគ្គុទេសក៏ដឹកនាំ សម្រាប់គាត់ ដែរ។ គាត់ពិតជាស្រេកឃ្លានចង់បានខ្លាំងណាស់។ គាត់ដឹងថា ត្រូវតែ មានអ្វី ខុស ប្លែកជាមិនខាន។ ការសម្ដែងចេញរបស់គាត់ទៅកាន់ ព្រះគ្រីស្ទយប់នោះបាន បង្ហាញជាភស្តុតាង។ វាក៏បានសម្ដែងពីអារម្មណ៍របស់អ្នកដទៃទៀតដែរ ប៉ុន្តែគ្មាន—អ្នកណាម្នាក់ នៅក្នុងចំណោមពួកគេ ដែលមានភាព អង់ អាច ដូច ជាគាត់មាន។ ហើយក៏មិនមានអ្នកណាហ៊ានធ្វើអ្វីដូចជាគាត់បានធ្វើដែរ។ អ្នកទាំងអស់គ្នា បានធ្វើការ ថ្កោលទោសលោកនីកូដេម ដោយបានធ្វើដំណើរមក ដល់ ពេលយប់។ គាត់ទៅទីនោះ។ គាត់បានមកដល់។ ខ្ញុំដឹងថា មនុស្សមួយ ចំនួនមិន បានចាប់ផ្ដើមទេ ទោះជាពេលថ្ងៃ ឬក៏យប់។ ប៉ុន្តែគាត់បានទៅដល់ ទីនោះ ហើយគាត់

ត្រូវការអ្នកដែលណែនាំដល់គាត់ ព្រមទាំងនិយាយថា "លោក ម្ចាស់ យើង" មកពីសាលាប្រជុំ "យើងដឹងថាលោកគឺជាគ្រូដែលមកពីព្រះជាម្ចាស់។" ហេតុអ្វីបានជាគាត់ដឹង? គាត់បង្ហាញថាគាត់គ្មានកំហុសអ្វីទេ។ ឃើញ ទេគឺគាត់ចង់ដឹងថាតើការកើតជាថ្មីមានន័យយ៉ាងដូចម្តេច គាត់ចង់ធ្វើតាម សេចក្តី អ្វី ដែលត្រឹមត្រូវ ជាមួយមនុស្សដែលត្រឹមត្រូវ ពីព្រោះព្រះជាម្ចាស់ បាន បង្ហាញ ពីអ្នកដែល គ្មាន កំហុស ពីព្រះមគ្គុទេសក៏ដែលដឹកនាំ គឺព្រះយេស៊ូវ។ មើល សេច ក្តី ដែលគាត់ បាន និយាយ "លោកម្ចាស់ខ្ញុំដឹងថាលោកពិតជាគ្រូដែលមកពីព្រះជាម្ចាស់ ពីព្រោះគ្មានអ្នកណាម្នាក់អាច ធ្វើអ្វីដូចលោកបានធ្វើនោះទេ លុះត្រាតែ អ្នក នោះ មានព្រះ គង់នៅជាមួយ។"

41 វាបានបង្ហាញពីភាពដែលគ្មានកំហុសទេដែលព្រះជាម្ចាស់ដ៏មានព្រះជន្ម រស់គង់នៅជាមួយគាត់។ អ្វីដែលគាត់បានធ្វើបន្ទាល់នោះគឺ "មិនមែនជាខ្ញុំទេដែលធ្វើកិច្ចការនេះ ប៉ុន្តែគឺជាព្រះវរបិតាដែលសណ្ឋិតនៅក្នុងខ្ញុំ។ ព្រះយេស៊ូវ មាន ព្រះបន្ទូលទៅគេថា៖ ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា ព្រះបុត្រាពុំអាចធ្វើអ្វីដោយព្រះអង្គផ្ទាល់បានឡើយ គឺព្រះបុត្រាធ្វើតែកិច្ចការណា ដែលទ្រង់បានឃើញព្រះបិតាធ្វើប៉ុណ្ណោះ។ កិច្ចការអ្វីដែលព្រះបិតាធ្វើ ព្រះបុត្រាក៏ធ្វើកិច្ចការនោះដែរ។" នៅក្នុងពាក្យផ្សេងទៀត ព្រះជាម្ចាស់បានបង្ហាញព្រះអង្គនូវអ្វីដែលត្រូវធ្វើ ហើយព្រះអង្គយាងទៅធ្វើកិច្ចការនោះ។ ព្រះអង្គមិនបានធ្វើសេចក្តីអ្វីនោះទេរហូត ដល់ព្រះវរបិតាប្រាប់ព្រះអង្គឲ្យធ្វើវា។ អាម៉ែន។ នេះគឺជាហេតុការដែលកើតឡើង ជាក់ស្តែង។ ប្រសិនជាយើងគ្រាន់តែរងចាំ ព្រះវិញ្ញាណធ្វើចលនាក្នុងយើងមុនពេលយើង ចាប់ ផ្តើមធ្វើអ្វីមួយ! គឺវា ដូច្នេះឯង។ យើងនឹងលង់នៅក្នុងព្រះគ្រីស្ទ ដោយព្រះ អង្គមិន ចាំបាច់ជំរុញអ្នកដូចជាអ្វីដែលព្រះអង្គធ្វើដាក់ខ្ញុំ ប៉ុន្តែគ្រាន់តែការ ងក់ក្បាលបន្តិច ដំបូង គឺអ្នកត្រៀមខ្លួនរួចហើយ នឹងគ្មានអ្វីនឹងអាចបញ្ឈប់ អ្នកបានឡើយ ពីព្រោះអ្នកដឹកថានោះគឺជាបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

42 គាត់ត្រូវការអ្នកណែនាំម្នាក់។ ព្រះអង្គជាព្រះមគ្គុទេសក៏ ដែលគ្មានកំហុសឆ្គង ។ នឹងអាចដឹកនាំបានដោយគាត់ដឹងថា អ្នកនាំផ្លូវនេះគឺជាការបណ្តាលមកពីព្រះ ជាម្ចាស់។ គាត់ស្គាល់ពីការបំរើនៅ ក្នុងទំនៀមទំលាប់នៃពួកពីគណៈផារីស៊ុ និងសាឌូស៊ីហើយនៅមានផ្សេងដទៃទៀត គាត់បានបំរើអ្នកកាន់តាមលទ្ធិសាសនា និងមិន មានឃើញអ្វីកើតឡើតទាល់តែសោះ។ ប៉ុន្តែដោយសារមានបុរសម្នាក់គាត់

បាននៅក្នុងសាច់រឿងធំនេះ ដែលបានសន្យាថាគាត់គឺជាព្រះមេស៊ី ដែលមានចែង នៅក្នុងព្រះគម្ពីរ។ បន្ទាប់មកគឺព្រះអង្គបានមើលទីជុំវិញ ហើយព្រះអង្គបានធ្វើ កិច្ចការរបស់ព្រះជាម្ចាស់។ ព្រះយេស៊ូវមានបន្ទូលថា "ប្រសិនជាខ្ញុំមិនធ្វើតាមព្រះ វរបិតាខ្ញុំ នោះកុំ ជឿតាមខ្ញុំឡើយ។ ប៉ុន្តែបើសិនជាអ្នកមិនជឿដល់ខ្ញុំ ជឿដល់គ្រប់ កិច្ចការ ដែល ខ្ញុំធ្វើ ព្រោះវាជាបន្ទាល់អំពីខ្ញុំ។"

43 បន្ទាប់ពីនោះលោកនីកូដេម លែងសង្ស័យដោយនិយាយថា "លោកម្ចាស់ យើង ដឹង ថាលោកគឺជាគ្រូដែលមកពីព្រះជាម្ចាស់ ព្រោះគ្មាន អ្នកណាម្នាក់ អាច ធ្វើ កិច្ច ការដែលលោកធ្វើបានឡើយ បើសិនជាគ្មានព្រះ ជាម្ចាស់ គង់នៅ ជាមួយ ព្រះអង្គទេ។" ឃើញទេ គាត់នៅតែ ត្រូវការអ្នកណែនាំទោះបីជាគាត់គឺជា ថ្នាក់ដឹក នាំជាន់ខ្ពស់ក៏ដោយ។គាត់ជាអ្នកដឹកនាំនៅព្រះវិហាររបស់គាត់។ គាត់មាន សេច ក្ដីថ្លៃថ្នូរហើយគាត់មាន—កន្លែងដែលសមរម្យ គាត់ជាបុរសម្នាក់ដ៏ពូកែគឺ គ្មាន ការ សង្ស័យនោះទេដែលគាត់ទទួល បានការគោរពពីមនុស្សទូទាំងប្រទេស។ ប៉ុន្តែ ដល់ពេលដែលកើតជាថ្មី គាត់ត្រូវការអ្នកណែនាំដល់គាត់! យើងក៏ដូចគ្នាដែរគឺ យើង ក៏ត្រូវការអ្នកណែនាំដូចគ្នា។

44 លោកកូនេលាស ជាបុរសខ្លាំងពូកែម្នាក់ និងជាអ្នកខ្ពង់ខ្ពស់។ គាត់សាង សង់ព្រះវិហារ។ គាត់បានផ្ដល់ការគោរពចំពោះសាសន៍យូដា ពីព្រោះគាត់ដឹងថា សាសនារបស់ពួកគេគឺត្រឹមត្រូវ។ ហើយគាត់បានដាក់ទាន និងអធិស្ឋាន ជារៀង រាល់ថ្ងៃប៉ុន្តែនៅពេលដែលព្រះវិញ្ញាណយាងមក(មានអ្វីដែលត្រូវបន្ថែមនៅ ក្នុងព្រះ វិហារ) គាត់ត្រូវការអ្នកណែនាំ។ ព្រះជាម្ចាស់បានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ មក ឲ្យគាត់។ ព្រះអង្គបានចាត់ព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតក្នុងពេត្រុស។ "មួយសន្ទុះ ក្រោយមកពេត្រុសមិនទាន់និយាយពាក្យទាំងនោះចេញនៅឡើយ ព្រះវិញ្ញាណ បរិសុទ្ធបានសណ្ឋិតនៅលើគាត់។" [ការសែនទទេ—Ed។] ព្រះជាម្ចាស់ បាន ប្រើអ្នកណែនាំតាមរយៈលោកពេត្រុស។ ព្រះអង្គបានប្រើអ្នកណែនាំនោះ ពី ព្រោះ ព្រះអង្គក៏បាននាំ ផ្លូវដល់លោកកូនេលាស ទៅកាន់ផ្លូវដែលត្រឹមត្រូវដែរ។ ហើយ នៅពេលដែលគាត់ មិនទាន់និយាយនៅឡើយ ព្រះវិញ្ញាណបរិសុទ្ធ បាន សណ្ឋិត នៅលើពួកសាសន៍ដទៃ។ ពេលនោះ គាត់មានប្រសាសន៍ថាៈ "តើមាននរណាអាច ឃាត់ទឹកនេះ មិនអោយធ្វើពិធីជ្រមុជទឹកអ្នកទាំងនេះបាន"? ឃើញទេ ជាអ្នកនាំផ្លូវ ដែលមានបន្ទូល មិនមែនជាលោកពេត្រុសទេ។ ពីព្រោះ មានក្រុមសាសន៍យូដា...

និងសាសន៍ដទៃ "ទាំងអ្នកមិនស្អាត ទាំងអ្នកកខ្វក់" ចំពោះគាត់ គឺគាត់មិនចង់ទៅទាល់តែសោះ។ ប៉ុន្តែដោយអ្នកនាំផ្លូវមានបន្ទូល "យើងចាត់អ្នកឲ្យទៅ។" អ្នកនឹងធ្វើកិច្ចការដែលអ្នកមិនគិត ថា អ្នកមិនអាច ធ្វើបាន នៅពេលដែល អ្នកនាំ ផ្លូវបានដឹកនាំដោយពេញលេញ នៅពេលដែលអ្នកអនុញ្ញាតឲ្យព្រះអង្គនាំផ្លូវដល់អ្នក។ អូ តើវាអស្ចារ្យយ៉ាងណាទៅ ដែលមានព្រះវិញ្ញាណបរិសុទ្ធជាអ្នកដឹកនាំ។ ព្រះអង្គគឺជាអ្នកនាំផ្លូវ។ ដូច្នេះហើយ។ ព្រះអង្គមានបន្ទូលតាមរយៈពេត្រុស និងបានប្រាប់គាត់ពីអ្វីដែលគាត់ត្រូវធ្វើ។ បន្ទាប់ពីពួកគេទាំងអស់បានទទួលព្រះវិញ្ញាណបរិសុទ្ធពេលនោះ គាត់និយាយថា៖ "គ្មាននរណាអាចឃាត់យើង មិនអោយធ្វើពិធីជ្រមុជទឹកជូនអស់អ្នកដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ ដូចជាយើងបានទទួលដែរនោះទេ"។ ហើយពួកគេបានទទួលពិធីជ្រមុជទឹក ដោយនូវព្រះនាមព្រះយេស៊ូវ។ ឥឡូវ តើអ្នកណាបាននាំគាត់ឲ្យធ្វើបែបនោះ? គឺអ្នកនាំផ្លូវដែលនៅក្នុងគាត់។ តើព្រះយេស៊ូវមិនបានមានបន្ទូលទៅកាន់ពួកគេទេ "ចូរកុំភ័យបារម្ភនឹងរកពាក្យដែលអ្នករាល់គ្នាត្រូវនិយាយយ៉ាងណាៗនោះឡើយ ដ្បិតព្រះជាម្ចាស់នឹងប្រទានពាក្យដែលអ្នករាល់គ្នាត្រូវនិយាយ នៅពេលនោះតែម្តង? អាម៉ែន។"

45 មហាតលិក បានធ្វើដំណើរមកពីក្រុងយេរ៉ូសាឡឹម។ ហើយព្រះជាម្ចាស់បាននាំផ្លូវគាត់នៅពេលនោះ ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយគាត់មានបុរសម្នាក់ទៀតនៅទីនោះដែលបានពេញដោយការដឹកនាំនោះដូចគ្នា។ គាត់មិនមែនជាអ្នកអធិប្បាយនោះទេ គាត់គ្រាន់តែដូចជាគ្រូជំនួយ។ ហើយគាត់បានធ្វើដំណើរដល់ទីនោះដោយប្រោសអ្នកជំងឺឲ្យជា និង ដេញវិញ្ញាណអាក្រក់ ហើយបានបណ្តេញនូវភាពរឹករវរ ហើយទីក្រុងនោះបានពេញទៅដោយអំណរ។ គាត់មានមនុស្សរាប់រយអ្នកនៅជុំវិញគាត់ ហើយអ្នកនាំផ្លូវនិយាយថា "ប៉ុណ្ណឹងបានហើយ ចូរត្រឡប់មកតាមផ្លូវនេះវិញ។" គាត់មិនបានឈ្លោះប្រកែកជាមួយនឹងអ្នកនាំផ្លូវរបស់គាត់ទេ។

46 ដាច់ខាតមិនត្រូវមាន ការឈ្លោះប្រកែកជាមួយពាក្យ អ្នកនាំផ្លូវរបស់អ្នកឡើយ។ ត្រូវតាមគាត់។ ប្រសិនជាអ្នកមិនព្រមធ្វើតាមនោះទេអ្នកនឹង វង្វេងផ្លូវជាមិនខាន។ ហើយត្រូវចាំថានៅពេលដែលអ្នកចាកចេញពីអ្នកនាំផ្លូវនោះអ្នកនឹងទៅតាម ផ្លូវ របស់អ្នក ដូច្នេះហើយយើងចង់នៅជិតស្និទ្ធជាមួយនឹងអ្នកនាំផ្លូវ។

47 ដូច្នេះនៅតាមផ្លូវទ្រង់មានបន្ទូលថា "ភីលីព ចូរចាកចេញពីបណ្តាជន ហើយចេញទៅវាលរហោស្ថានដែលជាកន្លែងដែលគ្មានអ្នកណានៅ។ ប៉ុន្តែនៅ ពេល

ដែលយើងបញ្ជូនឯងទៅទីនោះ យើងនឹងបញ្ជូនមនុស្សឲ្យឯង។″ នឹងមាន មន្ត្រីមហាតលិកម្នាក់ដែលមកដល់ គាត់ជាមន្ត្រីល្អម្នាក់របស់ម្ចាស់ក្សត្រីមួយអង្គនៅស្រុក ត្យូពី។ កំពុងតែធ្វើដំណើរ បណ្តើរគាត់អានគម្ពីរព្យាការីអេសាយបណ្តើរ។ ហើយ អ្នកនាំផ្លូវមាននិយាយថា ‶ចូរទៅមុខ រួចចូលទៅជិតរទេះសេះនោះទៅ″។

ហើយ គាត់ក៏សួរថា ‶តើលោកយល់អ្វីដែលលោកកំពុងតែអានដែរឬទេ?″

48 គាត់តបមកវិញថា៖ ‶ធ្វើម្តេចអោយខ្ញុំយល់បាន បើគ្មាននរណាពន្យល់ណែនាំសោះ នោះ?″ អូ! ប៉ុន្តែភីលីពមានអ្នកនាំផ្លូវ។ អាម៉ែន។ ហើយគាត់ក៏ចាប់ ផ្តើមអានពីជំពូកដដែលៗ ហើយអធិប្បាយពីព្រះគ្រីស្ទទៅកាន់គាត់។ អាម៉ែន។ អ្នក នាំផ្លូវ! លោកមិនបានប្រាប់គាត់ពីគោលលទ្ធិសាសនាអ្វីនោះទេ តែគាត់បានប្រាប់ស្តីពី អ្នកណែនាំ គឺព្រះគ្រីស្ទ! ហើយលោកបានធ្វើពិធីជ្រមុជទឹកឲ្យគាត់នៅទីនោះ។ វាបានកើតឡើងពិតមែន។ អូ ខ្ញុំចូលចិត្តខ្លាំងណាស់!

49 នៅពេលដែលជនជាតិអ៊ីស្រាអែលបានចាកចេញ ពីប្រទេសអេស៊ីបទៅកាន់ទឹកដីសន្យានៅក្នុងនិក្ខមនំ១៣:២១ព្រះជាម្ចាស់ជ្រាបថាពួកគេមិនដែលធ្វើ ដំណើរតាមផ្លូវដែលវែងឆ្ងាយពីមុនមកទេ។ គឺគ្រាន់តែមានចម្ងាយសែសិបម៉ាយ ប៉ុន្តែពួកគេត្រូវតែមានអ្វីមួយទៅជាមួយពួកគេ។ ពួកគេបានវង្វេងផ្លូវ។ ដូច្នេះហើយបានជាព្រះជាម្ចាស់បានបញ្ជូនអ្នកនាំផ្លូវឲ្យពួកគេ។ និក្ខមនំ ១៣:២១ គឺអ្វីមួយ ដូចជា ‶យើងចាត់ទេវតានាំមុខអ្នក សសរភ្លើង ដែលបំភ្លឺផ្លូវពួកគេ។″ ដើម្បីនាំផ្លូវពួកគេទៅកាន់ទឹកដីសន្យា។ ហើយកូនចៅអ៊ីស្រាអែលបានដើរតាមអ្នកនាំផ្លូវនោះ សសរភ្លើង(ពេលយប់)ដុំពពក នៅពេលថ្ងៃ។ នៅពេលដែលដុំនោះឈប់ ពួកគេក៏ឈប់។ ពេលដុំនោះធ្វើដំណើរទៅមុខ ពួកគេក៏ធ្វើដំណើរ។ ហើយ នៅពេលដែលពួកគេជិតទៅដល់ទឹកដីនោះ គឺពួកគេមិនអាច ឈានចូលបាន ព្រះអង្គនាំគេត្រឡប់ទៅកាន់ទីរហោស្ថានវិញ។ ពេលនោះព្រះអង្គ មិននៅជាមួយនឹងពួកគេទេ។

50 នោះជាអ្វីដែលកើតឡើង នៅក្នុងក្រុមជំនុំនាពេលបច្ចុប្បន្ន។ មិនមានអ្វីត្រូវឆ្ងល់ទេ ប៉ុន្តែអ្វីដែលជាការរងទុក្ខវេទនាមកពីព្រះជាម្ចាស់នាពេលបច្ចុប្បន្ន គឺដូចជាអ្វីដែលកើតឡើងនៅក្នុងសម័យរបស់លោកណូអេ ក្រុមជំនុំនឹងបាត់ទៅ បើសិនជាមានការកែតំរូវ និងដាក់ឲ្យមានសណ្តាប់ធ្នាប់។ ប៉ុន្តែទ្រង់ត្រូវតែនាំយើងដើរវិលជុំម្តងហើយម្តងទៀត ម្តងទៀត។

51 អ៊ីស្រាអែលបានដឹងខ្លះៗ នៅពេលដែលពួកគេស្រែក ដោយឃើញទាហានរបស់អេស៊ីបបានស្លាប់ ទ័ពសេះលង់នៅក្នុងទឹក រទេះចម្បាំងរបស់ផារ៉ោនក្រឡាប់ ពួកគេបានទទួលជ័យជំនះ ម៉ូសេដើរដោយវិញ្ញាណ ច្រៀងក្នុងវិញ្ញាណ ម៉ារាម រាំក្នុងវិញ្ញាណ និងកូនស្រីរបស់អ៊ីស្រាអែលរាំលោតកញ្ចែង ស្រែកហ៊ោកញ្ជ្រៀវ ដែលមានតែពីរទៅបីថ្ងៃពី កន្លែងដែលមានទឹកដោះនិង ទឹកឃ្មុំ។បន្ទាប់មកទើបដឹង ថានៅមានរយៈពេលសែសិបឆ្នាំទៀត ដោយសារតែការរអ៊ូរទាំរបស់ពួកគេជំទាស់ ទៅនឹងព្រះជាម្ចាស់ និង អ្នកនាំផ្លូវ។

52 ហើយយើងឃើញខ្លួនឯង នៅក្នុងរបៀបដូចគ្នាដែរ។ ខ្ញុំទៅទីក្រុងស្រីផតបន្ទាប់មក។ ហើយព្រះវិញ្ញាណបរិសុទ្ធបានបំពេញនៅថ្ងៃបុណ្យអរព្រះគុណ កាលពី ហា សិបឆ្នាំ កន្លងផុតទៅនៅ—នៅក្នុង រដ្ឋលូវីស្សីអាណា នៅថ្ងៃបុណ្យអរព្រះគុណ។ តើព្រះវិហារ បានចាក់ បំពេញដោយរបៀបណាចាប់តាំងពីពេលនោះ! តើអ្នក បាន ដឹងថា វិហាររ៉ូមមុាំងការតូលិកគឺចាប់ផ្តើមពីវិហារពេនទីកុ ស្ត? នោះគឺជាការ ពិត។ វាពិតណាស់។ គឺព្រះវិហារពេនទីកុស្ត ប៉ុន្តែការលើកកម្ពស់ខ្លួនឯងបានធ្វើ ឲ្យមាន ការប្រែក្លាយ—ដោយយកព្រះបន្ទូលរបស់ ព្រះជាម្ចាស់ ធ្វើជា ទំនៀមទំ លាប់របស់ គេ ដោយបន្ទឹងបន្ថែមជាដើម។ ហើយមើលពីឥឡូវពួកគេ ទទួលបានអ្វី ស្ទើរតែគ្មាន ព្រះបន្ទូលនៃបទគម្ពីរនៅក្នុងនោះសោះ។ គឺត្រូវបានជំនួសដោយអ្វីមួយផ្សេងទៀត ចំរៀកនំប៉័ង សំរាប់ព្រះវិញ្ញាណបរិសុទ្ធ។ ជំនួសការជ្រមុជចូលទៅក្នុងទឹក ដោយការប្រោះទឹក។ ពួកគេជំនួស "ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ" ដោយ "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។" ពួកគេជំនួសគ្រប់ប្រធានបទ សំខាន់ៗអំពីព្រះ ជាម្ចាស់ ដែលបានប្រទានមកដល់យើង ហើយពួកគេ កាន់តែឃ្លាតឆ្ងាយទៅៗ ចេញពីគោលលទ្ធិបទគម្ពីរ។

53 ហើយពេនទីកុសបាន បំពេញនៅក្នុងរដ្ឋលូវីស្សីអាណា ហាសិបឆ្នាំកន្លង ផុតទៅ ហើយបើសិនជាអាចឈរបានពីររយឆ្នាំទៀត គឺកាន់តែឃ្លាត ឆ្ងាយជាងវិហារកាតូលិកទៀត ប្រសិនជាវានៅតែបន្តធ្លាក់ចុះតាមរបៀបកាលពីហាសិបឆ្នាំ កន្លងទៅ ដោយមូលហេតុគេចេះតែបន្ថែមរាល់ពេលជានិច្ច។ អ្នកអធិប្បាយជំនាន់ដើមគឺហួសហើយ។ ការជួបប្រជុំគ្នានៅតាមដងផ្លូវអ្នកមិនដែលឮទៀតឡើយ។ គ្រប់យ៉ាងត្រូវបានបន្ថែមដោយក្រុមហូលីរ៉ូដ សក់កន្ទ្រើង ស្រ្តីស្លៀកពាក់ខោខ្លី លាបពណ៌ ហើយនៅមានទៀត ហើយហៅខ្លួនឯងថាជាគ្រីស្ទាន។ ខ្លះមាន កាន់ ហ្គីតា

ហើយរត់ចុះឡើង ហើយស្ត្រីស្លៀកសំលៀកបំពាក់រឹតតឹង...ជាប់សាច់—ខ្លួន ហាក់បីដូចជាខ្លួននៅកណ្ដាលវាល គ្រវីគ្រលែងចុះឡើងរត់ចុះឡើងពេញវេទិកា រាំរែកដោយទាញមេក្រូចុះ ហើយ ស្ត្រីទាំង នោះហៅខ្លួន ឯងថាគ្រីស្ទាន។

54 អ្វីដែលយើងត្រូវការគឺអ្វីដែលនៅជំនាន់ដើម ព្រះជាម្ចាស់បានបញ្ជូន ការបញ្ឆេះ សាសនាដែល បញ្ឆេះអ្វីដែលជាលោកិយចេញពីក្រុមជំនុំ។ យើងត្រូវតែត្រឡប់មកព្រះវិញ្ញាណបរិសុទ្ធវិញ និងភ្លើងរបស់ព្រះវិញ្ញាណ ត្រឡប់ទៅកាន់ភ្លើងនៃព្រះវិញ្ញាណ ហើយបញ្ឆេះរាល់ទាំងច្រេះ នាំការអធិប្បាយជំនាន់ដើមត្រឡប់មកវិញ ធ្វើឲ្យស្ថានសួគ៌ខ្ពស់ស្កឹមស្កៃ និងស្ថាននរកក្ដៅគគុក ដូចជាតំរង់កាំភ្លើងធំ។ យើងត្រូវការការអធិប្បាយប្រភេទនោះ។ ប៉ុន្តែអ្នកធ្វើវានៅថ្ងៃនេះ សមាជិករបស់អ្នក នឹងបោះឆ្នោតទំលាក់អ្នក។

55 ពេលខ្លះអ្នកអធិប្បាយដែលល្អ គឺនាំទៅផ្លូវខុស ដោយសមាជិករបស់ពួកគេ។ នោះជាមូលហេតុដែលខ្ញុំគ្មាននិកាយ។ ខ្ញុំមានទីចាត់ការតែមួយ ដែលមកពី ស្ថានសួគ៌។ កន្លែងណាដែលព្រះអង្គចាត់ឲ្យខ្ញុំទៅខ្ញុំនឹងទៅ។ អ្វីដែលព្រះអង្គមានបន្ទូលខ្ញុំនិយាយ។ យើងមិនចង់បាននិកាយ។ ក្រុមជំនុំនេះធ្លាប់និយាយអំពីនិកាយនោះ អ្នកនឹងបាត់បង់គ្រូគង្វាលរបស់អ្នក។ ខ្ញុំមិនសេពគប់ទេសូម្បីតែប្រាំនាទី។ គ្រប់ក្រុមជំនុំ ដែលមាននិកាយទៅដើម្បីសាបគ្រាប់ពូជ ហើយប្រាប់ខ្ញុំនូវអ្វីដែលខ្ញុំមិន ចង់បានហើយប្រាប់ខ្ញុំ ពីព្រះមួយអង្គបានរស់ឡើងវិញ។ ព្រះវិញ្ញាណបរិសុទ្ធបញ្ជូនមកដើម្បីណែនាំដល់ក្រុមជំនុំ មិនមែនសំដៅលើតែក្រុមមនុស្សមួយ ចំនួននោះទេ។ ព្រះវិញ្ញាណបរិសុទ្ធគឺមានគ្រប់ប្រាជ្ញាញាណ។ មនុស្សគឺមាន លក្ខណៈមិនអើពើ។

56 ព្រះជាម្ចាស់បានប្រាប់គេថា ព្រះអង្គនឹងបញ្ជូនអ្នកនាំផ្លូវម្នាក់ឲ្យគេ ព្រះអង្គនាំ គេទៅតាមផ្លូវ។ ហើយដរាបណាពួកគេដើរតាមសរសរភ្លើង គឺពួកគេមិនអីទេ។ ព្រះអង្គបាននាំគេ ទៅដល់ព្រំប្រទល់នៃទឹកដីសន្យា ហើយបន្ទាប់មកក៏បែរទៅជាឆ្ងាយទៅៗនៅពេលដែលព្រះអង្គដឹកនាំទៅ។បន្ទាប់មកលោកយ៉ូស្វេជាអ្នកចម្បាំងដ៏ប៉ិនប្រសប់ នឹកចាំពីថ្ងៃដែលព្រះអង្គបង្គាប់ដល់ពួកគេ "ចូរញែកខ្លួនជាវិសុទ្ធ នៅថ្ងៃទីបីព្រះជាម្ចាស់នឹងបើកផ្លូវឲ្យអ្នករាល់គ្នាអាចឆ្លងកាត់ ទន្លេយ័រដាន់"? ឥឡូវចូរមើលនូវអ្វីដែលព្រះអង្គមានបន្ទូល(ខ្ញុំពេញចិត្ត) នៅក្នុង បទគម្ពីរព្រះអង្គ មាន

បន្ទូលថា "ចូរនៅពីក្រោយក្បែរហិបនៃសម្ព័ន្ធមេត្រី ដោយអ្នក រាល់គ្នាមិនដែលឆ្លងកាត់ផ្លូវនេះពីមុនមកនោះទេ។"

57 តើអ្វីទៅជាហិបនៃសម្ព័ន្ធមេត្រី? ជាព្រះបន្ទូល។ កុំធ្វើដំណើរតាមឬសគល់នៃនិកាយបច្ចុប្បន្ន ចូរនៅពីក្រោយព្រះបន្ទូល ដោយអ្នកមិនដែលឆ្លងកាត់ផ្លូវនេះពីមុនមក។ បងប្អូនអើយនឹងមានពេលវេលាកំណត់មកដល់ក្រុមជំនុំគ្រីស្ទបរិស័ទនឹងធ្វើការពិសោធន៍ដោយខ្លួនឯងផ្ទាល់ គឺឥឡូវនេះ។ យើងកំពុងតែនៅកន្លែងប្រជុំធំមួយដែលកំពុង តែប្រព្រឹត្តទៅនៅក្នុងទីក្រុងរ៉ូមឥឡូវនេះ ភាពខុសប្លែកគ្នាកំពុង តែធ្វើឡើង ការចូលជាសម្ព័ន្ធរួមគ្នាដើម្បីបង្កើតជាទ្រង់ទ្រាយមួយ គឺដូចគ្នាបេះបិទទៅនឹងអ្វីដែលមានចែងនៅក្នុងព្រះបន្ទូល។ ហើយអ្នកបានដឹងពីអ្វីដែលយើងនិយាយកាលពីព្រឹកមិញនៅក្នុងរាជសារ។ ហើយឥឡូវនេះគ្រប់យ៉ាងគឺត្រឹមត្រូវ ហើយមនុស្សនៅតែដើរតាមគោលលទ្ធិសាសនា។ អ្នកគួរតែនៅពីក្រោយព្រះ បន្ទូលប្រសើរជាង! ព្រះបន្ទូលនឹងនាំអ្នកឆ្លងផុត ពីព្រោះព្រះបន្ទូលនោះគឺជាព្រះ គ្រីស្ទហើយព្រះគ្រីស្ទគឺជាព្រះជាម្ចាស់ហើយព្រះជាម្ចាស់គឺជាព្រះវិញ្ញាណបរិសុទ្ធ។

58 ឈរនៅពីក្រោយព្រះបន្ទូល! អូ មែនហើយ! ចូរនៅជាមួយអ្នកនាំផ្លូវនោះ។ នៅជាប់ពីក្រោយ។ កុំនៅពីមុខ អ្នកត្រូវតែនៅពីក្រោយ។ ចូរឲ្យព្រះបន្ទូលនោះជាអ្នកនាំផ្លូវ កុំធ្វើជាអ្នកនាំព្រះបន្ទូល។ ចូរឲ្យវាទៅ។

59 យ៉ូស្វេមានប្រសាសន៍ថា "ដោយអ្នករាល់គ្នាមិនដែលឆ្លងកាត់ផ្លូវនេះពីមុនមក នោះអ្នករាល់គ្នាមិនស្គាល់ផ្លូវនេះទេ។"

60 នោះជាបញ្ហានាពេលសព្វថ្ងៃ។ គឺអ្នកមិនត្រូវការអ្នកនាំ ផ្លូវឲ្យនាំអ្នកទៅ តាមផ្លូវដ៏ធំនោះទេ។ អូ អ្នកដឹងគ្រប់ទាំងច្រកល្ហក និងស្គាល់គ្រប់ទាំងអស់គឺអ្នកស្គាល់ផ្លូវទៅកាន់អំពើបាប។ មិនមាន...អូ អ្នកនៅរិលវល់អស់រយៈពេលជាយូរ។ គឺមិនចាំបាច់ឲ្យ មានអ្នកណាប្រាប់អ្នកទេ អ្នកដឹងគ្រប់ផ្លូវកាត់។ ត្រឹមត្រូវហើយ គឺគ្រប់អំពើបាប ទាំងអស់អ្នកស្គាល់ទាំងអស់។ មិនចាំបាច់មានអ្នកណាមកប្រាប់ អ្នកឲ្យលួចគឺអ្នក ចេះតែម្តង។មិនចាំបាច់មានអ្នកប្រាប់អ្នកឲ្យចេះដេរដាក់បណ្តាសាទេ គឺអ្នកចេះ។ មិនមានអ្នកណាប្រាប់អ្នកឲ្យធ្វើរឿងអាក្រក់ទេ ពីព្រោះវាមាន នៅគ្រប់ជាកន្លែង។

61 ប៉ុន្តែត្រូវចាំថា អ្នកដែលជាគ្រីស្ទាន អ្នកបានឆ្លងផុតហើយ។ គឺបានឆ្លង ទៅកាន់ទឹកដីមួយទៀត។ អ្នកបានកើតជាថ្មី។ អ្នកនៅក្នុងទឹកដីស្ថានសួគ៌។ អ្នកកំពុងតែនៅក្នុងទឹកដីសន្យា។

62 អ្នកអាចសម្លឹងមើល ឃើញផ្លូវនៅមុំនេះ។ អូ មែនហើយ អ្នកដឹងពីរបៀបដែលត្រូវឈរលើកន្លែងដែលជាក់លាក់។ អ្នកស្គាល់ពី—ពីរបៀបនៃការប្រើប្រាស់សន្លឹកបៀរដោយសាប់ជាមួយដៃ។ អ្នកដឹងពីការលេងឡុកឡាក់នៅពេលដែលគេក្រឡុកវាតើវាមានន័យដូចម្ដេច ហើយគ្រប់យ៉ាងគឺយ៉ាងនោះ។ ប៉ុន្តែនៅ ពេលដែលស្គាល់ពីភាពបរិសុទ្ធ និងភាពសុច្ចរិត និងអំណាចរបស់ព្រះជាម្ចាស់ ហើយដឹងពីដំណើរការ និងកិច្ចការដែលព្រះវិញ្ញាណបរិសុទ្ធធ្វើ គឺអ្នកនៅពីក្រោយ ព្រះបន្ទូលដែលជាអ្នកនាំផ្លូវ។ ឃើញទេ? អ្នកមិនដែលឆ្លងកាត់ផ្លូវនោះពីមុន មកទេ។

63 ពិតមែនហើយ អ្នកអាចនិយាយបានថា "ខ្ញុំជាបុរសឆ្លាតម្នាក់ ខ្ញុំមាន—មានសញ្ញាប័ត្រពីរមកពី មហាវិទ្យាល័យ។" អ្នកគួរតែបំភ្លេចវាចោលទៅ។ មែនហើយ។

64 "ខ្ញុំធ្លាប់ឆ្លងកាត់សិក្ខាសាលា។" អ្នកបំភ្លេចវាចោលទៅ។ មែនហើយ។ អ្នកគួរ តែ នៅពីក្រោយអ្នកនាំផ្លូវរបស់អ្នក ប្រសើរជាង។ ចូរ ឲ្យអ្នកនាំផ្លូវនោះនាំអ្នកទៅ។ ព្រោះ ទ្រង់ស្គាល់ផ្លូវដែលអ្នកមិនស្គាល់។ អ្នកមិនធ្លាប់ឆ្លងកាត់ផ្លូវនោះពីមុនមកនោះទេ។ "ល្អណាស់" អ្នកនិយាយ "ពួកគេស្គាល់។"

65 មើលបើសិនជាពួកគេពិតជាស្គាល់មែន។ ព្រះយេស៊ូវមានបន្ទូលថា "អ្នកដែល ឆ្លងកាត់ផ្លូវនេះ ទីសំគាល់ទាំងនេះនឹងតាមមកជាមួយគេ។ គឺគេនឹងដេញអារក្សក្នុងនាមខ្ញុំ គេនិយាយភាសាថ្មី។ ប្រសិនបើគេកាន់ពស់ ឬផឹកអ្វីដែលមានជាតិពុល ក៏គេពុំមានគ្រោះថ្នាក់អ្វីដែរ។ ប្រសិនបើគេដាក់ដៃលើអ្នកជំងឺអ្នកជំងឺនឹង បាន ជា សះស្បើយ។" មនុស្សជាច្រើនបានបដិសេធ បដិសេធ គឺអត់មានការបណ្ដាល នោះ ទេ។ ពួកគេមិនធ្វើតាមអ្នកណែនាំ។ គឺពួកគេដើរតាមមនុស្ស ដែលកាន់សាសនា ធ្វើតាម គោលលទ្ធិ។ អ្នកគួរតែនៅពីក្រោយព្រះបន្ទូលប្រសើរ ជាងពីព្រោះអ្នកមិនធ្លាប់ដើរតាមផ្លូវនេះ អ្នក ដឹងទេ។

66 ប៉ុន្តែអ្នកបានកើតជាថ្មី អ្នកបានកើតនៅក្នុងភាពបរិសុទ្ធ។ អ្នកមិនធ្លាប់ឆ្លងកាត់ផ្លូវនោះពីមុនមក។ ប្រសិនជាអ្នកឆ្លងកាត់តាមផ្លូវនេះ...អ្នកត្រូវតែឆ្លងកាត់ភាពរិសុទ្ធ ពីព្រោះវាគឺជាទឹកដីថ្មី ជីវិតថ្មី មនុស្សថ្មី។

67 អ្នកនឹងមកព្រះវិហារ ហើយលឺឮមនុស្សបន្លឺសម្លេងឡើង វិសុទ្ធ "ថ្វាយសេរីល្អដល់ព្រះជាម្ចាស់!ហាលេលូយ៉ា!"

68 ហេតុអ្វី អ្នកនឹងនិយាយថា "តែ ពួកគេមិនដែលធ្វើអញ្ចឹងទេនៅក្នុងព្រះវិហាររបស់ខ្ញុំ! ខ្ញុំនឹងក្រោកឡើងហើយធ្វើវា!" មើល? ចូរប្រយ័ត្ន។

69 នៅពីក្រោយព្រះបន្ទូល ឥឡូវចូរឲ្យអ្នកនាំផ្លូវ នាំអ្នក។ "ព្រះអង្គនឹងនាំអ្នកទៅកាន់គ្រប់ទាំងសេចក្តីពិត និងបើកសម្តែងនូវរាល់កិច្ចការទាំងនេះ ដែលអ្នកកំពុងនិយាយ។ ព្រះអង្គនឹងបង្ហាញអ្នក។ ព្រះអង្គនឹងប្រាប់អ្នកនូវអ្វីនឹងត្រូវមកដល់" អ្នកនាំផ្លូវដ៏ពិត។ សូមកុំទៅរកសង្ឃរាជឬបូជាចារ្យ តែចូលទៅអ្នកនាំផ្លូវ។ កុំទៅរកអ្នកណាផ្សេង តែទៅរកអ្នកនាំផ្លូវ។ គឺជាមួយអង្គដែលត្រូវបានបញ្ជូនមកឲ្យនាំផ្លូវដល់អ្នក។ គឺមានតែព្រះអង្គមួយអង្គគត់ដែលអាចធ្វើបាន។ ព្រះជាម្ចាស់ បាន ប្រទានអ្នកនាំផ្លូវ ដល់អ្នក។ ចូរយកផ្លូវដែលព្រះជាម្ចាស់ផ្តល់ឲ្យ។

70 បញ្ហាដែលកើតមានបច្ចុប្បន្នមនុស្ស ដែលដើរចូលមកព្រះវិហារគឺគេគ្រាន់តែអង្គុយពីពីរទៅបីនាទីហើយជួបនូវហេតុការណ៍ដែលពួកគេមិនធ្លាប់ជួបពីមុនមក។

71 ខ្ញុំមានការកោតសរសើរស្ត្រីតូចម្នាក់ដែលមកពីព្រះវិហារមួយ យើងគ្រាន់តែអធិស្ឋានឲ្យនាង។ ព្រះជាម្ចាស់នឹងព្យាបាលដល់ប្អូនស្រី។ នាងអត់យល់ទេ។ គាត់ អត់ដឹងពីអ្វីទាំងនេះទេ។ នាងដើរចូលមក ហើយនិយាយថានាងអត់យល់។ ប៉ុន្តែ ខ្ញុំបានប្រាប់នាង "ចូលមក ហើយមើលខ្ញុំ។" នាងជាស្ត្រីដែលអិមអៀន និងមិនសូវហ៊ាន ប៉ុន្តែដោយមានអ្នកណែនាំ ចេះតែបន្តប្រាប់គាត់ "បន្តទៅមុខទៀត។" គាត់ចាប់ផ្តើមយល់។ ចប់សព្វគ្រប់ហើយ។ មើល ដោយសាតែមានព្រះវិញ្ញាណបរិសុទ្ធដែលណែនាំដល់ពួកយើងនូវគ្រប់កិច្ចការទាំងអស់នេះ។ ឃើញទេ ព្រះជាម្ចាស់ បានប្រទានផ្លូវមក។

72 តើអ្នកធ្លាប់...ធ្វើការកត់សម្គាល់ពីសត្វក្ងានព្រៃដើរឆ្លងកាត់ទេ? ទាដើរទៅទិស ខាងត្បូង? នឹកចាំពីកូនទាតូចមួយក្បាលដែលកើតនៅស្រះទឹកមួយនោះ។ វាអត់ ស្គាល់ ទិស កើត លិច ជើង ត្បូងទេ។ វាអត់ស្គាល់ទិសតំបន់អ្វីនោះទេ គឺវាស្គាល់តែស្រះទឹកមួយ នោះដែលនៅលើភ្នំមួយនៅក្នុងប្រទេសកាណាដា។ វាអត់ ដែលចេញពីស្រះទឹក នោះទេ ប៉ុន្តែវាកើតមកជាអ្នកដឹកនាំ។ ទាឈ្មោលមួយ

ក្បាលនោះបានកើតមកជាអ្នកដឹកនាំ។ ហើយដំបូងឡើយ នាយប់មួយ មានព្រិល ធ្លាក់នៅលើកំពូលភ្នំ។ តើមានអ្វីកើតឡើង? មានខ្យល់បក់មកត្រជាក់រំភើយ បក់មក។ ខ្ញុំអាចស្រមៃឃើញវាភ័យស្លុត និយាយថា "ម៉ាក់ មានរឿងអីនឹង?" ឃើញទេ វាមិនដែលធ្លាប់ឆ្លងកាត់អាកាសធាតុត្រជាក់បែបនោះពីមុនមក។វាចាប់ផ្តើមធ្វើការ កត់សម្គាល់នៅជុំវិញស្រះនោះចាប់ផ្តើមកក មានទឹកកកនៅក្នុងស្រះ។ វាអត់ដឹងទេ តែភ្លាមៗនោះ...វាកើតមកដើម្បីធ្វើការដឹកនាំដល់ហ្វូងទាដទៃទៀត។ វានឹង លោត ចូលទៅក្នុងកណ្តាលស្រះ នៅពេលដែលវាជួបសេចក្តីវេទនា។ អ្នកអាចហៅថាអ្វី ដែលអ្នកចង់ហៅ។ យើងហៅថាជាការបណ្តាល ឬអ្នកអាចហៅបាន អ្វីយ៉ាងណា ក៏ដោយវាគ្រាន់តែជាសភាវគតិ។ វានឹងហែលទៅកណ្តាលស្រះ ស្រែកទៅលើ អាកាសហើយហែលទៅមុខទៀត "ហុក ហុក ហុក ហុក!" ហើយសត្វទាទាំង អស់នៅក្នុងស្រះនោះនឹងទៅតាមវា។ ហេតុអ្វី? ពួកវាស្គាល់ អ្នកដឹកនាំវា ដូចជារបៀបដែល វាស្រែក។

73 "ប្រសិនជាមានសម្លេងត្រែ ដែលផ្លុំមិនច្បាស់ តើអ្នកណានឹងអាចត្រៀមខ្លួនសម្រាប់ ធ្វើសង្គ្រាមបាន?" ត្រូវហើយ។ តើអ្នកណាអាចត្រៀម ខ្លួនសម្រាប់ធ្វើសង្គ្រាម បានបើសិនជាសម្លេងត្រែនោះផ្លុំមិនច្បាស់?

74 ចុះបើសិនជាសត្វទានោះឲ្យសម្លេងមិនច្បាស់វិញ តើមានសត្វទាណាអាចត្រៀម ខ្លួនហោះបាន? សត្វទាតូចនោះស្រែកប្រកូកប្រកាស និងស្រែកថា "ហុក ហុក ហុក ហុក!" ហើយសត្វទាតូចៗទាំងអស់ហែលមករកវា។ "ហុក ហុក ហុក ហុក!" នោះពួកវា។ ហាក់បីដូចជាមានការប្រារព្ធពិធីអ្វីមួយដែលពួកវាមាន នៅកណ្តាលស្រះទឹកពួកវាវេទៅវេមក។ បន្ទាប់ពីមួយសន្ទុះក្រោយមកវាមាន អារម្មណ៍ថាត្រូវតែចាកចេញ។ ហើយវាចាប់ផ្តើមត្រដាងស្លាងតូចរបស់វាហោះចេញ ពីស្រះនោះ ហាក់ឡើងលើចុះឡើងប្រហែលជាបួនឬប្រាំដង ហើយក៏តំរង់ទៅ លូវីស្យ៊ីអាណា ដែលវាអាចទៅបាន សត្វទាទាំងអស់ហែលពីក្រោយវា។ "ហុក ហុក ហុក ហុក" វាមកហើយ។ ហេតុអ្វី? វាជាអ្នកនាំផ្លូវ! អាម៉ែន! សត្វទាវាស្គាល់ អ្នកនាំផ្លូវរបស់វា ក្រុមជំនុំវិញគឺអត់ទេ។ មែនហើយ វាដឹងថាវាធ្វើអ្វី។

75 មើលហ្វូងសត្វក្ងានចាស់ៗទាំងនោះពីខ្សែបន្ទាត់មកពីអាឡាស្កា។ ហើយមានក្ងានឈ្មោលដែលតែងតែនាំផ្លូវពួកវា ហ្វូងក្ងានទាំងនោះត្រូវតែសម្លឹងមើលទៅកាន់ក្ងានឈ្មោលនោះ។ ពួកវាត្រូវតែដឹងថាតើក្ងានឈ្មោលនោះនិយាយអំពីអ្វី។

តើអ្នកមានបានអានវានៅក្នុងទស្សនាវដ្ដី *លុក្ស* ទេ ប្រហែលជាបួនឆ្នាំមុនដែលក្ងានឈ្មោលចាស់មួយក្បាល នោះ មានពេលមួយវាអត់ដឹងថាវាកំពុងធ្វើអ្វីនោះទេហើយ វាបាននាំហ្វូងសត្វក្ងានធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសអង់គ្លេស? ត្រឹមត្រូវហើយ។ ពួកវាអត់ដែលស្គាល់ប្រទេសអង់គ្លេសពីមុនមកនោះទេ។ ហេតុអ្វី? ពួកវាមិនដែលកត់សម្គាល់ពីមេដឹកនាំរបស់ពួកវា—ពួកវាទេ។ ក្ងានឈ្មោលចាស់ មួយក្បាល នោះមិនដឹងថាវាកំពុងតែទៅណា។ ហើយឥឡូវវាទៅដល់ទីនោះហើយរកផ្លូវមក វិញមិនបាន។

76 វាសំខាន់ខ្លាំងណាស់សម្រាប់ហ្វូងក្ងានទាំងមូល សព្វថ្ងៃនេះ ពួកវានៅតែជាហ្វូង។ មានគេនិយាយថា នៅក្នុងទស្សនាវដ្ដី*លុក្ស* បាននិយាយថាក្ងានទាំងនោះនៅជាហ្វូង និងហើរពាសពេញប្រទេសអង់គ្លេស ប៉ុន្តែវាអត់ស្គាល់ផ្លូវត្រឡប់មកវិញ។ វាដូចជា *សត្វក្ងាន*ខ្លះដែលខ្ញុំធ្លាប់ស្គាល់។ អ្នករាល់គ្នាក៏មានហ្វូងដូចគ្នាហើយ ជា ការជួបជុំ ការពារគ្នាហើយមានអ្នកខ្លះមានការផុសផុលមកជាមួយ ព្រមទាំង មានអធិប្បាយ ខ្លះផងដែរ ប៉ុន្តែអ្នកមិនបានដឹងថាអ្នកកំពុងតែទៅណា នោះទេ។ នៅជាក្រុមវិលវល់ ពីព្រោះអ្នកមានក្ងានឈ្មោលនាំអ្នកចេញពីនិកាយជ្រុលនិយម ហើយមិនត្រឡប់ ទៅកាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ វិលត្រឡប់មកការជ្រមុជដោយព្រះវិញ្ញាណ។ ហើយបន្ទាប់មកទៀតយើងឆ្ងល់ថាមូលហេតុអ្វីបានជាមិន មាន ការផុសផុលនៅ ក្នុងសម័យកាលនេះ។ ឃើញទេ? អ្នកទទួលបានសំលេង ដ៏ច្បាស់នោះ! សំលេងនោះ គឺជាដំណឹងល្អដែលផ្លុំសម្លេងត្រែចេញ មកជាដំណឹងល្អគ្រប់ទាំងព្រះបន្ទូលរបស់ព្រះ ជាម្ចាស់។ មិនមែនជាគោលលទ្ធិសាសនាទេ មិនមែនជានិកាយ ប៉ុន្តែគឺជាព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធ។ "ទីសម្គាល់នឹងនៅ ជា មួយអស់អ្នកដែលជឿ។" ឃើញទេ? ហើយនៅទីនោះគេដើរតាមផ្លូវនោះហើយ។

77 ក្ងានឈ្មោលចាស់មួយក្បាល មានពេលមួយពួកគេនិយាយថា ហ្វូងក្ងាននោះត្រូវគេតាមសម្លាប់ហើយដេញវាឲ្យហើរទៅកន្លែងដែលងងឹត ដោយមិនដឹងថាខ្លួនកំពុងតែទៅណា ហើយពួកវាហើរបុកភ្នំនៅទីនោះ ដោយមានខ្លះបែកហ្វូង និងបែកខ្ញែក។ ប្រាកដហើយ! ពួកវាត្រូវស្គាល់សម្លេងច្បាស់លាស់មួយ។ ដូចជាទាតូចមួយក្បាលនោះដោយវាគ្រាន់តែបន្លឺសម្លេងច្បាស់លាស់ ហើយធ្វើឲ្យគ្រប់គ្នាស្គាល់

បាន ហើយពួកវាមានការជួបជុំជាហ្វូង ហើយបានធ្វើដំណើរទៅទិសខាងត្បូង។ តើពួកវាធ្វើដំណើរទៅទីនោះធ្វើអ្វី? តើទីនោះមិនត្រជាក់ពេកទេ។

78 ឥឡូវ ប្រសិនជាព្រះជាម្ចាស់បានប្រទានឲ្យសត្វទានោះមានវិចារណញ្ញាណគ្រប់គ្រាន់ដើម្បីដឹង ពីរបៀបគេចខ្លួនពីភាពត្រជាក់ ចុះតើព្រះអង្គគួរតែប្រទានឲ្យក្រុមជំនុំដោយរបៀបណា? ប្រសិនជាសត្វទានោះអាចធ្វើបានដោយសភាវគតិ ចុះចំណែកឯព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំវិញ? តើគួរតែនាំយើងចេញពី ភាពជ្រុលនិយម និងការកាន់តាមគោលលទ្ធិសាសនា និងអ្វីៗផ្សេងទៀតដោយនាំ ទៅកាន់ សេរីរុងរឿង ភាពឧត្តុង្គឧត្តម នៃការជ្រមុជនៅក្នុងព្រះវិញ្ញាណ។ នោះ ហើយគឺជាអ្នកនាំផ្លូវពិតប្រាកដដែលនឹងដឹកនាំព្រោះព្រះអង្គនឹងបញ្ចេញខ្យល់ដង្ហើមគ្មានអ្វីក្រៅពីដំណឹងល្អនោះទេ។ ប្រាកដណាស់ អ្នកត្រូវការអ្នកនាំផ្លូវ!

79 នៅពេលដែលអ្នកប្រាជ្ញ មិនស្គាល់អ្វីទាំងអស់ពីព្រះជាម្ចាស់។ ពួកគេ ជាអ្នក ធ្វើ—កិច្ចការដ៏អស្ចារ្យ ដូចជាអ្នកចេះវេទមន្ត។ ពួកគេបានធ្វើដំណើរឆ្ពោះទៅទិស បូព៌។ អ្នកដឹងទេ ព្រះគម្ពីរចែងថា "យើងបានឃើញផ្កាយរះនៅទិសខាងកើត ចូរ ទៅដើម្បីថ្វាយបង្គំព្រះអង្គ។" ពួកគេធ្វើដំណើរមកពីទិសខាងលិច ពួកគេបានសម្លឹងមើលទៅទិសខាងកើត បានឃើញផ្កាយរបស់ព្រះអង្គរះ...ឬក៏បានមើល ទៅទិសខាងលិច ដោយពួកគេនៅទិសខាងកើត។ យើងនៅទិសខាងកើត ហើយបានឃើញផ្កាយរបស់ព្រះអង្គនៅទិសខាងលិច។ ឃើញទេ? "យើងបាន ឃើញផ្កាយរបស់ព្រះអង្គនៅទិសខាងកើត។" ហើយ មើល ពួកគេនៅទិស ខាង កើត។ "នៅពេលដែលយើងនៅទិសខាងកើត យើងឃើញផ្កាយ ហើយយើងមក ដើម្បីនឹងថ្វាយបង្គំព្រះអង្គ។"

80 ខ្ញុំអាចស្រមៃឃើញពីអ្នកដើរតាមទាំងនោះ គឺត្រៀមខ្លួនជាស្រេចនឹងទៅ។ ខ្ញុំអាចស្រមៃឃើញប្រពន្ធរបស់ពួកគេណាម្នាក់និយាយទៅកាន់គាត់ និយាយថា "ឥវ៉ាន់បានរៀបចំសព្វគ្រប់ហើយ ចុះឯណាទៅត្រីវិស័យរបស់អ្នក?"

គាត់ឆ្លើយ "ខ្ញុំ—ខ្ញុំនឹងមិនប្រើត្រីវិស័យទេនៅពេលនេះ។"

81 និយាយថា "តើអ្នកនឹងឆ្លងកាត់ភ្នំដោយរបៀបណា?" ត្រូវចាំថាពួកគេត្រូវធ្វើដំណើរឆ្លងកាត់ទន្លេទីគ្រីសនិងចុះតាមដើមឈើ ហើយហេតុអ្វីបានជាពួកគេត្រូវធ្វើ

ដំណើរពីឆ្នាំដោយជិះសត្វអូដ។ តើពួកគេធ្វើបានដោយរបៀបណា? និយាយថា "ដោយមិនមានប្រើត្រីវិស័យអ្វីទេ។"

និយាយថា"អត់ទេ។"

"តើអ្នកធ្វើដំណើរទៅដោយរបៀបណា?"

82 "ខ្ញុំទៅ ព្រះជាម្ចាស់នឹងប្រទានផ្លូវ។ ផ្កាយឯនាយនោះនឹងដឹកនាំខ្ញុំទៅឯក្សត្រ នោះ។" គឺយ៉ាងនោះហើយ។

83 "យើងបានឃើញផ្កាយ ដែលរះនៅទិសខាងកើត និងដើរតាមផ្លូវពីទិសខាងលិច ដើម្បីថ្វាយបង្គំព្រះអង្គ។ តើព្រះអង្គគង់នៅឯណា?" ពួកគេដើរតាមផ្លូវដែលព្រះជាម្ចាស់ប្រទានឲ្យ។ ពួកគេបានចងជាប់ជាមួយនឹងជំនឿលទ្ធិសាសនាទីនោះអស់មួយរយៈ។ ពួកគេបានធ្វើដំណើរមកកាន់ទីក្រុងយេរ៉ូសាឡឹម ហើយចាប់ផ្តើមធ្វើដំណើរឡើងចុះ មនុស្សស្លៀកពាក់ស្អាតបាតទាំងនេះ និយាយថា "តើព្រះអង្គគង់នៅទីណា? តើព្រះអង្គដែលនឹងប្រសូត្រមកជាស្តេចជនជាតិយូដានៅឯណា?" ជាអ្នកគ្រប់គ្រង នៅទីក្រុងយេរ៉ូសាឡឹម។ ប្រាកដជាក្រុមជំនុំធំៗបានដឹងខ្លះៗអំពីដំណឹងនេះ។ "តើព្រះអង្គគង់នៅទីណា? តើឯណាទៅព្រះអង្គដែលប្រសូត្រមកជាស្តេចរបស់ជនជាតិយូដា? យើងបានឃើញផ្កាយរបស់ព្រះអង្គនៅទិសខាងកើត យើងមកដើម្បីនឹងថ្វាយបង្គំព្រះអង្គ។ ព្រះអង្គនៅឯណា?"

84 ហេតុអ្វី ពួកគេបានទៅរកគ្រូគង្វាល *ដូច្នេះ-និង-ដូច្នេះ* និងមហាបូជាចារ្យ *ដូច្នេះ-និង-ដូច្នេះ* អត់មានអ្នកណាដឹងពីហេតុការណ៍នោះទេ។ "ហេតុអ្វីមានស្តេចមួយអង្គប្រសូត្រពីជនជាតិយូដា ព្រះអង្គគង់នៅឯណា?" ពួកគេអត់ស្គាល់ទេ។

85 ប៉ុន្តែមានអ្នកគង្វាលចៀម នៅតាមជ្រលងភ្នំពួកគេគ្រាន់តែមានពេលមួយបាទ លោកម្ចាស់ ព្រះជាម្ចាស់ប្រទានមធ្យោបាយដល់ពួកគេ។

86 ហើយពួកគេស្នាក់នៅម្តុំនោះ មានសម្លេងផ្ទាល់មានបន្ទូល ទៅកាន់ពួកគេ "យើង នឹងប្រាប់ឯងនូវអ្វីដែលឯងត្រូវធ្វើ គឺត្រូវមានកិច្ចប្រជុំប្រឹក្សា។" ដូច្នេះពួកគេបានហៅក្រុមប្រឹក្សាជាន់ខ្ពស់សាន់ហេឌ្រីន និង—និង គិតមើលបើពួកគេបាន ឮដំណឹង អ្វីទៀត។ "ទេ យើងអត់មានបានដឹងពីដំណឹងនោះទេ។"

87 ដូចជាអ្វីដែលកើតឡើងនាពេលបច្ចុប្បន្ន។ ពួកគេអត់ស្គាល់ពីអ្នកនាំផ្លូវ ព្រះវិញ្ញាណ បរិសុទ្ធដែលធ្វើការប្រោសឲ្យជា ការចាក់បំពេញ ការសង្គ្រោះ ការយាង

មកម្តងទៀត។ អ្នកនាំផ្លូវប្រាប់យើងគ្រប់យ៉ាងនូវអ្វីដែលនឹងកើតឡើង យើងក៏នៅក្នុង កណ្តាលចំណោមពួកគេ។ ជាអ្នកជ្រាបដឹងពីចិត្តគំនិត ដែលពួកគេមិនដឹងពីអ្វី ទាល់តែសោះ ពួកគេហៅថាការជ្រាបដឹងពីគំនិត ឬអ្វីផ្សេងទៀត។ ពួកគេអត់ដឹងថាត្រូវនិយាយពីអ្វីអំពីកិច្ចការនោះ។

88 អញ្ចឹងអ្នកមើល អ្នកប្រាជ្ញទាំងនោះ...នៅចាំ នៅពេលដែលពួកគេចូលទៅក្នុងទីក្រុងយេរ៉ូសាឡឹម ផ្កាយនោះក៏បាត់។ ហើយបើអ្នកសម្លឹងរកអ្នកកាន់សាសនា និងអ្នកកាន់តាមនិកាយដើម្បី នាំអ្នកទៅរកព្រះជាម្ចាស់ នោះជំនួយរបស់ព្រះ ជាម្ចាស់ នឹងចាកចេញពីអ្នក។ ប៉ុន្តែនៅពេលដែលពួកគេឈឺ និងនឿយហត់ចំពោះកិច្ចការនោះ ហើយបែរចេញពីពួកគេ ចេញពីអ្នកកាន់សាសនា និងអ្នកកាន់តាមនិកាយ ពួក យូដាទាំងនោះ ហើយចាកចេញពីក្រុងយេរ៉ូសាឡឹម បន្ទាប់មកផ្កាយក៏ចាប់ផ្តើមរះម្តងទៀត ហើយពួកគេអរសប្បាយពោរពេញដោយអំណរ។ ពួកគេបាន ឃើញអ្នកនាំផ្លូវម្តងទៀត! អូ តើវាកើតឡើងដូចម្តេចទៅ ចេញពីព្រះវិហារចំណាស់ ធម្មតាដែលត្រជាក់ បន្ទាប់មកត្រឡប់ទៅរកកន្លែងមួយ ដែលឆេះឆួលឃើញ ទេ អ្នកនាំ ផ្លូវកំពុងតែដឹកនាំ តើអ្វីទៅជាភាពខុសប្លែក! មែនហើយ "យើងបាន ឃើញផ្កាយ របស់ព្រះអង្គនៅទិសខាងកើត ហើយធ្វើដំណើរមកដើម្បី ថ្វាយបង្គំព្រះអង្គ។"

89 លោកយ៉ូស្វេនិយាយទៅកាន់ពួកគេ "ឥឡូវអ្នកដើរតាម ហិបសម្ព័ន្ធមេត្រីពីព្រោះអ្នកទាំងអស់គ្នាមិនដែលឆ្លងកាត់ផ្លូវនេះពីមុនមក។" ព្រះជាម្ចាស់ នឹងមិនអនុញ្ញាតិឲ្យហិបសម្ព័ន្ធមេត្រីនោះទៅកន្លែងណាផ្សេងឡើយ តែតាមផ្លូវមួយដែលត្រឹមត្រូវ។ គ្រប់គ្នាបានដើរតាមហិបសម្ព័ន្ធមេត្រីនោះ ហើយបានឆ្លងកាត់ ទន្លេយ័រដាន់។

90 ដូចជាសព្វថ្ងៃ ដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ។ មែនហើយ។ យើងអាចដឹងបានថាកិច្ចការនោះមកពីព្រះវិញ្ញាណបរិសុទ្ធ ឬមិនមែន យើងឃើញតាមរយៈការសម្តែង...ឲ្យឃើញ ការសម្តែងឲ្យឃើញនោះបង្ហាញថាពិតជាត្រឹមត្រូវមែន តាមរយៈព្រះបន្ទូលរបស់ព្រះ។

91 ឥឡូវមិនជាយូរប៉ុន្មាន មានបងប្អូនមួយក្រុមមានទាំងឈាម និងប្រេង ហើយវាមិនជាថ្មីទេបើសិនជាគេចង់ធ្វើតាមរបៀបនោះ។ ខ្ញុំ...មិនបានបង្ហាញថា វាពិតជា

ត្រឹមត្រូវទេចំពោះខ្ញុំទេ។ ក្នុងបទគម្ពីរអាចបញ្ជាក់ថាវាត្រឹមត្រូវឬអត់ មើល ដរាបណាវាស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះមិនមានអ្វីខុសទាស់ទេ។ ពួកគេនិយាយ "នេះជាមូលហេតុដែលអ្នកទទួលបានព្រះវិញ្ញាណបរិសុទ្ធ អ្នកមានប្រេងនៅក្នុងដៃ។" ឥឡូវខ្ញុំ—ខ្ញុំមិនយល់ស្របទេ។ ឃើញទេ? ទេ ខ្ញុំមិនជឿថាប្រេងនោះអាចធ្វើអ្វីបាននោះទេ។ ហើយប្រសិនជាឈាមនោះអាចព្យាបាល និងផ្តល់សេចក្តីសង្គ្រោះមែន ចុះចំណែកព្រះលោហិតព្រះយេស៊ូវិញមានអ្វីកើតឡើង? ប្រសិនជាប្រេងនោះ អាចព្យាបាលបានមែនចុះ ចំណែកស្នាមរបួសរបស់ព្រះអង្គវិញ? មើល? ឃើញទេ?

92 ខ្ញុំចូលចិត្តឲ្យមានអ្នកនាំផ្លូវមក ដើម្បីនាំអ្នកទៅកាន់សេចក្តីពិតនៃ ព្រះបន្ទូល បន្ទាប់មកអ្នកដឹងថាអ្នកគឺសូន្យហើយត្រៀមខ្លួនសំរាប់ការរាប់ ថយ ក្រោយ។ វាត្រឹមត្រូវហើយ ត្រៀមខ្លួនដើម្បីហោះចេញ។ មែនហើយ ដោយសារ មូលហេតុអ្វីទៅ? មានតែអ្នកនាំផ្លូវប៉ុណ្ណោះទេដែលអាចធ្វើវឲ្យក្លាយទៅជាការពិត។

93 ខ្ញុំមានបទគម្ពីរនៅទីនេះ ខ្ញុំបានបទគម្ពីរទាំងនេះ ប៉ុន្តែខ្ញុំចង់អានមួយនេះ។ គឺនៅពេត្រុសទីពីរ ជំពូក១ ខ២១។

*ដ្បិត...ព្រះបន្ទូលដែលព្យាការីបានថ្លែងទុកមកនោះ មិនមែនចេញពីបំណងចិត្តរបស់មនុស្សទេ គឺព្រះវិញ្ញាណបរិសុទ្ធវិញឯណោះដែលជំរុញ ចិត្ត លោក ទាំង នោះ អោយ ថ្លែង ព្រះបន្ទូល ក្នុង ព្រះនាម ព្រះជាម្ចាស់។*

94 តើទំនាយថ្លែងមកដោយរបៀបណា? មិនមែនចេញពីបំណងចិត្តរបស់មនុស្សនិកាយលទ្ធិសាសនា ទេ ប៉ុន្តែដោយបំណងព្រះហឫទ័យរបស់ព្រះជា ម្ចាស់ នៅពេលដែលពួកបរិសុទ្ធបានធ្វើចលនាដោយព្រះវិញ្ញាណបរិសុទ្ធ។ គាត់តែង តែជា អ្នកនាំផ្លូវរបស់ព្រះជាម្ចាស់។ គឺព្រះវិញ្ញាណនោះឯង ជាសរសរភ្លើង ជាព្រះវិញ្ញាណបរិសុទ្ធ មានអ្នកណាស្គាល់ថាជាព្រះគ្រីស្ទ។ លោកម៉ូសេបាន ចាកចេញពីប្រទេសអេស៊ីប គឺជាអង្គព្រះគ្រីស្ទ ដែលប្រសើរជាងអេស៊ីប។ គឺព្រះគ្រីស្ទតែមួយអង្គ។ បាទ នៅពេលដែល ពួកគេ ឈរនៅទីនោះហើយនិយាយថា "អ្នកថាជាអ្នក...ហេតុអ្វី អាយុរបស់អ្នក មិនលើស ៥០ឆ្នាំផង ហើយអ្នកនិយាយ ថាអ្នកបានឃើញលោកអាប្រាហាំ?"

95 ទ្រង់ មានបន្ទូលថា "មុនលោកអាប្រាហាំ **គឺជាខ្ញុំ។" ខ្ញុំជាម្នាក់**ដែលបានជួប លោកម៉ូសេនៅគុម្ពបន្លាដែលឆេះនោះ។ មែនហើយ។ ព្រះអង្គគឺជាព្រះ ជា ម្ចាស់ ដែល ជាសាច់ឈាម។ មិនមែនជាមនុស្សទីបីទេ គឺជាបុគ្គល ដដែល ដែលនៅ ក្នុងមុខងារផ្សេងគ្នា។ មិនមែនជាព្រះបីអង្គទេ គឺមុខងារចំនួនបីរបស់ព្រះមួយអង្គ។ ត្រឹមត្រូវហើយ។

96 ឥឡូវចូលដល់បទគម្ពីរ។ នៅពេលដែលព្រះអង្គផ្គត់ផ្គង់គឺព្រះអង្គតែងតែ ផ្តល់ឲ្យនូវអ្វីដែលល្អបំផុត។ នៅពេលដែលព្រះជាម្ចាស់ប្រទានមធ្យោបាយ ដើម្បីការពារ ក្រុមជំនុំរបស់ព្រះអង្គគឺ ទ្រង់តែងតែផ្តល់នូវមធ្យោបាយដែលល្អបំផុត។ នៅ ពេលដែលព្រះអង្គឲ្យអ័ដាំ និងអេវ៉ា នៅក្នុងសួនច្បារអេដែនអ្វីដែលព្រះអង្គឲ្យដល់ ពួកគេ គឺព្រះបន្ទូល។ "អ្នកនៅជាប់ពីក្រោយនឹងពាក្យនេះ ហើយអ្នកនឹង បាន រួច។ ប៉ុន្តែប្រសិនជាអ្នកបែរចេញពីវា នៅថ្ងៃដែលអ្នកបរិភោគផ្លែនោះ ជាថ្ងៃដែលអ្នកត្រូវ ស្លាប់។" ព្រះជាម្ចាស់មិនដែលផ្លាស់ប្តូរនូវយុទ្ធសាស្ត្ររបស់ព្រះអង្គទេ។ ហើយសាតាំង វាក៏មិនដែលផ្លាស់ប្តូរនូវយុទ្ធសាស្ត្ររបស់វាដែរ តើយុទ្ធសាស្ត្រនោះ ចូល ទៅ កាន់អ័ដាំ និង អេវ៉ាដោយរបៀបណា នៅពេលបច្ចុប្បន្ននេះ។ មូលហេតុអ្វី? ដោយព្យាយាមលើកយកហេតុផលមក។"ឥឡូវនេះគឺវាសមហេតុផលដែលព្រះជា ម្ចាស់ មិនអនុញ្ញាតិ។ អូ ព្រះជាម្ចាស់ពិតមានបន្ទូលថាអញ្ចឹងមែន"សាតាំងនិយាយ"ប៉ុន្តែ ប្រាកដណាស់ព្រះជាម្ចាស់ព្រះអង្គបរិសុទ្ធព្រះអង្គមិនធ្វើបែបនោះទេ។"ពិត ប្រាកដ មែនគឺព្រះអង្គនឹងធ្វើព្រោះព្រះអង្គបានមានបន្ទូលហើយ!

97 ហើយនេះជាអ្វីដែលមនុស្សនិយាយនាពេលបច្ចុប្បន្ននេះ "អូ ឥឡូវចាំសិន! អ្នកអត់ជឿទេឥឡូវ ប្រសិនជាខ្ញុំទៅព្រះវិហារ ហើយខ្ញុំដាក់ដង្វាយមួយភាគដប់ ហើយខ្ញុំធ្វើ*អញ្ចឹង* អ្នក*ដទៃទៀត* តើព្រះជាម្ចាស់នឹងបណ្តេញខ្ញុំចេញពីទីនោះ?" ទាល់តែមនុស្សម្នាក់បានកើតជាថ្មី បើមិនដូច្នេះទេនោះគាត់នឹងមិនយល់ពីព្រះរាជ្យ របស់ ព្រះជាម្ចាស់ឡើយ! ឃើញទេ? គឺមិនអាចដោះសាបានទេ! "អញ្ចឹង មនុស្សប្រុស ចំណាស់គួរឱ្យអាណិតម្នាក់និងមនុស្សស្រីចំណាស់ ដែលគួរ ឱ្យ អាណិត គឺ មានព្រលឹង ពួកមនុស្សចាស់ដែលល្អ។" មានរបៀបតែមួយដែលពួកគេអាចឃើញ ព្រះជាម្ចាស់បាន គឺជាការកើតជាថ្មីម្តងទៀត។ ខ្ញុំមិន ខ្វល់ថាអ្នកតូច ទាប ប៉ុណ្ណា ចាស់ ប៉ុណ្ណា ក្មេងប៉ុណ្ណា ពួកគេបាន ធ្វើ អ្វីខ្លះគេបានទៅព្រះវិហារច្រើន ប៉ុណ្ណា គេ អាច សូត្រពីគោលជំនឿ សាវកបាន ច្រើនប៉ុណ្ណានោះទេ។ គឺអ្នកត្រូវតែ បានកើត

ជាថ្មី ឬអ្នកមិនចាំបាច់ មានមូលដ្ឋានគ្រឹះដើម្បីចាប់ផ្តើមនោះទេ។ វាជាការត្រឹមត្រូវណាស់។

98 ដូច្នេះអ្នកឃើញហើយថាអ្នកត្រូវការអ្នកនាំផ្លូវ។ ព្រះអង្គនឹងនាំផ្លូវអ្នកទៅកាន់សេចក្តីពិត ហើយសេចក្តីពិតនោះគឺជាព្រះបន្ទូល។ ព្រះអង្គនឹងនាំផ្លូវអ្នក។ ហើយព្រះ អង្គ នឹងនាំផ្លូវអ្នកជានិច្ច។ ព្រះជាម្ចាស់មិនដែលប្រែប្រួល ព្រោះព្រះអង្គ គ្មានដែនកំណត់ ហើយព្រះអង្គជ្រាបនូវអ្វីដែលល្អប្រសើរបំផុត។ ព្រះអង្គជាព្រះគង់ នៅគ្រប់ទីកន្លែងក្នុងពេលតែមួយ និងសព្វញ្ញូញាណ ព្រះអង្គ—ព្រះអង្គជាគ្រប់យ៉ាង។ វា ត្រឹម ត្រូវមែន ហើយដែលព្រះអង្គមានលក្ខណៈបែបនោះ គឺព្រះអង្គមិនមានការប្រែប្រួលអ្វីទាំងអស់។ ត្រូវហើយ។

99 ព្រះអង្គច្បាស់លាស់នៅក្នុងផ្លូវដែលព្រះអង្គដឹកនាំអ្នក។ ព្រះវិញ្ញាណបរិសុទ្ធជាអ្នកនាំផ្លូវ គឺព្រះអង្គទៀងត្រង់ដូចគ្នាទៅនឹងព្រះបន្ទូលដែលព្រះអង្គបង្រៀន។ ឥឡូវនេះ លូកា ត្រូវបានដឹកនាំដោយអ្នកនាំផ្លូវ ដោយព្រះអង្គមានបន្ទូលថា "ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោក ហើយប្រកាសដំណឹងល្អដល់មនុស្សទាំងអស់។ ហើយអស់អ្នកដែលជឿ និងទទួលពិធីជ្រមុជទឹក នឹងបានសង្គ្រោះ តែអស់អ្នកដែលមិនជឿនោះនឹងត្រូវមានទោស។ អស់អ្នកដែលជឿនឹងធ្វើទីសំគាល់ទាំងនេះ គឺគេនឹងដេញអារក្សក្នុងនាមខ្ញុំ ពួកគេនឹងដេញវិញ្ញាណអាក្រក់ និយាយភាសាដទៃ លើកពស់ឡើង ផឹកអ្វីដែលមានជាតិពុល ប្រសិនបើគេដាក់ដៃលើអ្នកជំងឺអ្នកជំងឺនឹងបានជាសះស្បើយ។" ហើយព្រះគម្ពីរសម្តែងថា "ពួកគេនឹងចេញទៅ គ្រប់ទិ ស ទី" ដឹកនាំដោយអ្នកនាំផ្លូវអ្នកដឹង "ប្រកាស ព្រះបន្ទូលដោយមានទី សម្គាល់ដែលមកជាមួយ។" តើវាជាអ្វីទៅ? អ្នកនាំផ្លូវបានបង្ហាញថានោះជាការពិត!

100 នេះជាគោលការណ៍របស់ព្រះជាម្ចាស់។ នេះជារបៀបដែលបានដាក់ចុះមក។ នោះជាកម្មវិធីរបស់ព្រះអង្គព្រះអង្គមិនបែរចេញពីគោលការណ៍របស់ព្រះអង្គឡើយពីព្រោះព្រះអង្គគឺគ្មានដែនកំណត់។ អាម៉ែន។ ព្រះអង្គមិនប្រែប្រួលទេ ទ្រង់ជាព្រះ។ ខ្ញុំអាចប្រែប្រួល ខ្ញុំជាមនុស្ស។ អ្នកអាចប្រែប្រួល អ្នកជាមនុស្សប្រុសស្រី។ ប៉ុន្តែព្រះជាម្ចាស់មិនប្រែប្រួលនោះទេ។ ខ្ញុំមានដែនកំណត់ ខ្ញុំអាចធ្វើខុស និងនិយាយអ្វីដែលខុស គឺពួកយើងទាំងអស់គ្នា។ ប៉ុន្តែព្រះជាម្ចាស់មិនអាចទេ ហើយព្រះអង្គជាព្រះ។ ការសម្រេចព្រះឫទ័យដំបូងរបស់ព្រះអង្គគឺគ្រប់លក្ខណ៍។ របៀប ដែលព្រះអង្គ សម្តែងចេញ ដើម្បីជួយមនុស្សមានបាប ជារបៀបដែលព្រះអង្គ ត្រូវ ធ្វើ

គ្រប់ពេល វេលា។ ប្រសិនជាព្រះអង្គត្រូវបានត្រាស់ហៅដើម្បីសង្គ្រោះមនុស្សមានបាប គឺព្រះអង្គសង្គ្រោះដោយផ្អែកលើគោលការចម្បងមួយ។ ពេលក្រោយមនុស្សមានបាបចូលមកគឺព្រះអង្គធ្វើតាមរបៀបដដែលឬ ព្រះអង្គធ្វើខុសពីអ្វីដែលព្រះអង្គបានធ្វើ ពីលើកដំបូង។ អាម៉ែន។ ខ្ញុំស្រឡាញ់ព្រះអង្គ។ ខ្ញុំស្គាល់សេចក្ដីពិត។

101 ខ្ញុំមានវ័យហាសិបបីឆ្នាំ ជាគ្រូអធិប្បាយដំណឹងល្អនៅទីនេះអស់រយៈពេលសាមសិបបីឆ្នាំកន្លះ ខ្ញុំមិនដែលឃើញនូវភាពខុសឆ្គង។ ខ្ញុំធ្លាប់ឃើញមានការសាកល្បងប្រាំពីរដងនៅជុំវិញពិភពលោក នៅគ្រប់សាសនាទាំងអស់ និងគ្រប់ទីកន្លែងផ្សេងទៀត ពីមុនមានចំនួនកន្លះលានក្នុងមួយលើកៗ ហើយមិនដែលធ្លាក់ចុះឡើយ។ ខ្ញុំមិននិយាយចេញពីសៀវភៅណានោះទេ គឺខ្ញុំនិយាយចេញពីបទពិសោធន៍។ ដោយខ្ញុំដឹងថាព្រះជាម្ចាស់ឈរនៅ ពីក្រោយព្រះប ន្ទូលរបស់ព្រះអង្គ និងលើកតម្កើង។ ឥឡូវប្រសិនជាអ្នកមានកាន់តាមគោលលទ្ធិសាសនា អ្នកគួរតែប្រយ័ត្ន។ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធនឹងគាំទ្រព្រះបន្ទូលរបស់ព្រះជាម្ចាស់។

102 នៅក្នុងគម្ពីរពួកបរិសុទ្ធយូហាន នៅក្នុងជំពូកដំបូង ដោយថែងថា "ព្រះអង្គគឺជាព្រះបន្ទូល។ ព្រះអង្គជាអ្នកនាំផ្លូវ។ កាលដើមដំបូងមានព្រះបន្ទូលព្រះបន្ទូលក៏គង់នៅជាមួយព្រះ។ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ហើយ ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម និងបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា។" ពិតមែនហើយ !

103 ពេត្រុសត្រូវបានដឹកនាំឲ្យនិយាយ នៅក្នុងកិច្ចការ ២:៣៨ ពីរបៀបដែល ត្រូវទទួលព្រះវិញ្ញាណបរិសុទ្ធ គាត់បានមានប្រសាសន៍ថា "សូម បង ប្អូន កែ ប្រែ ចិត្តគំនិត ហើយម្នាក់ៗត្រូវទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទដើម្បីព្រះជាម្ចាស់លើកលែងទោសបងប្អូនអោយរួចពីបាប ហើយព្រះនាំផ្លូវនឹងដឹកនាំអ្នកចាប់តាំងពីពេលនោះតទៅ។" មែនហើយ នោះគឺអ្វីដែលត្រូវធ្វើ។ ដំបូង គឺប្រែចិត្តពីអំពើបាបចេញពីការដែលអ្នកមិនជឿ ដែលអ្នកធ្លាប់មិនជឿអ្វីទាំងនេះ។ ចូរ ប្រែចិត្ត បន្ទាប់មកទទួលពិធីជ្រមុជទឹក ហើយបន្ទាប់មកអ្នកនាំផ្លូវនឹងទទួលអ្នកចាប់ផ្ដើមពីទីនោះមក។ ឃើញទេ នោះហើយ ជាតួ នាទីរបស់អ្នក។ គឺតួនាទីនៅ ក្នុងការ ប្រែចិត្ត។ ជាតួនាទីរបស់អ្នកក្នុងការទទួលពីធីជ្រមុជទឹក ។ បន្ទាប់មកតួ នាទីរបស់អ្នកនាំផ្លូវគឺយកអ្នកពីទីនោះ ដឹកនាំអ្នកពីគុណធម៌ ទៅដល់ចំណេះដឹង ដើម្បីអ្នក ចេះទ្រាំទ្រ អត់ធ្មត់ ភាពកោតខ្លាចព្រះ និងស្រឡាញ់ដល់បងប្អូន ហើយព្រះវិញ្ញាណ បរិសុទ្ធដៅសញ្ញាសម្គាល់។ ឃើញទេ? ហើយពេញ ទៅដោយភាព ខ្ពង់

ខ្ពស់របស់ព្រះជាម្ចាស់ កូនប្រុសកូនស្រីរបស់ព្រះជាម្ចាស់ មានយុថ្កាជាផ្លូវនៅក្នុងព្រះគ្រីស្ទ។ ខ្ញុំស្រឡាញ់ ជាយុថ្កាក្នុងព្រះគ្រីស្ទ។

104 មែនហើយលោកព្រាត្រុសត្រូវបានព្រះវិញ្ញាណដឹកនាំ ដើម្បីសរសេរកណ្ឌគម្ពីរម៉ាកុស ជំពូកទី១៦ ពិតប្រាកដណាស់។

105 លោកយ៉ូហានបានដឹកនាំឲ្យសរសេរកណ្ឌគម្ពីរ វិវរណៈ។ គាត់ត្រូវបានអ្នកនាំផ្លូវនាំដឹកនាំ។ គាត់គឺត្រូវបាននាំដោយអ្នកនាំផ្លូវមានប្រសាសន៍ថា "ហើយប្រសិនបើមាននរណាម្នាក់ដកហូត ឬបន្ថែមសេចក្តីណាមួយពីព្រះបន្ទូល ដែលមានថ្លែងទុកក្នុងសៀវភៅនេះ ព្រះជាម្ចាស់ក៏នឹងដកហូតចំណែករបស់អ្នកចេញពីក្នុងសៀវភៅជីវិតដែរ។"

106 ឥឡូវ តើអ្នកនឹងជំនួសអ្វីផ្សេងទៀតទៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀប ណា ហើយអ្នកនៅតែនិយាយថាអ្នកដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធឬ? មិនយល់ទេមែនទេ? ទេ លោក។ វាមិនអាចទេ។

107 ព្រះអង្គគឺជាអ្នកនាំផ្លូវខ្ញុំពេញមួយជីវិត។ ព្រះអង្គនាំខ្ញុំទៅកាន់ជីវិត។ ទ្រង់ជាមួយអង្គដែលនាំខ្ញុំទៅកាន់ជីវិត ហើយព្រះអង្គគឺជាជីវិតរបស់ខ្ញុំ។ បើគ្មានព្រះអង្គខ្ញុំក៏ គ្មានជីវិតដែរ។ ក្រៅពីទ្រង់ខ្ញុំមិនចង់បានអ្វីផ្សេងទៀត ឡើយ។ ព្រះអង្គ គឺអ្វី ៗ–គ្រប់–យ៉ាងសំរាប់ខ្ញុំ។ នៅក្នុងគ្រាមានទុក្ខលំបាកព្រះអង្គគង់នៅក្បែរខ្ញុំ។ ម្សិលមិញ ព្រះអង្គបានប្រទានពរខ្ញុំ ថ្ងៃនេះក៏ដូចគ្នា។ តើខ្ញុំអាចរំពឹងអ្វី? គឺមិនប្រែប្រួលរហូត ដល់អស់កល្បជានិច្ច សរសើរព្រះនាមទ្រង់! អាម៉ែន។ មែនហើយ។ ព្រះអង្គមានបន្ទូលសន្យា។ ហើយព្រះអង្គនឹងធ្វើ។ ព្រះអង្គជាជីវិតខ្ញុំ ព្រះអង្គជាអ្នកដឹកនាំខ្ញុំ គឺលើស–ទាំងអស់។ ខ្ញុំទុកចិត្តព្រះអង្គ។ ខ្ញុំបានជួបនឹងការល្បួងលរ ជាច្រើន។ ខ្ញុំទុកចិត្តទ្រង់ទោះខ្ញុំទៅទីណាក៏ដោយ។ ខ្ញុំចង់ឱ្យអ្នកធ្វើវា។ ប្រសិនបើ អ្នក ទៅសម្អាត ស្ត្រីទាំងឡាយអើយ ទុកចិត្តព្រះអង្គ។ បើអ្នកទៅតាមទីប្រជុំជន ទុកចិត្តព្រះអង្គ។

108 មានពេលមួយដែលខ្ញុំគិតថាខ្ញុំជាអ្នកដែលពូកែដើរក្នុងព្រៃ អ្នកដឹងទេ ដោយការ បរបាញ់ច្រើនពេក។ ខ្ញុំគិតថា "ខ្ញុំជាអ្នកដែលមិនថ្លោះធ្លោយឡើយគ្មានអ្នកណា ធ្វើឲ្យ...ខ្ញុំវង្វេងបានទេ។ ម្តាយរបស់ខ្ញុំជាស្ត្រីកូនកាត់ឥណ្ឌា ហើយខ្ញុំចូល

ចិត្ត អញ្ចឹង។អូខ្ញុំអើយ! អ្នកមិនបាត់ខ្ញុំនៅក្នុងព្រៃទេខ្ញុំដឹងថាខ្ញុំកំពុងតែនៅកន្លែងណា។”

109 បន្ទាប់ពីរាត្រីទឹកឃ្មុំ ខ្ញុំបានបញ្ឆោតលេង ជាមួយភរិយារបស់ខ្ញុំដោយប្រាប់នាងថា “អូនដឹងទេ វាជាការល្អសម្រាប់យើងដែលត្រូវរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃ ទីម្ភៃបី។” ព្រោះវាជាពេលដែលព្រះជាម្ចាស់បានមានបន្ទូលប្រាប់បងឲ្យធ្វើ។

110 ហើយខ្ញុំបានគិតថា “ឥឡូវ សំរាប់រាត្រីទឹកឃ្មុំ ខ្ញុំបានសន្សំសំចៃលុយ ហើយខ្ញុំ នឹងនាំនាងទៅលេងនៅ នីអាការ៉ា នៅរដូវស្លឹកឈើជ្រុះវិញ ហើយឆ្លងទៅ អាឌីរ៉ុន ដែក ហើយនឹងធ្វើការបរបាញ់សត្វបានខ្លះ។” ឃើញទេ? ហើយខ្ញុំបាន យកនាង ទៅជាមួយ និងប៊ីលលីដែរ។ ប៊ីលលីនៅក្មេងនៅឡើយ។ ហើយខ្ញុំបាន នាំនាងទៅ សំរាប់រាត្រីទឹកឃ្មុំហើយជាដំណើរកំសាន្តបរបាញ់សត្វដែរអ្នកដឹងហើយ។ ដូច្នេះ—ដូច្នេះខ្ញុំបានគិតថាវា ជារឿងដែលល្អដែលត្រូវធ្វើ។ ហើយខ្ញុំក៏បាន នាំនាងទៅហើយក៏...

111 ខ្ញុំបានសរសេរសំបុត្រ ទៅកាន់លោក ដេនថុនជាអ្នក នៅភូមិភាគនោះ។ ហើយក៏បានធ្វើដំណើរទៅ នៅលើភ្នំ ហ៍រីខេន។ ហើយខ្ញុំបាននិយាយថា “លោកដេនថុន ខ្ញុំកំពុងធ្វើដំណើរឡើងមកហើយ ខ្ញុំចង់បរបាញ់សត្វខ្លាឃ្មុំ ខ្លះនៅ ទីនេះជាមួយនឹង លោកនៅរដូវស្លឹកឈើជ្រុះនេះ។”

112 ហើយគាត់និយាយថា “បានប៊ីលលីធ្វើដំណើរមក។” ដូច្នេះគាត់បាន និយាយថា “ខ្ញុំនឹងធ្វើដំណើរទៅតាម*កាលបរិច្ឆេទកំណត់*”។ អញ្ចឹង ប្រពន្ធខ្ញុំ និងខ្ញុំ នឹងទៅដល់ទី នោះ មុនមួយថ្ងៃ ជាមួយប៊ីលលី ហើយក៏បានចាក់សោផ្ទះ។ មានរាងទ្រេតបន្តិចទៅនឹងដើមឈើ។

113 ជាកន្លែងដែល លោក ហ្វ្រេដ សុថ្សមេន ហើយនឹងខ្ញុំបានទៅហើយ ឈរនៅទីនោះមិនយូប៉ុន្មាន។ ព្រះវិញ្ញាណបរិសុទ្ធ ខ្ញុំបានឃើញគាត់ឈរនៅទីនោះ មានភ្លើងពណ៌លឿងហោះជុំវិញគុម្ពព្រៃហើយហ្វ្រេដឈរនៅទីនោះ។ គាត់បាននិយាយថា “មកក្បែរនេះ ខ្ញុំចង់និយាយទៅកាន់អ្នក។ សំរាប់ថ្ងៃស្អែក” គាត់និយាយ “ចូរប្រយ័ត្នមានគេដាក់អន្ទាក់។”និយាយថា “ត្រូវតែប្រុងប្រយ័ត្នជានិច្ច!” ពិតមែនអត់ បងហ្វ្រេដ? ហើយខ្ញុំបានចេញទៅប្រាប់មនុស្សរាប់រយអ្នកនៅយប់នោះ ពាស ពេញវីម៉ុន ខ្ញុំនិយាយថា “មានអន្ទាក់ ខ្ញុំចង់ឃើញវា។ ខ្ញុំអត់ដឹងថាវានៅកន្លែង ណា

ខ្លះទេ។"ហើយពេលដែលយប់ស្អែកចូលមកដល់ខ្ញុំក៏ឃើញថាមានមែន។ និយាយថា "នេះគឺជាអន្ទាក់ដែលគេបានដាក់។" មែនហើយ។ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំ ខ្ញុំឲ្យ ធ្វើអ្វីដែលត្រូវធ្វើ។ ហើយអូ្ហ ពិតប្រាកដណាស់! អូ្ហ អ្នកទាំង អស់ គ្នាភាគច្រើនដឹង។ ខ្ញុំក៏គ្មានពេលវេលាដើម្បីប្រាប់ដែរ។

114 ប៉ុន្តែនៅពេលដែលខ្ញុំឈរនៅកន្លែងនោះ ខ្ញុំក៏មានអារម្មណ៍ថាត្រជាក់ នៅថ្ងៃនោះ។ លោកដេនថុន បានធ្វើដំណើរមកដល់នៅថ្ងៃបន្ទាប់ ខ្ញុំបាននិយាយថា "អូនដឹងទេវាជាការដែលល្អណាស់បើសិនជាបងបរ—បាញ់បានសត្វព្រៃយកទៅផ្ទះវិញ។" ខ្ញុំនិយាយថា "យើងបានធ្វើវា...ហើយយើងបានសន្សំសំចៃថវិកា ដោយយើង ទើបតែរៀបអាពាហ៍ពិពាហ៍រួច។" ហើយខ្ញុំនិយាយ "យើងអាចមាន សាច់ត្រៀមសម្រាប់រដូវធ្លាក់ទឹកកក ប្រសិនជាបងបរបាញ់បានសត្វនៅថ្ងៃនេះ។"

115 ហើយភរិយារបស់ខ្ញុំឆ្លើយ "អញ្ចឹងបងទៅៗ ប៊ីលលី។" និយាយទៀត "ឥឡូវបងចាំបានទេថា ខ្ញុំមិនដែលនៅក្នុងព្រៃនេះពីមុនមកទេ។" នាងនិយាយ គឺនាង នៅប្រហែលជាម្ភៃប្រាំម៉ាយលើភ្នំ អ្នកដឹងទេ នាងនិយាយ។ "ខ្ញុំអត់ស្គាល់ អ្វីទាំង អស់នៅកន្លែងនេះ។" ហើយនាងនិយាយ "ដូច្នេះខ្ញុំ..."

116 ខ្ញុំបាននិយាយ "ហ្នឹងហើយអូនមានចាំ បានទេកាលពីពីរឆ្នាំមុន បងបានសម្លាប់សត្វខ្លាឃ្មុំបីនោះ។ គឺនៅលើកំពូលភ្នំម្ដុំនោះ។" ហើយខ្ញុំនិយាយថា "ឥឡូវបងនឹងទៅបាញ់យកសត្វព្រៃ ហើយយើងនឹងបានសត្វខ្លាឃ្មុំខ្លះ" ហើយខ្ញុំបន្តនិយាយ "យើងនឹងមានសាច់សម្រាប់រដូវធ្លាក់ទឹកកក។" ស្ដាប់ទៅដូចជាល្អម្យ៉ាងដែរ។ (យើងបានបេះផ្លែ ប្លេកប៊ើរី និង យកធ្យូងទៅជាមួយ សំរាប់—រដូវត្រជាក់ ហើយបន្ទាប់មកប៊ីលលីបានលក់ផ្លែនោះ ហើយខ្ញុំនិងមេដាបានបេះវាទុកពីល្ងាចបន្ទាប់ពីចាក់សាំងរួច។) បន្ទាប់មកខ្ញុំ—ខ្ញុំនិយាយ "បងនឹងទៅយកកាំភ្លើងរបស់បង ហើយនឹងចុះនៅទីនោះ។" ខ្ញុំនិយាយ "មានក្ដាន់ច្រើននៅទីនេះ ខ្ញុំនឹងរកមើលមួយ។" ហើយខ្ញុំបាននិយាយ "អូនដឹងទេ" ខ្ញុំនិយាយ "បងនឹងរកវាបាន។" ហើយខ្ញុំនិយាយ "យើងនឹង...បរបាញ់ពួកវាបន្តិចទៀត។"

នាងឆ្លើយថា "យល់ព្រម។"

117 ដូច្នេះពេលដែលខ្ញុំចាប់ផ្ដើមចេញទៅ វាហាក់បីដូចជាមិនស្ងួវស្រួល។ ហើយពួកយើងមួយចំនួនជាអ្នក ញ៉ូវ ហាំផ្សៀ ហើយឡើងមកក្នុងទឹកដី ញ៉ូវ អ៊ីងគ្លែន យល់

អ្វីដែលខ្ញុំនិយាយទេ គឺនៅពេលដែលមានអ័ព្ទចុះ ឬ នៅលើភ្នំគ្រប់កន្លែង អ្នកនឹងមិនដឹងថា ខ្លួនឯងកំពុងតែនៅកន្លែងណានោះទេ។ គឺទាំងអស់នេះឯង។ អ្នកមិនអាចឃើញ ដៃរបស់អ្នកបោះទៅមុខ។ ហើយខ្ញុំចាប់ផ្ដើមដើរចុះក្រោម—ដោយមានការប៉ះពារខ្លះៗ ដូចជា កំពុងតែធ្វើដំណើរឡើងចុះៗ។ ហើយខ្ញុំចាប់ផ្ដើម នឹកឃើញពីខ្លារខិន ដែលអ្នកនៅម្ដុំនេះគេថាសំបូរណាស់នៅតំបន់នេះ។ នៅ ប៉ែក ខាង លិច យើង ហៅ វាថា ខ្លារខិន។ ហើយគេហៅថាជាតោភ្នំ។ វាទាំងអស់ សុទ្ធ តែនៅក្នុងប្រភេទអំបូរសត្វតែមួយ។ វាជា ពូម៉ា តើវាជាស្ទើឲ្យប្រាកដ។ ដូចជាឆ្មា កំពស់ប្រវែងប្រាំបួនហ្វុត ទំងន់ប្រហែល មួយរយហាសិប ទៅពីររយផោន។ វាបាន ឆ្លងកាត់ផ្លូវ ហើយខ្ញុំបាន ទាញកាំភ្លើង របស់ខ្ញុំចេញមកយ៉ាងលឿន តែមិនលឿនល្មមអាចបាញ់វាបានទេ។

118 ខ្ញុំបានរំកិលតាមជ្រលងភ្នំ ដេញតាមខ្លារខិននោះ ដោយមើលតាមស្លឹកឈើតាមកន្លែងដែលវារត់ទៅ អ្នកដឹងទេ។ ខ្ញុំបានឮវា។ វាមានជើងបួន។ ខ្ញុំដឹងថាវាមិន មែនជាសត្វជើងពីរទេ គឺវាមានជើងបួន។ ហើយខ្ញុំក៏ដឹងដែរថាវាមិនមែនជាសត្វ ក្ដាន់ ព្រោះសត្វក្ដាន់វាឃើត។ ហើយវាមិនងាយនឹងភ្លាត់អេិលទេ រាងវាដូចឆ្មាអញ្ចឹងគឺខ្ញុំចូលចិត្ត។ ហើយសត្វខ្លាឃ្មុំដើរវែនជើង។ ដូច្នេះហើយខ្ញុំដឹងថាវាច្បាស់ជាសត្វខ្លារខិនហើយ។ ហើយវាពួននៅពីក្រោយដើមឈើធំមួយ ហើយខ្ញុំមើលវា អត់ឃើញទេ រហូតដល់ឃើញវាមួយភ្លែត ហើយក៏បាត់វាទៅ។

119 ហើយខ្ញុំតាមសម្គាល់មើលស្លឹកឈើកំពីកនៅកន្លែងដែលវាទៅ អ្នកដឹងទេគឺនៅលើកំពូលភ្នំ ហើយដេញតាមនោះ ខ្ញុំមិនបានមើលពពកនោះកំពុងចុះមកទេ អ្នកដឹងទេគឺមានអ័ព្ទចុះពេញ។ ខ្ញុំរំកិលចុះមកក្រោមតាមជ្រលងភ្នំហើយទៅតាមដើមឈើធំៗតាមដានរបស់ខ្លារខិននោះ។ ខ្ញុំគិតថា "ខ្ញុំនឹងចាប់វាបានត្រឹមតែ មួយស្របក់។" ខ្ញុំអាចមើលឃើញកន្លែងមួយ ហើយខ្ញុំអាចរត់ឡើងកន្លែងខ្ពស់ ហើយសម្លឹងមើលនិងមើលលបៗជុំវិញ មើលប្រសិនជាខ្ញុំអាចមើលឃើញវា ស្ដាប់ដោយប្រុងប្រយ័ត្ន និងចុះមក រមៀលចុះមកម្ដងទៀត។ អ្នកអាចឮសម្លេង តាម គុម្ព ព្រៃនៅពីមុខខ្ញុំ។ ឃើញទេ វារត់ចូលក្នុងដើមឈើបន្ទាប់មកខ្ញុំ ដេញ តាមវា អត់ទាន់។ ឃើញទេ វាឆ្លាត វាលោតចេញពីដើមឈើមួយទៅដើមឈើមួយទៀត។ បន្ទាប់ មក ខ្ញុំដឹងថាខ្ញុំមិនអាចដេញតាមវាទាន់ទេ។ អូ្ហ ខ្ញុំគិត "អូ្ហ ទោះយ៉ាងណាក៏ដោយ!"

120 ហើយខ្ញុំចាប់ផ្ដើមវិលត្រឡប់មករកជ្រលងអូរវិញហើយខ្ញុំបានធំក្លិនខ្លាឃ្មុំមួយក្បាល លេច ចេញមក គឺខ្លាឃ្មុំឈ្មោលចាស់។ ខ្ញុំគិតថា "ខ្ញុំនឹងចាប់វាបាន ខ្លាឃ្មុំអើយ ល្អណាស់!" ខ្ញុំបានធំក្លិនវាម្ដងទៀត ហើយទៅពីចម្ងាយ រួចខ្ញុំចាំឃ្លាំមើលមានដានអ្វី ហើយសញ្ញាទាំងអស់។ ខ្ញុំមើលអត់ឃើញអ្វីសោះ ក៏វិលត្រឡប់ ទៅមួយចំហៀងភ្នំទៀត។ បន្ទាប់មកទៀតខ្ញុំចាប់ផ្ដើមដឹងថាមានចុះអ័ព្ទ។ ហើយខ្ញុំធំ ក្លិន ម្ដងទៀត គឺតាមខ្យល់មកពីខាងណាមួយ។ ខ្ញុំនិយាយ "អត់ទេ។ ឥឡូវមាន អ្វីកើតឡើង ខ្យល់បកមកតាម*នេះ* ហើយខ្ញុំមកតាម...ក្លិនខ្លាឃ្មុំតាមផ្លូវ*នោះ* ហើយ ខ្ញុំឆ្លងទៅមក ហើយខ្យល់បានបក់មកពីទិសផ្សេងទៀត។ ដូច្នេះហើយ ខ្ញុំត្រូវតែ ត្រឡប់ទៅកន្លែង ដែលខ្ញុំបានធំក្លិនសត្វក្លាឃ្មុំនោះពីដំបូង ហើយនឹងចាប់វាពីទីនោះ មក។"

121 នៅតាមផ្លូវដែលត្រឡប់មកវិញ ខ្ញុំមើលតាមជ្រលងអូរ ខ្ញុំបានឃើញគុម្ព ព្រៃកំរើក។ ហើយនៅពេលដែលខ្ញុំមើលម្ដងទៀត គឺឃើញអ្វីមួយខ្មៅកំរើក។ ខ្ញុំគិតថា "នោះគឺវា។" ខ្ញុំបានដាក់គ្រាប់កាំភ្លើងចូលយ៉ាងលឿន រួចឈរតំរង់។ ហើយវាជាសត្វព្រៃយ៉ាងធំមួយក្បាល។ ខ្ញុំក៏គិតថា "នោះហើយជាអ្វីដែលខ្ញុំចង់បាន។" ក៏បានបាញ់សត្វនោះ។

122 ខ្ញុំបានគិតថា "ល្អហើយ!" ខ្ញុំមិនធ្លាប់ចាប់អារម្មណ៍ថាវាជា...ពេលដែលខ្ញុំ បាញ់ វាបាន ហើយបានជំនួសនូវអ្វីដែលខ្ញុំទទឹងរង់ចាំ...ខ្ញុំបានលាងដៃ និងសំលៀងកាំបិតដាក់ចូលវិញ។ ហើយខ្ញុំបានគិត "សរសើរព្រះជាម្ចាស់! អរព្រះគុណ ព្រះអម្ចាស់ព្រះយេស៊ូវ ព្រះអង្គបានប្រទានសាច់សម្រាប់ រដូវធ្លាក់ទឹក កក។ លើក សរសើរព្រះជាម្ចាស់!" ហើយខ្ញុំបានយកកាំភ្លើងរបស់ខ្ញុំមក។ ខ្ញុំបាន គិតថា "ខ្ញុំនឹងទៅវិញតាមជ្រលងអូរនោះឥឡូវ។" ខ្ញុំនិយាយ "មើលន៎ ព្យុះមកហើយខ្ញុំត្រូវតែប្រញាប់ចេញពីទីនេះ។ ខ្ញុំត្រូវប្រញាប់ចាកចេញពីទីនេះ និងទៅជួប ប្រពន្ធ កូនខ្ញុំ។" ខ្ញុំនិយាយ "ខ្ញុំត្រូវតែប្រញាប់ប្រញាល់។"

123 ខ្ញុំឡើងតាមជ្រោះអូរ ពាក់អាវធំពណ៌ក្រហមគ្មានឡេវ ហើយខ្ញុំបានឡើងតាមជ្រោះអូរនោះ។ រឿងដំបូង អ្នកដឹងទេ ខ្ញុំគិត "តើខ្ញុំមកតាមផ្លូវណា?" ខ្យល់ធ្លាក់បក់ ចុះមកហើយ ដើមឈើអង្រួនផ្ទប់គ្នា។ ខ្ញុំបានគិតថា "តើខ្ញុំមកតាមផ្លូវណា?" ខ្ញុំបានដើរជុំវិញនោះ។ ខ្ញុំ—ខ្ញុំគ្រាន់តែដឹងថាខ្ញុំរត់តម្រង់ទៅត្រង់ ទៅភ្នំហ័រីខេន។

ប៉ុន្តែ ខ្ញុំបាន ឈប់ដោយបែកញើស សស្រាក់ ហើយខ្ញុំបានគិតថា "តើមានរឿងអ្វីកើត ឡើងនៅទីនេះ? ខ្ញុំបានទៅអស់រយៈពេលកន្លះម៉ោង តែនៅតែមិនអាចរកច្រកចេញ។" ខ្ញុំបានងើយមើលទៅលើ ឃើញកន្លែងព្យួរក្តាន់។ គឺខ្ញុំនៅកន្លែងដដែល។ ហើយខ្ញុំបានគិតថា "តើខ្ញុំបានធ្វើអ្វី?"

124 ខ្ញុំបានចេញទៅម្តងទៀត។ ខ្ញុំបានគិតថា "លើកនេះខ្ញុំនឹងអាចរកផ្លូវចេញបានហើយ ខ្ញុំអត់បានចាប់អារម្មណ៍ទេ។" ខ្ញុំបានមើលអ្វីទាំងអស់ដែលមាន កំរើក នៅជុំវិញ។ មើលហើយមើលទៀតប្រឹងស្វែងរកហើយរកទៀត។ ហើយមានពពកចុះ ខ្ញុំដឹងថាមានព្យុះព្រិលនៅតាមផ្លូវ អ័ព្ទចាប់ផ្តើមចុះទាប ហើយខ្ញុំបានកត់សម្គាល់។ ខ្ញុំបានគិតថា "ខ្ញុំនឹងទៅកាន់តែឆ្ងាយហើយ" ទៅទៀតៗៗៗ។ ហើយខ្ញុំបានគិតថា "គឺវាចម្លែកខ្លាំងណាស់ មើលទៅហាក់បីដូចជាខ្ញុំធ្លាប់ ឃើញ កន្លែងនេះពីមុន។" ហើយខ្ញុំបានមើល ហើយឃើញសត្វដែលខ្ញុំព្យួរ។ ឃើញទេ?

125 អ្នកដឹងទេថាខ្ញុំបានស្ថិតនៅក្នុងកាលៈទេសៈអ្វី? ជនជាតិឥណ្ឌាបានហៅថា "ដើរក្នុងសេចក្តីស្លាប់។" ឃើញទេ អ្នកដើរវិលវល់ ទៅមកជុំវិញ។ ខ្ញុំបានគិតថា ល្អណាស់សម្រាប់ខ្ញុំ មានអ្នកនាំផ្លូវមិនងាយវង្វេងបានទេ។ ឃើញទេ គ្មាននរណាប្រាប់ខ្ញុំនៅក្នុងព្រៃ តែខ្ញុំបានស្គាល់ផ្លូវទៅមកទៅមកជុំវិញ។ ឃើញទេ?

126 ហើយខ្ញុំចាប់ផ្តើមចេញទៅម្តងទៀត ខ្ញុំបាននិយាយថា "ខ្ញុំមិនធ្វើកំហុស នេះទៀតទេ។" ហើយខ្ញុំបានត្រឡប់មកកន្លែងនេះម្តងទៀត។

127 ខ្ញុំបានឡើងទៅជើងជ្រោះបន្តិច បន្ទាប់មានខ្យល់បក់មក។ អូ មានព្រិលគ្រប់ទិសទី! ស្ទើរតែងងឹត។ ហើយខ្ញុំដឹងថាមេដានឹងស្លាប់នៅយប់នោះនៅក្នុងរហោស្ថាន ព្រោះនាងអត់ដឹងថាត្រូវមើលថែខ្លួនយ៉ាងណាទេនៅទីនោះ។ ហើយប៊ីលលីទើបតែមានអាយុជិតបួនឆ្នាំ ឬបីឆ្នាំ គឺនៅតូចនៅឡើយ។ ខ្ញុំបានគិតថា "តើពួកគេនឹងត្រូវធ្វើអ្វី?" ពិតណាស់ ខ្ញុំទៅកាន់តែឆ្ងាយហើយត្រូវរអិលដោយស្លែ ខ្ញុំបានគិតថា "ខ្ញុំកំពុងតែនៅកន្លែងដែលរាបស្មើរ ហើយខ្ញុំមិនអាចឃើញអ្វីទាំងអស់គឺឃើញតែ អ័ព្ទ។" ឥឡូវខ្ញុំកំពុងតែធ្វើដំណើរដោយគ្មានទិសដៅ។

128 ជាធម្មតា ខ្ញុំនឹងរកកន្លែងដែលខ្ញុំអាចចាំបាន ហើយប្រសិនជាមានអ្នកណាម្នាក់នៅជាមួយខ្ញុំ។ នោះខ្ញុំនឹងរង់ចាំរហូតដល់ព្យុះស្ងប់ស្ងាត់ អាចមួយថ្ងៃឬពីរថ្ងៃរួចទើបចេញទៅ។ កាត់បំណែកសាច់សត្វក្តាន់...ដែលស្ពាយនៅពីក្រោយហើយ

បរិភោគវាដោយមិនមានការខ្វាយខ្វល់។ ប៉ុន្តែមិនអាចធ្វើបែបនោះបានទេ ដោយទុកប្រពន្ធកូនចោលនៅក្នុងព្រៃ ឲ្យដាច់ពោះស្លាប់នោះទេ។ ឃើញទេ?

129 ដូច្នេះខ្ញុំចាប់ផ្តើមគិត "តើខ្ញុំអាចធ្វើអ្វីបាន?" ដូច្នេះខ្ញុំទៅឆ្វាយបន្តិច។ ហើយគិត "ឥឡូវចាំសិន។ នៅពេលដែលខ្ញុំឆ្លងកាត់ជ្រលងទីមួយគឺមានខ្យល់បក់មកប៉ះមុខ របស់ខ្ញុំ អញ្ចឹងខ្ញុំគួរតែឆ្លងកាត់ផ្លូវនេះ។ ខ្ញុំគួរតែឆ្លងតាមផ្លូវនេះ ខ្ញុំប្រាកដជាមកតាមផ្លូវនេះ។" ហើយខ្ញុំឆ្ងល់ថាហេតុអ្វីបាន ជាខ្ញុំហាក់បីដូចជាចុះទៅក្នុង កន្លែងដែល ធំល្វឹងល្វើយដោយមិនដឹងថាកំពុងតែនៅកន្លែងណា។ ខ្ញុំនិយាយ "អូ!" ខ្ញុំចាប់ ផ្តើមភ័យខ្លាចហើយខ្ញុំបានគិតថា "ចាំសិនប៊ីលអ្នក អត់វង្វេងទេ" ព្យាយាមបញ្ឆោត ខ្លួនឯង។ អ្នកមិនអាចបញ្ឆោតបានទេ។ ទេ ទេ។ មនសិការខាងក្នុងប្រាប់អ្នកថា អ្នកខុសហើយ។

130 អូ អ្នក—អ្នកព្យាយាមនិយាយ "អូ ខ្ញុំបានសង្គ្រោះហើយ ខ្ញុំទៅព្រះវិហារ។" តើអ្នកមិនខ្វាយខ្វល់ទេ អ្នកចាំរហូតដល់សេចក្តីស្លាប់មកដល់ ហើយអ្នកនឹង ដឹងថាវា គឺមានលក្ខណៈខុសប្លែក។ មនសិការរបស់អ្នកប្រាប់អ្នក។ ហើយពេល ខ្លះអ្វីដែលនៅក្នុងខ្លួនរបស់អ្នកប្រាប់អ្នកថាអ្នកខុសហើយ។ ឃើញទេ? អ្នកដឹង ប្រសិនជាអ្នកស្លាប់នោះអ្នកនឹងមិនអាចជួបព្រះបរិសុទ្ធបាននោះទេ។ ដូចជា អ្នកបានឃើញទ្រង់កាលពីយប់មិញ ទោះបីជាទេវតាបរិសុទ្ធក៏ត្រូវពាក់ស្បៃ បាំងមុខពួកគេដែរដើម្បីអាចឈរនៅចំពោះព្រះអង្គ។ តើអ្នកនឹងឈរខាងក្រៅពីព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូវទុកជាស្បៃបាំងមុខអ្នក?

131 ខ្ញុំបានគិតថា "អូ ខ្ញុំនឹងធ្វើវាបាន។" ខ្ញុំបានចាប់ផ្តើមបន្ត ហើយខ្ញុំបានដឹងថា ខ្ញុំកំពុងតែឮនូវអ្វីមួយ បន្ទាប់មកខ្ញុំចាប់ផ្តើមភ័យខ្លាច។ ហើយខ្ញុំបានគិតថា "ឥឡូវ ប្រសិនជាខ្ញុំធ្វើដូច្នេះ នោះខ្ញុំនឹងត្រឡប់ទៅជាចំរៀកៗ"។ នោះគឺជាអ្វីដែលមនុស្ស វង្វេងគេធ្វើ គឺគាត់ដាច់ជាចំរៀកៗ បន្ទាប់មកគាត់អាចយកកាំភ្លើងរបស់គាត់ មក បាញ់ខ្លួនឯង ឬអាចធ្លាក់តាមប្រឡាយហើយធ្វើឲ្យជើងរបស់គាត់បាក់ រួចគាត់ បានដេកដួលនៅទីនោះហើយក៏ស្លាប់នៅទីនោះ។ ដូច្នេះហើយខ្ញុំ បាន គិតថា "តើខ្ញុំត្រូវធ្វើអ្វី?" ដូច្នេះខ្ញុំបានបន្តដើរទៅមុខទៀត។

132 ហើយខ្ញុំបន្តឮអ្វីមួយកំពុងតែនិយាយ "យើងជាជំនួយក្នុងពេលដែលមាន ទុក្ខលំបាក។" ខ្ញុំគ្រាន់តែបន្តធ្វើដំណើរទៅមុខទៀត។

133 ខ្ញុំបានគិតថា "ឥឡូវខ្ញុំគិតថាខ្ញុំចេញជិតរួចហើយខ្ញុំកំពុងតែឮសំឡេងនិយាយមកកាន់ខ្ញុំ។" ខ្ញុំបន្តដំណើរទៅមុខ។ ខ្ញុំបានទៅ "ហូ ហ្វូច ហ្វូច" សំឡេងហ្វូចអ្នកដឹងទេ ខ្ញុំគិតថា "ឥឡូវខ្ញុំអត់វង្វេងទេ។អ្នកដឹងទេថាអ្នកកំពុងតែនៅកន្លែងណា! តើអ្នកមានរឿងអី? អ្នកមិនអាចវង្វេងបានទេ។ អ្នក—អ្នកគឺជា អ្នក បរ បាញ់ យ៉ាងជំនាញអ្នកមិនអាចវង្វេងបានទេ។" និយាយអួតបំប៉ោងខ្លួនឯង អ្នកដឹងទេ ការ អួតអាងពីខ្លួន របស់ខ្ញុំអួតដាក់ខ្លួនឯងនោះ។

134 អ្នកមិនអាចអួតបានទេ។ នៅតាមផ្លូវនេះមានដុំកង់វិលតូចមួយនិយាយថា "អូ្ន អ្នកឯងវង្វេងហើយអ្នកក៏ដឹងខ្លួនថាអ្នកកំពុងតែវង្វេងដែរ។ មើលអ្នកឯង វង្វេងហើយ។"

135 ខ្ញុំបន្តដំណើរទៅមុខ។ "អូ្ន ខ្ញុំមិនវង្វេងទេ!ខ្ញុំ នឹងមិនអីទេ។ ខ្ញុំនឹងរកផ្លូវចេញឃើញ។" គ្រប់យ៉ាងមើលទៅហាក់បីដូចជាកំប្លែង ខ្យល់ក៏បក់កាន់តែជិត។ ព្រិលក៏ចាប់ ផ្ដើមហើរ យើងហៅថា "ការធ្លាក់ចុះ។" ខ្ញុំបានគិតពី "ប្រពន្ធកូន! អត់ទេខ្ញុំនឹងមិន..." ខ្ញុំបានគិត "ឱខ្ញុំអើយ!"

136 ខ្ញុំបានឮផ្ទាល់ម្ដងទៀតថា "យើងជាជំនួយនៅក្នុងពេលមានទុក្ខលំបាក។" ខ្ញុំជាគ្រូប្រកាសដំណឹងល្អ ហើយជាគ្រូអធិប្បាយនៅឯរោងឧបោសថ។

137 ដូច្នេះហើយខ្ញុំបានគិតថា "អញ្ចឹង តើខ្ញុំត្រូវធ្វើអ្វី?" ខ្ញុំបានឈប់ ហើយមើលគ្រប់ទិសទី ហើយមានអ័ព្ទបានធ្លាក់ចុះមកហើយ។ ខ្ញុំ...គឺជាវា។ មិនអាច ធ្វើអ្វីបានទៀតទេ។ ខ្ញុំបានគិត "អូ្ន តើខ្ញុំត្រូវធ្វើអ្វីទៅ?" ខ្ញុំបានគិតថា "លោក ខ្ញុំមិន រស់ទេខ្ញុំមានទំនុកចិត្តលើខ្លួនឯងជ្រុលពេកហើយ។ ខ្ញុំបានគិតថាខ្លួនឯងជា អ្នក បរបាញ់ដ៏ជំនាញ ប៉ុន្តែគឺមិនដូច្នេះឡើយ។"

138 បងប្អូន ខ្ញុំតែងតែជឿជាក់លើទ្រង់។ ការបាញ់ ខ្ញុំបានទទួលភាពល្បីល្បាញនៅទីនោះ។ ហើយជាអ្នកនេសាទត្រីទៀតផង ខ្ញុំជាអ្នកក្រម្នាក់ ប៉ុន្តែខ្ញុំតែង តែជឿជាក់លើទ្រង់។ ការបាញ់កាំភ្លើងគឺខ្ញុំនៅអន់ ប៉ុន្តែទ្រង់បានធ្វើឲ្យខ្ញុំ ក្លាយទៅ ជាអ្នកដែល បំបែកឯកត្តកម្មពិភពលោកខាងការបាញ់កាំភ្លើង។ ឃើញទេ? បាញ់ក្ដាន់ ចម្ងាយប្រមាណប្រាំពីរ ទៅប្រាំបីរយយ៉ាដ។ ដកកាំភ្លើងបាញ់បានសាមសិបប្រាំ ក្បាលដោយមិនមានខុសមួយសោះ។ គ្រាន់តែអាននៅកន្លែងណាដែលអ្នក

អាច រកអានបាន។ ឃើញទេ? គឺមិនមែនជាខ្ញុំឡើយ តែជាទ្រង់ ខ្ញុំបានជឿជាក់លើទ្រង់។

នៅទីនោះ ខ្ញុំបានគិតទៀតថា "តើខ្ញុំត្រូវធ្វើអ្វី? តើខ្ញុំត្រូវធ្វើអ្វី?"

139 ខ្ញុំបន្តទៀត...គឺកាន់តែជិតទៅៗហើយ "យើងជាជំនួយនៅក្នុងពេលដែលមានទុក្ខលំបាក ជាជំនួយក្នុងពេលបច្ចុប្បន្ន។"

140 ខ្ញុំបានគិតថា "តើជាសម្លេងព្រះជាម្ចាស់មានបន្ទូលមកកាន់ខ្ញុំមែនទេ?" ខ្ញុំបាន ដោះមួកចេញ។ ខ្ញុំមានមួកទាហ៊ាន កន្សែងពណ៌ក្រហមរុំជុំវិញ វា។ ខ្ញុំបានដោះវាចេញ។ ដោះអាវធំចេញវាសើម។ ហើយខ្ញុំបានទំលាក់អាវធំខ្ញុំចុះ ពាក់កាំភ្លើងទៅនឹងមែកឈើ។ ខ្ញុំបាននិយាយ "ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ឥឡូវ ខ្ញុំមើលរំលងខ្លួនឯងខ្ញុំឮសម្លេងនិយាយមកកាន់ខ្ញុំ។ តើសម្លេងនោះគឺជាព្រះអង្គមែនទេ?" ខ្ញុំបាននិយាយទៀត "ព្រះអម្ចាស់អើយ ទូលបង្គំទទួលស្គាល់ថា ខ្ញុំមិនមែនជា អ្នកបរបាញ់ទេ។ ទូលបង្គំមិន ទូលបង្គំ—ទូលបង្គំមិនស្គាល់ផ្លូវនៅ ជុំវិញ នេះឡើយ។ ព្រះអង្គអើយសូមជួយ ទូល បង្គំផង។ ខ្ញុំមិនសមរស់ឡើយ ហើយ ធ្វើ អ្វីដែលទូលបង្គំបានធ្វើ ឡើងមក ទីនេះដោយ គិតថាទូលបង្គំដឹងច្រើនល្មមនឹង មិនវង្វេងឡើយ។ ទូលបង្គំ ត្រូវការ ព្រះអង្គ។ ភរិយារបស់ទូលបង្គំជាស្ត្រីល្អម្នាក់។ កូនប្រុសរបស់ទូលបង្គំនៅតូចម្តាយរបស់គាត់ ព្យាយាមធ្វើជាម្តាយដ៏ល្អសម្រាប់គាត់ ហើយទូលបង្គំទើបតែ រៀប ការជាមួយនាង។ ហើយនាងនៅទីនោះ ជាមួយ កូនកណ្តាលព្រៃ ពួកគេនឹង ត្រូវ ស្លាប់ នៅទីនោះជាមិនខាននូវយប់នេះ។ មានខ្យល់សីតុណ្ហភាពធ្លាក់ ដល់ ដប់ ក្រោមសូន្យ ហើយពួកគេមិនដឹងពីរបៀប ដែលត្រូវរស់នៅរបៀបនេះទេ។ពួកគេនឹងស្លាប់នូវយប់នេះ។ សូមកុំឲ្យពួកគេស្លាប់ឡើយ ព្រះជាម្ចាស់អើយ។ សូមនាំទូលបង្គំទៅកាន់ពួកគេ ដើម្បីឲ្យកូនអាចមើលឃើញថាពួកគេមិនស្លាប់ទេ។ កូនវង្វេង ហើយ! កូនវង្វេងហើយ ព្រះជាម្ចាស់! ទូលបង្គំ—ទូលបង្គំមិនអាចស្វែងរកផ្លូវនៅជុំវិញនេះបានទេ។ តើព្រះអង្គនឹងជួយដល់ទូលបង្គំទេ? ហើយសូមអត់ទោសទូលបង្គំ សម្រាប់ការគិតតែពីផ្លូវរបស់ខ្លួនឯង! កូន មិន អាចធ្វើអ្វីបានដោយគ្មាន ព្រះអង្គនោះ ទេ ទ្រង់គឺជាអ្នកនាំផ្លូវទូលបង្គំ។ សូម ជួយ ទូលបង្គំផងព្រះអង្គ។"

141 ខ្ញុំក្រោកឡើង ហើយនិយាយថា "អាម៉ែន។" ប្រមូលកន្សែងអាវធំរបស់ខ្ញុំឡើង លើកម្ពុកមកពាក់យកកាំភ្លើងរបស់ខ្ញុំ។ ខ្ញុំនិយាយថា "ឥឡូវខ្ញុំនឹងធ្វើឲ្យអស់ពីលទ្ធភាពរបស់ខ្ញុំដែលខ្ញុំដឹងថាត្រូវទៅដោយរបៀបណា ប្រើប្រាស់ការយល់ដឹង ដែលប្រសើរបំផុតរបស់ខ្ញុំ ហើយខ្ញុំនឹងទៅតាមផ្លូវត្រង់ ព្រោះខ្ញុំបាន ដើរជុំវិញ ដោយមិនដឹងថាខ្ញុំនៅកន្លែងណានោះទេ។ ប៉ុន្តែខ្ញុំនឹងទៅកន្លែងណា ដែលព្រះអង្គមានបន្ទូលឲ្យខ្ញុំទៅ ព្រះជាម្ចាស់ ព្រះអង្គជាអ្នកនាំផ្លូវទូលបង្គំ។"

142 ខ្ញុំបានចាប់ផ្តើមធ្វើដំណើរតាមផ្លូវ*នេះ*។ ខ្ញុំបាននិយាយថា "ផ្លូវនេះហើយ ហើយខ្ញុំត្រូវតែធ្វើឲ្យខ្លួនខ្ញុំមានភាពជឿជាក់។ ខ្ញុំទៅតាមផ្លូវ*នេះ*។ ខ្ញុំទៅតាមផ្លូវត្រង់*នេះ*។ ខ្ញុំនឹងមិនទៅតាមផ្លូវផ្សេងខ្ញុំទៅតាមផ្លូវ*នេះ*។ ខ្ញុំដឹងថាត្រឹមត្រូវហើយ។ ខ្ញុំទៅតាមផ្លូវ*នេះ*។" ប្រសិនជាខ្ញុំបានមកតាមផ្លូវនេះខ្ញុំប្រហែលជាចេញទៅខាង ប្រទេសកាណាដា។ ឃើញទេ?

143 បន្តិចមកទៀតខ្ញុំមានអារម្មណ៍ថាមានអ្វីប៉ះស្មារបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាដូចជាដៃមនុស្សប្រុស ខ្ញុំងាកក្រោយយ៉ាងលឿនមើលជុំវិញ។ គឺគ្មានអ្នកណាសោះ។ ខ្ញុំបានគិតថា "តើជាអ្វីទៅ?" នេះជាព្រះគម្ពីរនៅពីមុខខ្ញុំ។ ព្រះជាម្ចាស់ជាអ្នកនាំផ្លូវខ្ញុំ និងចៅក្រម គឺឈរនៅទីនោះ។ ខ្ញុំគ្រាន់តែបានងើយសម្លឹងមើលទៅខាងលើ។ ហើយមើលមកផ្លូវ*នេះ*វិញឃើញថាអ័ព្ទបានរសាត់បាត់ទៅ រហូតដល់ខ្ញុំ អាច មើលឃើញកំពូលភ្នំហ័ររីខេន។ ទៅតាមផ្លូវខាងស្តាំត្រង់ទៅ នោះហើយជាសមត្ថភាពបរបាញ់របស់ខ្ញុំ ខ្ញុំបានចេញពីទីនោះជិតព្រលប់ទៅហើយ។ ខ្ញុំបានចេញដំណើរទៅយ៉ាងលឿនដោយតម្រង់តាមផ្លូវ*នេះ*។ ខ្ញុំបានដោះមួកចេញហើយលើក ដៃឡើង ខ្ញុំបាននិយាយថា "សូមនាំទូលបង្គំព្រះអង្គអើយ ទ្រង់គឺជាអ្នកនាំផ្លូវរបស់ ទូលបង្គំ។"

144 ខ្ញុំបានចាប់ផ្តើម។ ចេញទៅតាមផ្លូវបត់ស្តាំទៅត្រង់ តាមច្រាំងចោទ ហើយឆ្លងកាត់ទីនោះជាបន្តបន្ទាប់។ រួចមេឃចាប់ផ្តើមងងឹត។ មានសត្វក្តាន់លោតនៅពីមុខខ្ញុំនិងសត្វផ្សេងទៀត។ ខ្ញុំមិនបានគិតពីអ្វីទាំងអស់ គឺផ្តោតតែលើផ្លូវដែលត្រូវឆ្លងកាត់ភ្នំនេះ។

145 ខ្ញុំដឹងថាប្រសិនជាខ្ញុំទៅដល់កន្លែងរបស់ លោក ដេនថុន នោះខ្ញុំ...ខ្ញុំអាចជួយដាក់ខ្សែព្រំដែនសម្រាប់និទាឃរដូវ។ យើងដាក់ខ្សែទូរស័ព្ទពីភ្នំហ័ររីខេន ដល់ក្រោម

ប្រវែងពី បី បីកន្លះ ឬបួនម៉ាយ ទៅដល់ជំរុំ។ ហើយចុះទៅដល់ក្រោមនោះមាន ឧបសគ្គខ្លះ ប៉ុន្តែនៅមានព្រិលទីនោះអ្នក ពិបាកប្រាប់ពីឧបសគ្គនោះណាស់។ ឃើញ ទេ? ហើយខ្យល់បក់បោកមក មេឃងងឹត ហើយព្យុះទឹកកក អ្នកមិនអាច ប្រាប់ថាអ្នកកំពុងតែនៅទីណានោះទេ។ ល្អអ្វីដែលខ្ញុំដឹងថាត្រូវធ្វើតែនៅពេលងងឹត ខ្ញុំមិនដឹងអ្វីទាំងអស់...ខ្ញុំដឹងថាមានផ្លូវមួយ ដែលឡើងទៅលើភ្នំ។ ព្រោះខ្ញុំគួរតែ ឡើងភ្នំ និងប៉មដែលនៅឯខាងលើកំពូលភ្នំ ហើយខ្ញុំត្រូវធ្វើដំណើរចម្ងាយប្រហែល ជាប្រាំមួយម៉ាយដើម្បីទៅដល់ទីនោះ។ គ្រាន់តែគិតមានអ័ព្ទធ្លាក់ចុះយ៉ាង ច្រើន ខ្ញុំ អាចមើលវាឃើញ!

146 បន្ទាប់មកទៀតខ្ញុំ—ខ្ញុំបានយកកាំភ្លើងវែងនៅក្នុងដៃ*នេះ* ហើយលើក*នេះ*ឡើង ពីព្រោះខ្ញុំ ត្រូវភ្ជាប់—ភ្ជាប់ខ្សែភ្លើងទៅលើដើមឈើចុះមកក្រោម ខ្សែទូរស័ព្ទតចូល ក្នុងខ្ទម ដើម្បីឲ្យគាត់អាចនិយាយជាមួយប្រពន្ធរបស់គាត់បាន ហើយបន្ទាប់ មក គាត់បានទូរស័ព្ទមកពីលើភ្នំនោះ។ ហើយខ្ញុំនឹងជួយដល់គាត់យកវាចុះមកក្រោម។ ហើយខ្ញុំនៅលើកដៃឡើងដូច*នេះ* និយាយថា "ឱព្រះជាម្ចាស់អើយ សូម ឲ្យខ្ញុំប៉ះ ខ្សែ នោះ។" ដើរបណ្ដើរ ហើយដៃខ្ញុំ ឈឺយ៉ាងខ្លាំង ដោយការហត់ នឿយ ផងខ្ញុំ ពិបាក នឹងកាន់ ហើយខ្ញុំត្រូវដាក់វាចុះ។ ហើយដូរការកាន់កាំភ្លើងវិញ ហើយដាក់ វា*ដូច្នេះ* ថយ ក្រោយពីរបីជំហ៊ានដើម្បីធានាថា ខ្ញុំមិនបាត់វាហើយ លើកដៃ ឡើង បន្តធ្វើដំណើរទៅ។ មេឃកាន់តែងងឹតខ្យល់បក់មក។ អូ ខ្ញុំតោងយ៉ាងជាប់ ដោយ និយាយ ថា "ហ្នឹងហើយ! ទេវាមិនមែនទេ។" អូ វាឲ្យ...កុំឲ្យ វាមាន សម្លេង មិនច្បាស់។

147 មួយសន្ទុះក្រោយមក ពេលដែលខ្ញុំស្ទើរតែបោះបង់ចោល ដៃរបស់ខ្ញុំបានប៉ះ ទង្គិចទៅនឹងអ្វីមួយ។ អូ! ខ្ញុំនឹកឃើញហើយ ពេលដែលខ្ញុំវង្វេង។ ខ្ញុំបាន កាន់ ខ្សែនោះ។ ហើយខ្ញុំបានដាក់កាំភ្លើងចុះ ដោះមួកចេញហើយក្រោកឈរនៅទីនោះ។ ដោយនិយាយថា "អូព្រះអើយ នេះជាអារម្មណ៍ដែលវង្វេង ហើយនៅពេល ដែល រក ផ្លូវឃើញវិញ។" ខ្ញុំនិយាយទៀត "ទៅតាមដោយតោងខ្សែរនេះដល់ចុង បញ្ចប់ ខ្សែ នោះ ខ្ញុំនឹងលែងវង្វេងទៀតហើយ។ ខ្ញុំនឹងតោងខ្សែនោះជាប់។ វានឹងនាំ ផ្លូវ ខ្ញុំ ទៅត្រង់តាមកន្លែងដែលខ្ញុំចង់ទៅ គឺទៅរកកន្លែងដែលបានសម្លាប់ក្តាន់ នៅខាង ក្រោមនោះ។ ប្រពន្ធ និងកូនរបស់ខ្ញុំវង្វេងអត់ដឹងថាខ្ញុំនៅកន្លែងណានោះទេ គាត់ អត់ ចេះបង្កាត់ភ្លើងទេហើយមិនដឹងថាត្រូវធ្វើអ្វី នៅពេលមានខ្យល់បក់មក ហើយ

ស្លឹកឈើបក់ធ្លាក់ពីដើមឈើ។" ខ្ញុំនៅតែមិន ហ៊ានព្រលែងខ្សែនោះ។ ខ្ញុំបានកាន់វាជាប់រហូតដល់វាបាននាំខ្ញុំទៅកាន់កន្លែងដែលខ្ញុំដឹងថាខ្ញុំកំពុងតែនៅត្រង់ណា។

148 នោះជាបទពិសោធន៍ដ៏គួរឲ្យរន្ធត់ណាស់ ហើយក៏ជាបទពិសោធន៍ដ៏អស្ចារ្យមួយដែលអាចនាំខ្ញុំឲ្យរកផ្លូវឃើញ តែវាមិនមែនតែពាក់កណ្ដាលនោះឡើយ។ ថ្ងៃមួយ ខ្ញុំបានវង្វេងនៅក្នុងអំពើបាប។ ខ្ញុំបានទៅព្រះវិហារមួយហើយមួយទៀត ព្យាយាមស្វែងរកអ្វីមួយ។ ខ្ញុំបានទៅព្រះវិហារ សេដវ៉េនដេ អេដវ៉េនទីស ពួកគេ បានប្រាប់ខ្ញុំ "រក្សាថ្ងៃឈប់សំរាក តមការបរិភោគសាច់។" ហើយទៅកាន់ព្រះវិហារបាបទីស្ទគេប្រាប់ថា"គ្រាន់តែក្រោកឡើងហើយប្រាប់គេថាអ្នកជឿដល់ព្រះ អម្ចាស់ព្រះយេស៊ូវគ្រីស្ទព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ហើយខ្ញុំនឹង ធ្វើពិធីជ្រមុជទឹក ឲ្យអ្នក គឺរួចហើយ។" គឺហាក់បីដូចជាគ្មានអ្វីទាល់តែសោះ។ ប៉ុន្តែនៅថ្ងៃមួយ មាន ដុំធ្យូងតូចមួយខ្ញុំបានកាន់នៅដៃលើកឡើងខ្ញុំបានចាប់កាន់អ្វីមួយ ឬខ្ញុំអាច និយាយបានថា មានអ្វីមួយដែលទាញខ្ញុំ។ វាគឺជាខ្សែនៃជីវិត ជាអ្នកនាំផ្លូវ។ ហើយព្រះអង្គបាននាំខ្ញុំ តាមផ្លូវដ៏វែងឆ្ងាយដោយសុវត្ថិភាព ហើយខ្ញុំ នឹងមិន ដកដៃរបស់ ខ្ញុំចេញពីខ្សែរបស់ព្រះនោះទេ។ ខ្ញុំនឹងតោងព្រះអង្គ ឲ្យជាប់។ ចូរឲ្យ លទ្ធិសាសនា និង និកាយទាំងឡាយធ្វើអ្វីដែលគេចង់ធ្វើចុះ ចំណែក ខ្ញុំវិញ គឺតោងជាប់ ព្រះអង្គដែលនាំផ្លូវ។ ដែលនាំគ្រប់ទិសទីពាសពេញ ផែន ដី និងស្ថាន សួគ៌ ព្រះអង្គមានតម្លៃខ្លាំងណាស់សម្រាប់ខ្ញុំ គឺនៅចុងបញ្ចប់នៃខ្សែ នោះ។ ព្រះអង្គ បាននាំ ខ្ញុំមកតាមផ្លូវដ៏វែងឆ្ងាយប្រកបដោយសុវត្ថិភាព ខ្ញុំនឹងទុក ចិត្ត ព្រះ អង្គ នូវគ្រប់ទាំងផ្លូវ។ "នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធយាងមក ព្រះអង្គនឹងនាំផ្លូ វអ្នក និង ដឹកនាំអ្នកគ្រប់ទាំងផ្លូវ..."

149 សម្លាញ់ គឺព្រះអង្គបាននាំខ្ញុំមកដល់សព្វថ្ងៃ។ ហើយបានធ្វើឲ្យខ្ញុំក្លាយ ជាយ៉ាងនេះ។ ខ្ញុំមានសេចក្ដីរីករាយនឹងណែនាំទៅកាន់អ្នកទាំងអស់គ្នា។ គឺជាព្រះអង្គដែលនាំផ្លូវតែមួយគត់ដែលបាននាំខ្ញុំឲ្យស្គាល់អ្វីគ្រប់យ៉ាង ទាំងនៅផែនដី និងនៅស្ថានសួគ៌។ ព្រះអង្គគឺជាអ្នកនាំផ្លូវដល់ខ្ញុំនៅពេល ដែលខ្ញុំចេញទៅបរបាញ់។ ព្រះអង្គជាអ្នកដែលនាំផ្លូវដល់ខ្ញុំនៅពេលដែលខ្ញុំចេញទៅនេសាទត្រី។ ព្រះអង្គគឺជា អ្នក ដែលណែនាំខ្ញុំនៅពេលដែលខ្ញុំនិយាយទៅកាន់នរណាម្នាក់។ ព្រះអង្គគឺជាអ្នកដែលដឹកនាំខ្ញុំនៅពេល ដែលខ្ញុំអធិប្បាយ។ ព្រះអង្គជាអ្នកនាំផ្លូវខ្ញុំនៅពេលដែល ខ្ញុំគេង។

150 ហើយនៅពេលដែលខ្ញុំដើរដល់ផ្លូវសេចក្ដីស្លាប់ ព្រះអង្គនឹងឈរនៅមាត់ទឹក។ ហើយព្រះអង្គនាំខ្ញុំឆ្លងកាត់ផ្លូវនោះ។"ខ្ញុំនឹងមិនខ្លាចសេចក្ដីអាក្រក់ណាទៀយ ត្បិតទ្រង់គង់នៅជាមួយនឹងទូលបង្គំ។ ព្រនង់ ហើយនឹងដំបងរបស់ទ្រង់នឹងកែតម្រង់ ខ្ញុំ ហើយនាំផ្លូវខ្ញុំឆ្លងកាត់ទន្លេនោះ។"

ចូរយើងអធិស្ឋាន។

151 ព្រះបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំអរព្រះគុណជាខ្លាំងសំរាប់ព្រះអង្គដែលនាំផ្លូវ ជាអ្នកដឹកនាំទូលបង្គំ។ ឱព្រះអង្គអើយ ពេលខ្លះទូលបង្គំមិនអាចឮ ពីព្រះសូរសៀងព្រះអង្គ ទូលបង្គំមានការភ័យខ្លាច។ ទូលបង្គំចង់បានទ្រង់គង់នៅក្បែរ ត្បិតទូលបង្គំមិនដឹងថានៅពេលណាទូលបង្គំត្រូវរត់ដល់ទឹកទន្លេនោះទេ។ ទូលបង្គំចង់បាន ព្រះអង្គគង់នៅជិតទូលបង្គំ។ សូមកុំចាកចោលទូលបង្គំឡើយព្រះអម្ចាស់។ ទូលបង្គំមិនអាចនិយាយ និងអធិប្បាយ និងមិនអាចបរ បាញ់ នៅក្នុងព្រៃ និងមិនអាចស្ទូចត្រីនៅតាមបឹង ទូលបង្គំមិនអាចបើកបរឡានរបស់ ទូលបង្គំ ហើយទូលបង្គំមិនអាចធ្វើអ្វី បានទាំងអស់បើគ្មានព្រះអង្គ។ ព្រះអង្គ គឺជាអ្នកនាំផ្លូវ ទូលបង្គំ។ តើជាអំណរអម្បាលមាណទៅដែលទូល បង្គំអាចចែក ចាយ ទៅកាន់បងប្អូនទាំងអស់គ្នា នៅយប់នេះពីរបៀបដែលព្រះអង្គបាននាំទូល បង្គំ!

152 ប៉ុន្មានថ្ងៃមុន ខ្ញុំបានគិតពីកាលពីពីរបីឆ្នាំមុន ខ្ញុំបានឈរនៅលើផ្លូវនេះ ដោយសារតែគ្រួសាររបស់ខ្ញុំបានធ្វើខុសហើយគ្មានអ្នកណានិយាយចូលខ្ញុំសោះ។ ខ្ញុំមានអារម្មណ៍ឯការ ចង់បានការប្រកបរាក់ទាក់។ គ្មានអ្នកណាចង់រាប់រកខ្ញុំទេ។ ពួកគេបាននិយាយថា "ឪពុករបស់គាត់គឺជាអ្នកបិទស្រាខុសច្បាប់។" ហើយព្រះអម្ចាស់អើយ គ្មានអ្នកណានិយាយចូលខ្ញុំទេ។ តែខ្ញុំស្រឡាញ់ដល់មនុស្ស។ ប៉ុន្តែ មានថ្ងៃ មួយ នៅពេលដែលខ្ញុំចេញពីខ្សែបន្ទាត់នោះ! ឥឡូវខ្ញុំគិតព្រះអម្ចាស់ ខ្ញុំបានចេញទៅ ទីរហោស្ថានដើម្បីសំរាក។ តើវាធ្វើអ្វី? មិនមានអ្វីជារបស់ខ្លួន មិនមានការអប់រំ គឺខ្ញុំគ្មានអ្វីទាំងអស់។ ប៉ុន្តែគឺព្រះអង្គហើយ ព្រះអម្ចាស់។ គឺព្រះអង្គ។ ព្រះអង្គ បានឲ្យ ខ្ញុំនៅចំណុចសូន្យ ព្រះអង្គបានឱ្យខ្ញុំចាប់បានត្រីធំ ពីព្រោះ ព្រះអង្គ ជ្រាបថា ខ្ញុំចង់ធ្វើបែបនោះ។ព្រះអង្គប្រទានឲ្យខ្ញុំមានឪពុកម្ដាយ។ ព្រះអង្គប្រទាន ឱ្យខ្ញុំមានបងប្អូនប្រុសស្រី។ព្រះអង្គប្រទានឱ្យខ្ញុំមានសុខភាពល្អ។ ព្រះអង្គប្រទាន ភរិយាមួយដល់ខ្ញុំ។ ព្រះអង្គប្រទានគ្រួសាដល់ខ្ញុំ។ ព្រះអង្គ គឺជា អ្នកនាំផ្លូវដល់ ទូល បង្គំព្រះជាម្ចាស់អើយ។ សូមឲ្យកូនបានកាន់ព្រះហស្ត ព្រះអង្គកុំឲ្យកូន

វង្វេង ឡើយ។ បើសិនជាដៃមួយរោយ នោះទូលបង្គំនឹងដូរដៃ។ ព្រះអង្គអើយសូម ជួយ ទូលបង្គំ។

153 ហើយឥឡូវនេះសូមឲ្យម្នាក់ៗនៅទីនេះបានតោងជាប់ខ្សែជីវិតដូចគ្នានោះដែរ ព្រះអម្ចាស់អើយ ព្រះវិញ្ញាណបរិសុទ្ធគឺជាជីវិតរបស់ពួកយើង ជាប្រភពនៃជីវិត។ ហើយសូមឲ្យព្រះវិញ្ញាណដឹកនាំយើងទៅតាមផ្លូវនៃទឹកដីអំណរ ដែលសេចក្តី វេទនា ក្នុងជីវិតបានផុតទៅនិងកិច្ចការរបស់យើង នៅផែនដីបានចប់សព្វគ្រប់ហើយ និង គ្មានភាពចាស់ជរា គ្មានមនុស្សដែលល្វើយខ្សោយ គ្មានយប់ដែល នឿយហត់ គ្មានការយំសោក និងសេចក្តីអផិស្នាន គ្មានទីហៅសំរាប់អាសនា ប៉ុន្តែយើង នឹង ត្រឡប់ទៅជាក្មេងជារៀងរហូតនៅទីនោះជំងឺ និងទុក្ខព្រួយ នឹងគ្មាន ទៀតទេ។ នឹង គ្មានអំពើបាបហើយយើងនឹងនៅ ដោយ ភាពសុច្ចរិតទៀង ត្រង់ របស់ព្រះជាម្ចាស់ គ្រប់ ទាំងអាយុកាលដរាបដល់អស់កល្បជានិច្ច។ សូមឲ្យ សម្រេចតាម ព្រះវរបិតា ចុះ។

154 ហើយឥឡូវបិតាអើយ ប្រសិនជានៅយប់នេះមានអ្នកដែលមិនបានតោងជាប់ ខ្សែនៃជីវិតនោះ សូមឲ្យពួកគេស្វែងរកឃើញឥឡូវនេះ។ ហើយសូមឲ្យព្រះវិញ្ញាណ បរិសុទ្ធដែលជាអ្នកនាំផ្លូវ...ហើយខ្ញុំអាចនិយាយចេញពីចិត្ត ដោយដៃទូលបង្គំនៅ លើព្រះ បន្ទូលរបស់ព្រះអង្គ ត្បិតព្រះអង្គតែងតែត្រឹមត្រូវជានិច្ច។ ជាច្រើនលើកខ្ញុំ បាន ធ្វើខុស ប៉ុន្តែព្រះអង្គគឺត្រឹមត្រូវ។ សូមឲ្យព្រះអង្គគង់ នៅជាមួយ នឹងទូលបង្គំ ព្រះអង្គ ម្ចាស់ អើយសូមឲ្យទូលបង្គំនៅជាប់ជាមួយព្រះអង្គ។ ហើយសូមឲ្យអ្នក ផ្សេងទៀតនៅទីនេះ ដែលមិនទាន់ស្គាល់ព្រះអង្គនៅឡើយនៅយប់នេះ សូមឲ្យគេ បានកាន់ព្រះហស្តព្រះអង្គដែលមិនដែលប្រែប្រួល ដែលនឹងអាចនាំផ្លូវពួកគេទៅ។

155 ហើយថ្ងៃណាមួយដែលយើងនឹងចេញពីទន្លេ។ វានឹងមានអ័ព្ទនាព្រឹកនោះ។ សមុទ្រនឹងបោករញ្ជួយ ទន្លេយ័រដាន់ ភាពរុងរឿងនឹងបំផ្លាញ សេចក្តីស្លាប់នឹង ឆក់យកជីវិតទៅពីយើង។ ប៉ុន្តែ ព្រះអង្គអើយ ទូលបង្គំ—ទូលបង្គំនឹងមិនភ័យ ខ្លាច ឡើយ។ ទូលបង្គំបានដោះវាជាយូរមកហើយ។ គឺគ្រាន់តែដោះ មួកការពារ ចេញ ជាអ្នកចម្បាំង ក្រឡេកមើលជុំវិញ ងាកត្រឡប់ ក្រោយដើម្បីមើលខ្សែដែល បាននាំខ្ញុំមកនោះ។ មើល គ្រប់ទីរហោស្ថានដែលខ្ញុំបានឆ្លងកាត់ និងបន្លាដែលដុះ ជាច្រើន ហើយគ្រប់ទាំងគ្រាប់គ្រោះដែលធ្វើឲ្យមានស្នាមជាំ ប៉ុន្តែខ្ញុំនៅតែតោងជាប់

ខ្សែនោះ។ ដូចជានៅក្នុងកំណាព្យបានពោលថា "មានខ្លះចេញពីទឹក ខ្លះចេញពីព្យុះ មានខ្លះតាម រយៈការល្បងលដ៏ធ្ងន់ ប៉ុន្តែទាំងអស់នោះគឺតាមរយៈព្រះលោហិត។" ហើយទូលបង្គំចង់យកការទាំងនេះ ដាវដែលចាស់ បានការពារទូលបង្គំនៅតាមផ្លូវ ដែលបានដាក់នៅក្នុងស្រោម ស្រែកឡើងថា "ព្រះបិតា សូមជួយចម្លងទូកនៅព្រឹកនេះ ទូលបង្គំធ្វើដំណើរទៅផ្ទះ។" ព្រះជាម្ចាស់នឹងគង់នៅទីនោះ ព្រះអម្ចាស់។ ព្រះបានមានបន្ទូលសន្យា។ ព្រះអង្គមិនបរាជ័យឡើយ។

156 មានពរដល់អស់អ្នកដែលឮឥឡូវនេះ។ ហើយប្រសិនជាគេមិនដឹងពីរបៀបដែលត្រូវកាន់ខ្សែនោះទេ ហើយមិនធ្លាប់កាន់វា នោះសូមឲ្យដៃដ៏បរិសុទ្ធលើកឡើងឥឡូវ ជាដៃដែលចង់បាន ដៃនៃបំណងចិត្ត ហើយប៉ះខ្សែនៃជីវិតដែលនឹងនាំពួកគេទៅតាមបំណងចិត្តរបស់ពួកគេ សេចក្តីសុខសាន្តដ៏គ្រប់លក្ខ និង ភាពស្កប់ស្កល់ និង ការសំរាកនៅក្នុងព្រះគ្រីស្ទ។

157 ជាមួយនឹងក្បាលរបស់យើងអោនចុះ ដោយលើកដៃឡើងនិយាយថា "សូមឱ្យខ្ញុំ។ សូមកាន់ដៃទូលបង្គំ"? អូ ព្រះជាម្ចាស់ប្រទានពរអ្នក។

នៅពេលដែលផ្លូវ កាន់តែអាប់អួរ ព្រះអម្ចាស់អើយ សូមនៅក្បែរ
នៅពេលដែលជីវិតទូលបង្គំស្ទើរតែបាត់បង់
នៅក្បែរមាត់ទឹកដែលទូលបង្គំឈរ សូមនាំជើងទូល បង្គំកាន់ដៃទូលបង្គំ
ដឹកដៃទូលបង្គំ ព្រះអម្ចាស់អើយសូមនាំផ្លូវទូលបង្គំ។

158 តើមានអ្នកលើកដៃទៀតទេ ដោយនិយាយថា "ព្រះអម្ចាស់អើយ ទូលបង្គំចង់បានការប៉ះពាល់ខ្សែនៃជីវិតនាយប់នេះ។ ទូលបង្គំចង់មានអារម្មណ៍ថាព្រះអង្គអត់ទោសបាប ហើយចង់ក្លាយជាស្នាព្រហស្តបង្កើតថ្មីចាប់ពីពេលនេះតទៅ"? ព្រះអង្គ ប្រទាន ពរដល់អ្នក។ មានអ្នកដទៃទៀត និយាយថា "សូមឲ្យទូលបង្គំបានប៉ះពាល់ព្រះអង្គ។ ព្រះអង្គ ម្ចាស់ អើយ សូមឲ្យ ទូលបង្គំលះចោលខ្លួនឯង"? ព្រះអង្គប្រទានពរដល់ស្ត្រី ទាំង ឡាយ។ "សូមឲ្យទូលបង្គំ លះចោលខ្លួនឯង ព្រះអង្គអើយ និងរកឃើញ នៅក្នុងព្រះអម្ចាស់ គឺក្នុងទ្រង់។"ព្រះអង្គ ប្រទានពរអ្នកនិងព្រះអង្គប្រទានពរអ្នក។ ត្រូវហើយ។ សូមឲ្យទូលបង្គំ លះចោលខ្លួនឯង ព្រះអង្គអើយ។

សូមឲ្យទូលបង្គំភ្លេចខ្លួលឯង។ ព្រះអង្គ ប្រទានពរដល់បងប្អូនប្រុសៗ។"សូមឲ្យទូលបង្គំ..."ព្រះអង្គប្រទានពរបងប្អូនស្រីៗ។ "សូមឲ្យទូលបង្គំ លះចោល ចំណេះដឹង។" ព្រះអង្គប្រទានពរបងប្អូនស្រីៗ។ កុំទុកចិត្តផែនការ ដែល មនុស្សរៀបចំឡើយ។ ចូរដើរតាមអ្នកនាំផ្លូវ ព្រះអង្គនឹងដឹកនាំអ្នកទៅកាន់គ្រប់ទាំងសេចក្តីពិត។ "សូមដឹកនាំទូលបង្គំព្រះយេស៊ូវអើយសូមនាំផ្លូវទូលបង្គំ។" សូមព្រះអង្គប្រទានពរដល់អ្នកត្រឡប់ទៅទីនោះវិញ។ អូ មានដៃជាច្រើនបានលើកឡើង ចង់បានសេចក្តីសេចក្តីសង្គ្រោះ។ ឥឡូវនេះ ខណៈពេលដែលយើង...

159 ទីអាសនាទីនេះ អ្នកមិនអាចហៅថាទីអាសនាបានទេ ពីព្រោះមានមនុស្សអង្គុយនៅពេញ។ ប៉ុន្តែ ព្រះអង្គគង់នៅទីនេះ។ អ្នកស្គាល់ច្បាស់ណាស់ នៅពេលដែលអ្នកលើកដៃឡើង ប្រាកដជាមានអ្វីមួយកើតឡើងនៅក្នុងចិត្តរបស់អ្នក។ ព្រះយេស៊ូវមានបន្ទូលថា "អ្នកដែលបានឮពាក្យខ្ញុំហើយជឿលើអ្នកដែលបាន ចាត់ ឲ្យខ្ញុំមក នោះនឹងមានជីវិតអស់កល្បជានិច្ច។" អ្នកប្រាកដ? បន្ទាប់មកមាន អាងដែលមានទឹកពេញ។ គឺនឹងមានពេលជាច្រើនសម្រាប់ពីធីជ្រមុជទឹក។ ចូរយើងអធិស្ឋាន។

160 ព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ ព្រះរាជសានៅយប់នេះតាមរយៈសម្លេងដែលស្អក ព្រះវិញ្ញាណបរិសុទ្ធគួរតែនៅកន្លែងណាមួយ។ គឺព្រះវិញ្ញាណនឹងទៅកាន់កន្លែងណាដែលគួរនឹងទៅ ព្រះអម្ចាស់អើយ គឺមានច្រើន ណាស់នៅ យប់នេះ មានដប់ប្រាំទៅម្ភៃនាក់បានលើកដៃ ដែលពួកគេត្រូវការអ្នកនាំផ្លូវ។ ពួក គេដឹងថាពួកកំពុងតែព្យាយាមបញ្ឆោតខ្លួន។ ដោយព្យាយាមនិយាយថា "ខ្ញុំមិន អីទេ" ប៉ុន្តែនៅក្នុងជម្រៅចិត្តពួកគេដឹងថាគឺមិនមែនមិនអីទេ។ គឺពួកគេចង់បានព្រះអង្គ។ ពួកគេចង់បានអ្នកនាំផ្លូវ។ ពួកគេចង់ចូលទៅកាន់ព្រះអង្គ។ ត្បិត ព្រះ អង្គជាឃ្លាំងដែលពេញរបស់គេ។ ពួកគេចង់ចុះឈ្មោះចូលនៅ ក្នុងការធ្វើ ដំណើរ នេះ។ ពួកគេអត់ស្គាល់ផ្លូវទៅទីនោះទេ។ គឺមិនមាននរណាម្នាក់ដឹងពីរបៀប ដែល ជួយពួកគេទេ គឺមានតែព្រះអង្គទេដែលដឹង។ ពួកគេចូលមករកការនាំផ្លូវរបស់ព្រះអង្គ គឺព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេបានលើងដៃឡើង។

161 ឱព្រះវិញ្ញាណបរិសុទ្ធ និង អ្នកនាំផ្លូវអើយ សូមយាងមកសណ្ឋិតលើពួកគេ។ សូមអត់ទោសនូវរាល់អំពើបាប។ អត់ទោសសេចក្តីរំលងរបស់ពួកគេ។ សូមទទួល

ពួកគេចូលទៅក្នុងរូបកាយ របស់ព្រះគ្រីស្ទនៅយប់នេះ ដើម្បីឲ្យពួកគេបានស្គាល់ព្រះអង្គដែលនឹងដឹកនាំផ្លូវពួកគេតាមខ្សែដែលនឹងនាំពួកទៅដល់ទន្លេយ័រដាន់ និងឆ្លងកាត់ទន្លេយ័រដាន់ ទៅកាន់ទឹកដីសន្យា។ សូមឲ្យពួកគេដើរតាមត្រង់ពីក្រោយព្រះបន្ទូល។ ព្រះមានបន្ទូលថា "ចូរប្រែចិត្ត ហើយធ្វើពិធីជ្រមុជទឹកនៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។" ពួកគេប្រហែលជាមិនសាកផ្លូវផ្សេងទេ។ ពួកគេ អាចដើរពីក្រោយព្រះបន្ទូល ដោយព្រះអង្គជាអ្នកដែលនឹងនាំផ្លូវ។ ជា—ជំហ៊ាន ឡើងរហូតដល់យើងអាច កាន់តោងអ្នកនាំផ្លូវ។ សូមទទួលយកព្រះអម្ចាស់អើយ។ សូមឱ្យពួកគេក្លាយ ជារបស់ព្រះអង្គ។ ឥឡូវពួកគេនៅក្នុងព្រះហស្ថ របស់ព្រះអង្គដូចជាភួងជ័យដែលនឹងគ្មានអ្នកណាដែលអាចនឹងដកចេញពីពួកគេបានឡើយ។ ខ្ញុំជឿថាព្រះអង្គ នឹង ទទួលយកពួកគេ ជាប្រជារាស្ត្រដែលបានសង្គ្រោះហើយ។ ខ្ញុំជឿ ថាពួគេលើកដៃ គឺពួកគេមិនអាចធ្វើបានដោយឯកឯងនោះទេ ទាល់តែព្រះអង្គមានបន្ទូលទៅកាន់ពួកគេ។ គឺជាព្រះអង្គហើយ ជាព្រះវិញ្ញាណបរិសុទ្ធ និងជាអ្នកនាំផ្លូវ។

162 គេដឹងថាពេលវេលាជិតដល់ហើយអ័ព្ទកំពុងតែធ្លាក់មកលើផែនដីគោលទិ្ធធំៗជាច្រើន និង—និង ភាពបែកខ្ញែកជាច្រើន ការរួបរួមព្រះវិហារ តែមួយ។ ហើយ ឱព្រះជាម្ចាស់អើយតើពួកគេព្យាយាមនិយាយដោយរបៀបណា "អស់អ្នក ដែលមានលក្ខណៈពិសេស នឹងត្រូវចាកចេញទៅកាន់អាឡាស្កា។" ហើយអ្វីដែល ពួកគេទទួលការគំរាមកំហែង គឺមិនមែនជាអ្វីដែលថ្មីសម្រាប់យើង ទេ គឺអ្នកនាំផ្លូវ ដែលអស្ចារ្យដែលបានបង្ហាញយើងនៅក្នុងផ្លូវនៃព្រះបន្ទូល។ យើងគ្រាន់តែដើរឆ្លងកាត់ផ្លូវនោះទេ។

163 ព្រះវរបិតាដ៏ជាព្រះជាម្ចាស់អើយ សូមព្រះអង្គមានបន្ទូលទៅកាន់ពួកគេ នៅយប់នេះ និងឥឡូវនេះទូលបង្គំ សូមថ្វាយពួកគេទៅកាន់ព្រះអង្គទុកដូចជាភួងជ័យរបស់ព្រះបន្ទូល។ នៅក្នុង ព្រះនាមព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ។

164 ឥឡូវនេះព្រះអង្គ នៅលើតុមានកន្សែងដៃ គឺសម្រាប់អ្នកដែលឈឺ មានទារកមានម្តាយ បងប្អូនប្រុសស្រី ដែលពួកគេបានជាប់នៅក្នុងដង្កៀបនោះ។ ហើយឥឡូវ ទូលបង្គំលើកឡើងមកជិតទូលបង្គំ។ ឥឡូវ យើងបានបង្រៀននៅ ក្នុងព្រះគម្ពីរ ដែល ពួក គេ បានដកចេញពីរូបកាយនៃ រូបកាយទាំងមូលរបស់ប៉ុល ហើយមនុស្សដែលឈឺបានទទួលការប្រោសឲ្យជា វិញ្ញាណអសោចចេញពីមនុស្សដែល

មានរូបកាយមិនស្អាត។ ឥឡូវព្រះអម្ចាស់យើងដឹងថាលោកប៉ូលជាមនុស្ស គឺគាត់គ្រាន់តែជាមនុស្ស។ ប៉ុន្តែគាត់បានទទួល ការចាក់ប្រេងតាំងដោយព្រះវិញ្ញាណដ៏វិសុទ្ធ គាត់បានអធិស្ឋានសម្រាប់កន្សែងនេះ ហើយសេចក្តីជំនឿដែលមនុស្សមាន គឺគាត់ជាសាវ័ករបស់ទ្រង់។ ឥឡូវនេះ លោកប៉ូលត្រូវបានដកចេញពីពួកយើងរាល់គ្នាហើយ ប៉ុន្តែមិនបានដកអ្នកនាំផ្លូវទេ ព្រះអង្គនៅតែគង់នៅទីនេះ។ ហើយព្រះជាម្ចាស់ ទូលបង្គំសូមអធិស្ឋាន សូមឲ្យព្រះអង្គប្រទានពរដល់កន្សែងទាំងនេះ ហើយសូមឲ្យអ្នកនាំផ្លូវបាននាំពួកគេទៅកាន់ទីកន្លែង ដែលមានការថ្វាយខ្លួនយ៉ាងពេញលេញ។

165 យើងបានប្រាប់ម្តងទៀតថានៅពេលដែលអ៊ីស្រាអែល បានដើរតាមអ្នកនាំ ផ្លូវរបស់ពួកគេ ហើយធ្វើដំណើរទៅ កាន់ទន្លេយ័រដាន់ (ជាជាង) ទៅកាន់សមុទ្រ ក្រហម។ ស្ថិតនៅក្នុងជួរនៃការបំពេញកាតព្វកិច្ច ពួកគេបានឈប់ ហើយអ្នក នាំផ្លូវបាននាំគេទៅដល់ទីនោះ។ អ្វី?គឺដើម្បីបង្ហាញពីសេរីល្អរបស់ព្រះអង្គ។ ហើយ នៅពេលដែលទីសង្ឃឹមទាំងអស់បានបាត់ទៅបន្ទាប់មកព្រះជាម្ចាស់ បាន ទតមើលតាមរយៈសរសរភ្លើង ហើយសូម្បីតែសមុទ្រមរណៈ ដ៏ចាស់ មានភាពភ័យ ខ្លាចហើយបានញែកក្រោយ ហើយធ្វើជាផ្លូវសម្រាប់ប្រជារាស្ត្រអ៊ីស្រាអែលដើរ ឆ្លងកាត់ទៅកាន់ទឹកដីសន្យា។

166 ប្រាកដណាស់ ព្រះអម្ចាស់ ព្រះអង្គនៅតែដដែល។ ពួកគេទាំងនេះ ប្រហែលជា គ្រីស្ទាន គេកំពុងតែស្ថិតនៅក្នុងផ្លូវនៃការបំពេញកាតព្វកិច្ច ប៉ុន្តែពួកគេត្រូវបាន នាំ ទៅកាន់កន្លែងមួយដែល មានជំងឺដែល ជាជ្រុងមួយរប ស់ពួកគេ។ សូមសម្លឹងមើលមកក្រោមតាមរយៈព្រះលោហិតរបស់ ព្រះយេស៊ូវនៅក្នុងយប់នេះ នោះវិញ្ញាណ អាក្រក់នឹងមានភាពភ័យខ្លាច វានឹងបែរក្រោយ ហើយកូនៗរបស់អ្នក នឹងមានសុខភាពល្អ។ សូមទទួលយកឱព្រះបិតាអើយ។ កូនសូមផ្ញើរពីរូបកាយរបស់ខ្ញុំ ទៅកាន់ពួកគេ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។

167 ទូលបង្គំសូមលើកថ្វាយពួកគេនៅចំពោះព្រះអង្គ ដោយជំនឿ ដោយនាំគេទៅកាន់សេរីល្អ នៃអាសនារបស់ព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌។ គ្រប់ទាំងបំណង ចិត្តរបស់អ្នកជំងឺ គ្រប់ទាំងជម្ងឺដែលពួកគេមាន ហើយអ្វីដែលកើត ឡើងនៅក្នុងជីវិតរបស់ពួកគេ នៅគ្រប់ទីកន្លែង ព្រះអង្គអើយ សូមសម្អាតពួកគេសូម ធ្វើឲ្យពួកគេក្លាយទៅជាកម្មសិទ្ធរបស់ព្រះអង្គ។ សូមព្យាបាលពួកគេព្រះអង្គ។ ហើយ

សូមឲ្យអំណាចដែលបានប្រោសព្រះយេស៊ូវរស់ពីផ្នូរសូមប្រោសនិងធ្វើឲ្យរូបកាយនោះត្រឡប់ជាថ្មីវិញនៅក្នុងព្រះគ្រីស្ទ។ សូមប្រទានឲ្យពួកគេមានសុខភាពល្អនិងកម្លាំងដើម្បីបម្រើព្រះអង្គ។

168 សូមនឹកចាំពីទូលបង្គំ ឱព្រះអម្ចាស់អើយ។ ទូលបង្គំជាអ្នកបម្រើរបស់ ព្រះអង្គ។ សូមជួយទូលបង្គំ ឈរនៅក្នុងតម្រូវការនៃសេចក្តីអធិស្ឋាន។ ហើយទូលបង្គំអធិស្ឋាន សម្រាប់ព្រះវិញ្ញាណបរិសុទ្ធ នឹងដឹកនាំពួកយើង ហើយប្រើយើង រហូតដល់ ថ្ងៃដែលយើងមើលឃើញព្រះភក្ត្រព្រះយេស៊ូវមុខទល់នឹងមុខ នៅក្នុងសេរីល្អរបស់ព្រះអង្គយាងមកនៅពេលដែលយើងជួបជាមួយទ្រង់នៅក្នុងអាកាសនៅគ្រាដែលព្រះអង្គលើកយើងទៅជាមួយ។ យើងទូលសូមនៅក្នុងព្រះនាមរបស់ព្រះគ្រីស្ទ។ អាម៉ែន

ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំ...ចុះអ្នកវិញ?)
ព្រោះទ្រង់ស្រឡាញ់ខ្ញុំមុន
ហើយបានបង់ថ្លៃសង្គ្រោះខ្ញុំ
លើដើមឈើកាល់វ៉ារី។

169 ឥឡូវ ប្រសិនជាអ្នកមិនស្រឡាញ់ដល់បងប្អូន ដែលអ្នករាល់គ្នាមើលឃើញ តើអ្នកនឹងអាច ស្រឡាញ់ដល់ព្រះអង្គដែល មើលមិនឃើញដោយរបៀបណា? ឥឡូវ ខណៈពេលដែលយើងច្រៀងថា *ខ្ញុំស្រឡាញ់ព្រះអង្គ* ចូរយើងទៅចាប់ដៃអ្នកជិតខាងយើងដោយចេញពីចិត្ត ដោយក្តីស្រឡាញ់។

ខ្ញុំស្រឡាញ់ទ្រង់...

សូមព្រះអង្គប្រទានពរអ្នក...?...សូមព្រះប្រទានពរអ្នក...?...សូមព្រះ ប្រទានពរអ្នក...?...សូមព្រះប្រទានពរ បងប្រុសណេវីល...?...អ+–ហ។ សូមព្រះ ប្រទានពរអ្នក...?...

លើដើមឈើកាល់វ៉ារី។

ឥឡូវចូរលើកដៃអ្នកឡើងទៅកាន់ព្រះអង្គ។

ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំស្រឡាញ់ទ្រង់
ព្រោះទ្រង់បានស្រឡាញ់ខ្ញុំមុន
ហើយបានបង់ថ្លៃសង្គ្រោះខ្ញុំ
លើដើមឈើកាល់វ៉ារី។

170 សម្រាប់បទចម្រៀងដ៏ពិរោះ តើអ្នកចង់ស្ដាប់ទេ? ខ្ញុំយល់ថាយើងមានក្រុមដឹកនាំ ចម្រៀងដំណឹងល្អនៅទីនេះមកពី អិនឌីអាណាប៉ូលិស។ ខ្ញុំជឿថា គាត់ច្រៀង នៅឯ រោងឧបោសថ ខាដល។ តើត្រូវឬអត់? ត្រឹមត្រូវហើយលោក។ នៅកន្លែង របស់គាត់នៅ រោងឧបោសថ ខាដល។ មានប៉ុន្មាននាក់ចងចាំ អ៊ី.ហ្វូវីដ ខាដល? អូ ខ្ញុំអើយ! ព្រះជាម្ចាស់ឲ្យព្រលឹងដ៏មាន តម្លៃរបស់ គាត់បាន សម្រាក។ បក្សាបក្សី ស្រែកច្រៀងនៅលើអាកាស ស្ដាប់ស្ត្រីដែលខ្ញុំស្រឡាញ់ច្រៀង គឺលើសជាងអ្វីដែលខ្ញុំធ្លាប់ឮនៅក្នុងជីវិតរបស់ខ្ញុំ តើជាអ្នកស្រី ខាដល ច្រៀង "តើ អ្នកបានចេញពី បន្ទប់របស់អ្នកកាលពីព្រឹកមិញ តើអ្នកបានបានគិត ដល់ការអធិ ស្ឋាន នៅក្នុងព្រះនាមព្រះគ្រីស្ទ ព្រះអង្គសង្គ្រោះរបស់យើង ទុកដូចជាខែលថ្ងៃនេះឬទេ?"

171 នៅព្រឹកមួយកនៅឆ្លងផ្លូវម្ខាងនៅក្នុងបន្ទប់ក្នុងខ្ទមចំណាស់មួយខ្ញុំបានក្រោក ឡើង ដើម្បីទៅបង្កាត់ភ្លើង។ តែចង្ក្រាននោះមិនព្រមឆេះសោះ។ ហើយខ្ញុំព្យាយាម បង្កាត់ ភ្លើងតែខ្យល់ចេះតែបក់មក គឺបក់បើុងអ្វីនៅពីមុខខ្ញុំអស់។ គឺរងាខ្លាំងស្ទើរ តែកក។ នៅបរិវេណជុំវិញគឺមានកំណកទឹកកក ហើយខ្ញុំនៅដើងទទេព្យាយាម បង្កាត់ភ្លើងនៅ ក្នុង ចង្ក្រានដ៏ចាស់នោះ មានចង្ក្រានបំពង់ផ្សែ។ ហើយខ្ញុំគ្រាន់តែ... មីដា និងខ្ញុំទើបតែរៀបការហើយ មិនយូរប៉ុន្មាន។ ហើយខ្ញុំព្យាយាមយកកំទេច ឈើចាស់ៗតែវានៅសើម ដូច្នេះ ហើយ ទើប ភ្លើងវាមិនកាត់ ហើយខ្ញុំអង្គុយនៅទីនោះខ្ញុំគិត "អូអើយ! ខ្ញុំនឹងព្យាយាមម្ដងទៀត។" ត្រូវទៅធ្វើការហើយ ហើយបាន ទុកចង្ក្រាន ចាស់នោះចោលនៅក្នុងសភាពបែបនោះ។ ហើយខ្ញុំបានបើកវិទ្យុ មីដាចាប់ផ្ដើមច្រៀង "តើអ្នកចេញពីបន្ទប់នៅព្រឹកនេះ តើអ្នកមានគិតពីសេចក្ដី អធិស្ឋាន ទេ" ខ្ញុំគ្រាន់តែ មានអារម្មណ៍ ថាចង់ក្រាបខ្លួនចុះនឹងដី "នៅក្នុងព្រះនាមរបស់ព្រះគ្រីស្ទជាព្រះសង្គ្រោះរបស់យើង ដូចជាខែលនៅថ្ងៃនេះ?" អូ តើខ្ញុំចូលចិត្តស្ដាប់ស្ត្រីនោះយ៉ាងណាទៅហ្ន៎!

172 នៅពេលខ្ញុំឆ្លងកាត់ទឹកទន្លេពេលខ្លះ ខ្ញុំជឿ ខ្ញុំឮថាអ្នកស្រី ខាដល អង្គុយនៅ

ទីនោះ ។ អ្នកដឹងទេ ខ្ញុំតែងតែធ្វើការណាត់ជួប។ នៅឯត្រើយម្ខាង មានដើមឈើខៀវស្រងាត់ អ្នកដឹងទេដើមឈើនោះជាដើមឈើជីវិតនិង នៅត្រើយម្ខាងទៀតមានឮចម្រៀងរបស់ទេវតាច្រៀងទាំងថ្ងៃ និងយប់ ពីព្រោះគ្មានយប់ទេនៅទីនោះ គឺមានតែថ្ងៃ។ ខ្ញុំនឹងទៅដល់ទីនោះហើយអង្គុយស្តាប់បទចម្រៀងនោះ។ ខ្ញុំជឿថាខ្ញុំ នឹង ឮអ្នកស្រីខាដល នៅទីនោះកំពុងតែច្រៀង។

173 សូមព្រះជាម្ចាស់ ប្រទានពរដល់បងប្អូនយើង ខ្ញុំបានភ្លេចឈ្មោះគាត់បាត់ហើយ។ តើគាត់ឈ្មោះអ្វី? [បងប្រុសនោះឆ្លើយថា "Ned Woolman។"—Ed។] បងប្រុសនេដវ៉ុលមែន(Ned Woolman)នឹងច្រៀងសម្រាប់បងប្អូន។ បងប្រុស Ned Woolman រីករាយដែលមានវត្តមានបងប្រុសនៅជាមួយពួកយើងនៅយប់នេះ។ [បងប្រុស Woolman ច្រៀងបទ*ឧបោសថនៃដួងចិត្តខ្ញុំ*]។

**មគ្គុទ្ទេសក៍ម្នាក់** KHM62-1014E

(A Guide)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាចថ្ងៃអាទិត្យ ថ្ងៃទី ១៤ តុលា ១៩៦២ នៅ Branham Tabernacle in Jeffersonville, Indiana, U.S.A.។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបកប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

**ការរក្សាសិទ្ធ**

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG